EDUCATION 2030

# វិស័យអប់រំឆ្នាំ ២០៣០

## សេចក្ដីប្រកាសទីក្រុង Incheon

## និង

## ក្របខ័ណ្ឌសម្រាប់សកម្មភាព

### ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា

UNESCO · UNDP · UNFPA · UNHCR The UN Refugee Agency · unicef · UN WOMEN United Nations Entity for Gender Equality and the Empowerment of Women · WORLD BANK GROUP

ឯកសារនេះត្រូវបានបកប្រែពីភាសាអង់គ្លេស និងត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយ
ក្រុមការងារអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP)។

ភាពខ្វះចន្លោះនៃការបកប្រែមិនមែនជាការទទួលខុសត្រូវរបស់អង្គការភាពជាដៃគូ
អប់រំនៃអង្គការក្រៅរដ្ឋាភិបាលទេ។

# វិស័យអប់រំឆ្នាំ ២០៣០

## សេចក្តីប្រកាសទីក្រុងអ៊ីនឈុន

ឆ្ពោះទៅរកការអប់រំមានគុណភាព
បរិយាប័ន្ន សមធម៌ និង
ការសិក្សាពេញមួយជីវិត
សម្រាប់ទាំងអស់គ្នា

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ(យូណេស្កូ) សហការជាមួយនឹងមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ(យូនីសេហ្វ) ធនាគារពិភពលោក មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(យូអេនអេហ្វភីអេ) កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ(យូអេនឌីភី) អង្គភាពនៃអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការពង្រឹងអំណាចរបស់ស្ត្រី (យូអេនវីមីន) និងឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(យូអិនអេចស៊ីអរ) បានរៀបចំវេទិកាពិភពលោក ស្តីពីវិស័យអប់រំឆ្នាំ ២០១៥ នៅទីក្រុង អ៊ីនឈុន (Incheon) សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៩ ដល់ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ ដែលរៀបចំដោយសាធារណរដ្ឋកូរ៉េ។ អ្នកចូលរួមប្រមាណជាង១៦០០នាក់ ដែលមកពី១៦០ ប្រទេសរួមមានរដ្ឋមន្ត្រីជាង១២០រូប ប្រមុខរដ្ឋ និងសមាជិកនៃគណៈប្រតិភូប្រធានភ្នាក់ងារ និងក្រុមមន្ត្រីនៃអង្គការពហុភាគី និងទ្វេភាគី និងតំណាងនៃអង្គការសង្គមស៊ីវិលក្នុងវិជ្ជាជីវៈបង្រៀនយុវជន រួមទាំងវិស័យឯកជនបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងអ៊ីនឈុនសម្រាប់វិស័យអប់រំឆ្នាំ ២០៣០ ដែលកំណត់នូវចក្ខុវិស័យថ្មីមួយសម្រាប់វិស័យអប់រំរយៈពេលដប់ប្រាំឆ្នាំនាពេលខាងមុខ។

# បុព្វកថា

១. យើងជារដ្ឋមន្ត្រី ប្រមុខរដ្ឋ និងសមាជិកនៃគណៈប្រតិភូ ប្រធានទីភ្នាក់ងារ ក្រុមមន្ត្រីនៃអង្គការពហុភាគីនិងទ្វេភាគី និងអ្នកតំណាងសង្គមស៊ីវិល អ្នកវិជ្ជាជីវៈបង្រៀន យុវជនរួមទាំងវិស័យឯកជនបានប្រមូលផ្តុំគ្នានៅក្នុងខែឧសភា ឆ្នាំ២០១៥ តាមការអញ្ជើញរបស់អគ្គនាយកនៃអង្គការយូណេស្កូនៅទីក្រុងអ៊ីនឈុន (Incheon) នៃសាធារណៈរដ្ឋកូរ៉េ សម្រាប់វេទិកាពិភពលោកស្តីពីវិស័យអប់រំឆ្នាំ ២០១៥ (WEF ឆ្នាំ ២០១៥)។ យើងសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណៈរដ្ឋកូរ៉េដែលបានរៀបចំពិធីដ៏មានសារៈសំខាន់នេះក៏ដូចជាដៃគូសហការដូចជាអង្គការ យូនីសេហ្វ ធនាគារពិភពលោក អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជាន កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ អង្គភាពនៃអង្គការសហប្រជាជាតិសម្រាប់សមភាពយេនឌ័រ និងការពង្រឹងអំណាចរបស់ស្ត្រី(យូអេនវីមីន) និងឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនដែលបានចូលរួមចំណែកក្នុងកិច្ចប្រជុំនេះ។ យើងសូមសម្តែងនូវការកោតសរសើរដោយស្មោះដល់អង្គការយូណេស្កូ សម្រាប់គំនិតផ្តួចផ្តើម និងការដឹកនាំកិច្ចប្រជុំនៃព្រឹត្តិការណ៍សំខាន់នេះសម្រាប់វិស័យអប់រំឆ្នាំ ២០៣០ ។

២. នៅក្នុងឱកាសជាប្រវត្តិសាស្ត្រនេះ យើងបានបញ្ជាក់សាជាថ្មីនូវចក្ខុវិស័យនៃចលនានៅទូទាំងពិភពលោកលើវិស័យអប់រំសម្រាប់ទាំងអស់គ្នាដែលបានផ្តួចផ្តើមឡើងនៅ Jomtien នាឆ្នាំ១៩៩០ និងបានរំលឹកឡើងវិញនៅ **Dakar** នាឆ្នាំ២000 ដែលជាការប្តេជ្ញាចិត្តសំខាន់ជាងគេបំផុតនៅប៉ុន្មានទសវត្សចុងក្រោយនេះ ដើម្បីឲ្យវិស័យអប់រំមានការរីកចំរើន។ យើងក៏បានបញ្ជាក់ជាថ្មីនូវទស្សនៈវិស័យ និងឆន្ទៈនយោបាយដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សថ្នាក់តំបន់ និងអន្តរជាតិជាច្រើនដែលបានចែងពីសិទ្ធិក្នុងការទទួលបានការអប់រំ និងទំនាក់ទំនងរបស់ខ្លួនជាមួយនឹងសិទ្ធិមនុស្សដទៃទៀត។ ទោះជាយើងទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងកន្លងមកក្តី យើងក៏ត្រូវទទួលស្គាល់នូវក្តីកង្វល់ជាខ្លាំងថា យើងពិតជានៅឆ្ងាយពីការឈានដល់ការសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា។

៣. យើងសូមរំលឹកដល់កិច្ចព្រមព្រៀងទីក្រុងម៉ាសកាត (Muscat) ដែលបានបង្កើតឡើងតាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងត្រូវបានអនុម័តនៅកិច្ចប្រជុំជាសកលស្តីពីវិស័យអប់រំសម្រាប់ទាំងអស់គ្នា (EFA)ឆ្នាំ២០១៤ ដែលបានផ្តល់ជាតុចូលដល់គោលដៅអប់រំ ដែលបានដាក់ស្នើជូនដល់ក្រុមការងារគោលដៅអភិវឌ្ឍន៍ដោយចីរភាព(SDGs)។ យើងក៏សូមរំលឹកដល់លទ្ធផលនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីប្រចាំតំបន់ ស្តីពីវិស័យអប់រំក្រោយឆ្នាំ២០១៥ និងសូមធ្វើការកត់សម្គាល់ដល់ការរកឃើញរបស់របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០១៥ និងរបាយការណ៍សំយោគថ្នាក់តំបន់លើការអប់រំសម្រាប់ទាំងអស់គ្នា។ យើងទទួលស្គាល់ការចូលរួមវិភាគទានដ៏មានសារៈសំខាន់នៃការផ្តួចផ្តើមលើកដំបូងជាសកលលើការអប់រំ ក៏ដូចជាតួនាទីរបស់រដ្ឋាភិបាល និងស្ថាប័នថ្នាក់តំបន់ ស្ថាប័នអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការប្រមូលការប្តេជ្ញាចិត្តថ្នាក់នយោបាយសម្រាប់វិស័យអប់រំ។

៤. យើងអនុម័តសេចក្តីប្រកាសនេះក្រោយពីពិនិត្យលើដំណើរការឆ្ពោះទៅរកគោលដៅអប់រំសម្រាប់ទាំងអស់គ្នាចាប់តាំងពីឆ្នាំ២000 និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(MDGs)ដែលទាក់ទងនឹងការអប់រំព្រមទាំងមេរៀនដែលបានជួបប្រទះ ការពិនិត្យលើបញ្ហាប្រឈមដែលនៅសេសសល់ និងបានពិភាក្សាលើរបៀបវារៈដែលបានស្នើ

ឡើងសម្រាប់វិស័យអប់រំឆ្នាំ២០៣០ លើក្របខ័ណ្ឌសម្រាប់សកម្មភាព ក៏ដូចជាអាទិភាព និងយុទ្ធសាស្ត្រនានា នៅពេលអនាគតដើម្បីទទួលបានជោគជ័យ។

## ឆ្ពោះទៅរកឆ្នាំ២០៣០: ចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំ

៥. ចក្ខុវិស័យរបស់យើងគឺការផ្លាស់ប្តូរជីវិតឲ្យប្រសើរឡើងតាមរយៈការអប់រំ ដោយទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់ នៃការអប់រំថាជាក្បាលម៉ាស៊ីនចម្បងមួយនៃការអភិវឌ្ឍ និងការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពផ្សេងទៀត។ យើងបានប្តេជ្ញាចិត្តជាមួយនឹងការយល់ដឹងពីភាពបន្ទាន់ដើម្បីឆ្ពោះទៅរករបៀបវារៈវិស័យអប់រំទោលថ្មីមួយដែលប្រកបដោយលក្ខណៈពិស្តារ មហិច្ឆតា និងក្តីសង្ឃឹមដែលនឹងមិនទុកនរណាម្នាក់ចោលនៅពីក្រោយឡើយ។ ចក្ខុវិស័យថ្មីនេះត្រូវបានឆ្លើយតបយ៉ាងពេញលេញដោយ SDG 4 ដែលបានស្នើឡើងថា ***"ធានាឲ្យបាននូវការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ រួមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"*** ដោយមានការកំណត់គោលដៅរបស់ខ្លួន។ ចក្ខុវិស័យនេះមានភាពផ្លាស់ប្តូរជីវិតឲ្យប្រសើរឡើង និងមានភាពសកលដោយត្រៀមខ្លួនឆ្លើយតបទៅនឹង "រឿងរ៉ាវដែលមិនទាន់បានបញ្ចប់" របស់របៀបវារៈការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលទាក់ទងនឹងការអប់រំ និងដោះស្រាយបញ្ហាប្រឈមការអប់រំថ្នាក់សកល និងថ្នាក់ជាតិ។ ចក្ខុវិស័យនេះ ត្រូវបានបំផុសគំនិតដោយទស្សនៈវិស័យយកតម្រូវការរបស់មនុស្សជាធំ (បែប humanistic) នៃការអប់រំ និងការអភិវឌ្ឍដោយផ្អែកលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរក៏ដូចជាយុត្តិធម៌សង្គម ការរួមបញ្ចូលគ្នា ការការពារ ភាពសម្បូរបែបនៃវប្បធម៌ ភាសា និងភាពចំរុះពូជសាសន៍ និងការទទួលខុសត្រូវរួមគ្នា។ យើងបញ្ជាក់ជាថ្មីថា ការអប់រំគឺជាផលដែលសាធារណៈជនត្រូវទទួលបាន គឺជាសិទ្ធិមូលដ្ឋានរបស់មនុស្ស និងជាមូលដ្ឋានសម្រាប់ធានាការសម្រេចបាននូវសិទ្ធិផ្សេងទៀត។ ចក្ខុវិស័យនេះ គឺជាការចាំបាច់សម្រាប់សន្តិភាព ការអត់ឱន ការបំពេញចំណង់របស់មនុស្ស និងការអភិវឌ្ឍដោយចីរភាព។ យើងទទួលស្គាល់ការអប់រំជាគន្លឹះដើម្បីសម្រេចបាននូវការងារពេញលេញ និងការលុបបំបាត់ភាពក្រីក្រ។ យើងនឹងផ្តោតកិច្ចខិតខំរបស់យើងលើការទទួលបានសមភាពនិងបរិយាប័ន្ន គុណភាព និងលទ្ធផលសិក្សាដែលមានវិធីសាស្ត្រសិក្សាពេញមួយជីវិត។

៦. ដោយមានការជម្រុញលើកទឹកចិត្តពីជោគជ័យធំៗរបស់យើងក្នុងការបង្កើន **ការផ្តល់ឱកាសទទួលបាន** ការអប់រំក្នុងរយៈពេល១៥ឆ្នាំចុងក្រោយនេះ យើងនឹងធានាឱ្យបាននូវការផ្តល់ជូនដោយឥតគិតថ្លៃលើសេវាសាធារណៈថ្នាក់បឋមសិក្សា និងមធ្យមសិក្សារយៈពេល១២ឆ្នាំប្រកបដោយគុណភាព សមភាព ដែលក្នុងនោះយ៉ាងហោចណាស់ប្រាំបួនឆ្នាំដែលជាកាតព្វកិច្ចនាំឱ្យមានលទ្ធផលសិក្សានានាដែលពាក់ព័ន្ធ។ យើងលើកទឹកចិត្តដល់ការផ្តល់ការអប់រំយ៉ាងហោចណាស់មួយឆ្នាំសម្រាប់ថ្នាក់មុនបឋមសិក្សាដោយឥតគិតថ្លៃ និងជាកាតព្វកិច្ចប្រកបដោយគុណភាព និងធានាផងដែរថា កុមារទាំងអស់មានឱកាសទទួលបានការអប់រំកុមារតូច និងការថែទាំប្រកបដោយគុណភាព។ យើងក៏ប្តេជ្ញាផ្តល់ការអប់រំប្រកបដោយអត្ថន័យ និងផ្តល់ឱកាសទទួលបានការបណ្តុះបណ្តាលដែលជាតម្រូវការបន្ទាន់ដល់កុមារ និងមនុស្សវ័យជំទង់ក្រៅសាលាជាច្រើនតាមការកំណត់គោលដៅ និងសកម្មភាពជានិរន្តរ៍ ដើម្បីឲ្យប្រាកដថា កុមារទាំងអស់គឺស្ថិតនៅក្នុងសាលា និងកំពុងសិក្សា។

៧. **បរិយាប័ន្ន និងសមធម៌** នៅក្នុងនិងតាមរយៈការអប់រំគឺជាមូលដ្ឋាននៃការអប់រំមួយដែលមានការផ្លាស់ប្តូរ ដូចនេះយើងត្រូវប្តេជ្ញាដោះស្រាយគ្រប់ទម្រង់ទាំងអស់នៃការរើសអើង ការផាត់ចេញពីសង្គម ការប្រកាន់ភាពខុសគ្នា

និងវិសមភាពក្នុងការទទួលបានឱកាសការចូលរួម និងការទទួលលទ្ធផលសិក្សា។ ប្រសិនបើគោលដៅទាំងនេះមិនបានឆ្លើយតបទេ ត្រូវចាត់ទុកថាគោលដៅអប់រំទាំងអស់មិនបានទទួលជោគជ័យឡើយ។ ដោយហេតុដូច្នេះហើយ យើងបានប្តេជ្ញាធ្វើឱ្យមានការផ្លាស់ប្តូរជាចាំបាច់លើគោលនយោបាយវិស័យអប់រំ និងផ្តោតកិច្ចខិតខំរបស់យើងលើអ្នកដែលជួបការលំបាកបំផុត ជាពិសេសជនពិការ ដើម្បីធានាថាគ្មាននរណាម្នាក់ត្រូវបានគេបោះបង់ទេ។

៨. យើងទទួលស្គាល់ពីសារៈសំខាន់នៃ**សមភាពយេនឌ័រ** ក្នុងការសម្រេចឲ្យបាននូវសិទ្ធិក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។ ហេតុនេះហើយ យើងត្រូវប្តេជ្ញាចិត្តដើម្បីគាំទ្រដល់គោលនយោបាយឆ្លើយតបចំពោះយេនឌ័រ ការធ្វើផែនការ និងបរិយាកាសសិក្សា ការបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងកម្មវិធីសិក្សា និងលុបបំបាត់ការរើសអើងយេនឌ័រជាមូលដ្ឋាន និងអំពើហឹង្សាក្នុងសាលារៀន។

៩. យើងបានប្តេជ្ញាលើការអប់រំដែលមាន**គុណភាព** និងការកែលម្អលទ្ធផលសិក្សាដែលតម្រូវឲ្យមានការពង្រឹងធាតុចូលក៏ដូចជាដំណើរការ និងការវាយតម្លៃលទ្ធផល រួមទាំងយន្តការដើម្បីវាស់វែងការរីកចំរើន។ យើងនឹងធានាថាគ្រូបង្រៀន និងអប់រំវិទូទាំងអស់ទទួលបានការពង្រឹងអំណាច ក៏ដូចជាការជ្រើសរើសឲ្យចូលបំរើការងារសមស្រប និងទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ មានសមត្ថភាពវិជ្ជាជីវៈប្រកបដោយការលើកទឹកចិត្ត និងការគាំទ្រក្រោមឱវាទប្រព័ន្ធគ្រប់គ្រងដែលមានធនធានគ្រប់គ្រាន់ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល។ ការអប់រំប្រកបដោយគុណភាពជំរុញឲ្យមានគំនិតច្នៃប្រឌិតនិងចំណេះដឹង និងធានាឲ្យមានជំនាញមូលដ្ឋាននៃអក្ខរកម្ម និងលេខនព្វន្ធ ព្រមទាំងជំនាញវិភាគ ជំនាញដោះស្រាយបញ្ហា និងជំនាញសង្គមក៏ដូចជាជំនាញទំនាក់ទំនងផ្សេងទៀត។ ការអប់រំប្រកបដោយគុណភាពក៏អភិវឌ្ឍន៍ជំនាញ គុណតម្លៃ និងឥរិយាបទដែលបណ្តាលឲ្យពលរដ្ឋមានសុខភាពល្អ និងមានជីវិតប្រកបដោយភាពពេញលេញ ធ្វើឱ្យពួកគេមានការសម្រេចចិត្តប្រកបដោយពត៌មានត្រឹមត្រូវហើយនឹងអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងតំបន់ និងពិភពលោកតាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD) និងការអប់រំពលរដ្ឋសកល (GCED)។ ក្នុងន័យនេះ យើងបានគាំទ្រយ៉ាងខ្លាំងចំពោះការអនុវត្តកម្មវិធីសកម្មភាពជាសកលលើ ESD ដែលបានសម្ពោធនៅសន្និសីទពិភពលោករបស់អង្គការយូណេស្កូស្តីពី ESD ក្នុងទីក្រុងណាហ្គូយ៉ា នាឆ្នាំ២០១៤។ យើងក៏បានបញ្ជាក់អំពីសារៈសំខាន់នៃការអប់រំ និងបណ្តុះបណ្តាលលើសិទ្ធិមនុស្ស ក្នុងគោលបំណងដើម្បីសម្រេចបាននូវរបៀបវារៈនៃការអភិវឌ្ឍដោយចីរភាពក្រោយឆ្នាំ២០១៥។

១០. យើងបានប្តេជ្ញាដើម្បីលើកកម្ពស់**ឱកាសរៀនសូត្រពេញមួយជីវិត** ដែលមានគុណភាពសម្រាប់ទាំងអស់គ្នានៅគ្រប់បរិបទ និងតាមកម្រិតទាំងអស់នៃការអប់រំ។ នេះរួមបញ្ចូលទាំងសមធម៌ និងការបង្កើនឱកាសទទួលបាននូវបច្ចេកទេស និងការអប់រំការបណ្តុះបណ្តាល ការអប់រំនៅឧត្តមសិក្សា និងការស្រាវជ្រាវប្រកបដោយគុណភាពជាមួយនឹងការយកចិត្តទុកដាក់ទៅលើការធានាគុណភាព។ លើសពីនេះទៀត ការផ្តល់យន្តការសម្រាប់ការសិក្សារៀនសូត្រដែលមានភាពបត់បែនបានព្រមទាំងការទទួលស្គាល់សុពលភាព និងវិញ្ញាបនបត្រនៃចំណេះដឹង ជំនាញ និងសមត្ថភាពដែលទទួលបានតាមរយៈការអប់រំក្រៅប្រព័ន្ធ និងមិនផ្លូវការក៏មានសារៈសំខាន់ដែរ។ យើងបានប្តេជ្ញាបន្ថែមទៀតដើម្បីធានាថាយុវជន និងមនុស្សពេញវ័យជាពិសេសក្មេងស្រី និងស្ត្រីទាំងអស់សម្រេចបានកម្រិតជំនាញអក្ខរកម្មវិជ្ជាជីវៈ និងជំនាញគិតលេខដែលមានការទទួលស្គាល់ រួមទាំងការទទួលបាននូវបំណិនជីវិត ហើយពួកគេត្រូវទទួលបាននូវឱកាសរៀនសូត្រ និងការបណ្តុះបណ្តាលតាមបែបមនុស្ស

ពេញវ័យ។ យើងក៏មានការប្តេជ្ញាក្នុងការពង្រឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគំនិតច្នៃប្រឌិត។ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICTs) ជាកត្តាចាំបាច់ដែលត្រូវបានរៀបចំដើម្បីពង្រឹងប្រព័ន្ធអប់រំ ការផ្សព្វផ្សាយចំនេះដឹង សិទ្ធិទទួលបានព័ត៌មាន និងការសិក្សាដែលមានគុណភាព និងប្រសិទ្ធិភាព ព្រមទាំងការផ្តល់សេវាដែលមានប្រសិទ្ធិភាពបន្ថែមទៀត។

១១. លើសពីនេះទៀត យើងបានកត់សម្គាល់ដោយក្តីបារម្ភយ៉ាងខ្លាំងថា នាពេលបច្ចុប្បន្ននេះ ចំនួនសិស្សក្រៅសាលាមួយភាគធំរបស់ពិភពលោកកំពុងរស់នៅក្នុងតំបន់មួយចំនួនដែលទទួលរងគ្រោះដោយសារជម្លោះហើយវិបត្តិអំពើហឹង្សា និងការវាយប្រហារទៅលើស្ថាប័នអប់រំ ក៏ដូចជាគ្រោះមហន្តរាយធម្មជាតិ និងជំងឺឆ្លងកាចសាហាវ នៅតែបន្តធ្វើឱ្យរំខានដល់ការសិក្សាអប់រំ និងការអភិវឌ្ឍនៅទូទាំងពិភពលោក។ យើងបានប្តេជ្ញាក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំបែបបរិយាប័ន្ន និងបែបឆ្លើយតបនឹងតម្រូវការ ដើម្បីបំពេញតាមតម្រូវការរបស់កុមារ យុវជន និងមនុស្សពេញវ័យនៅក្នុងបរិបទទាំងនេះរាប់ទាំងទីកន្លែងរបស់អ្នកដែលបានផ្លាស់ប្តូរទីតាំងរស់នៅ និងជនភៀសខ្លួន។ យើងបានគូសបញ្ជាក់ពីតម្រូវការសម្រាប់ការអប់រំដែលត្រូវបានផ្តល់ជូនប្រកបដោយបរិយាកាសសិក្សាមានសុវត្ថិភាព មានការគាំទ្រ និងមានសន្តិសុខដែលមិនមានអំពើហឹង្សា។ យើងសូមផ្តល់អនុសាសន៍ឲ្យមានការឆ្លើយតបនឹងវិបត្តិប្រកបដោយភាពសមស្របតាមរយៈការឆ្លើយតបបន្ទាន់ដោយការស្តារ និងការកសាងឡើងវិញក៏ដូចជាការសម្របសម្រួលឲ្យល្អប្រសើរជាងមុននៅថ្នាក់ជាតិ ថ្នាក់តំបន់និងថ្នាក់សកល។ អនុសាសន៍នេះគិតទាំងពីការអភិវឌ្ឍសមត្ថភាពសម្រាប់ការកាត់បន្ថយហានិភ័យ និងការកាត់បន្ថយផលប៉ះពាល់ដើម្បីធានាឱ្យបានការអប់រំមួយដែលត្រូវបានរក្សាឲ្យមានដំណើរការទោះក្នុងអំឡុងពេលនៃស្ថានការណ៍ជម្លោះ សង្គ្រោះបន្ទាន់ក្រោយជម្លោះ និងការងើបឡើងវិញពីជម្លោះក៏ដោយ។

## ការអនុវត្តរបៀបវារៈរួមរបស់យើង

១២. យើងបញ្ជាក់ជាថ្មីថា ការទទួលខុសត្រូវជាមូលដ្ឋានសម្រាប់ការអនុវត្តរបៀបវារៈដ៏ជោគជ័យនេះ ត្រូវពឹងផ្អែកលើរដ្ឋាភិបាល។ យើងត្រៀមខ្លួនដើម្បីបង្កើតក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយ ដែលលើកកម្ពស់ការទទួលខុសត្រូវ និងតម្លាភាពព្រមទាំងអភិបាលកិច្ច និងភាពជាដៃគូនៅគ្រប់កម្រិត និងគ្រប់វិស័យ និងដើម្បីលើកកម្ពស់សិទ្ធិនៃការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

១៣. យើងសូមអំពាវនាវឱ្យមានកិច្ចសហការ កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការត្រួតពិនិត្យជាសកល និងថ្នាក់តំបន់យ៉ាងខ្លាំងលើការអនុវត្តរបៀបវារៈវិស័យអប់រំដោយផ្អែកលើការប្រមូលទិន្នន័យ ការវិភាគ និងការរាយការណ៍នៅក្នុងកម្រិតប្រទេសដែលឋិតក្នុងក្របខ័ណ្ឌនៃអង្គភាព យន្តការ និងយុទ្ធសាស្ត្រថ្នាក់តំបន់នេះ។

១៤. យើងទទួលស្គាល់ថាភាពជោគជ័យនៃរបៀបវារៈវិស័យអប់រំឆ្នាំ ២០៣០នេះ តម្រូវឱ្យមានគោលនយោបាយ និងការធ្វើផែនការជាក់លាក់ព្រមទាំងមានការរៀបចំការអនុវត្តមានប្រសិទ្ធិភាព។ ជាភាពច្បាស់ណាស់ថា សេចក្តីប៉ងប្រាថ្នាដែលបានដាក់ចូលក្នុងគោលដៅអភិវឌ្ឍដោយចីរភាព មិនអាចត្រូវបានសម្រេចដោយគ្មានការបង្កើនខ្ទង់ហិរញ្ញប្បទានដែលត្រូវតាមការកំណត់គោលដៅជាក់លាក់នោះទេ ជាពិសេសនៅតាមបណ្តាប្រទេសទាំងឡាយដែលមិនទាន់សម្រេចបាននូវការអប់រំប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នានៅគ្រប់កម្រិត។ ហេតុនេះហើយបានជាយើងបានតាំងចិត្តបង្កើនការចំណាយសាធារណៈ លើវិស័យអប់រំឲ្យស្របតាមបរិបទប្រទេស

និងបានជម្រុញឲ្យមានការប្រកាន់ខ្ជាប់ទៅនឹងគោលនយោបាយថ្នាក់តំបន់ និងអន្តរជាតិលើការបែងចែកយ៉ាងមានប្រសិទ្ធិភាពគឺយ៉ាងហោចណាស់ ៤- ៦% នៃផលិតផលក្នុងស្រុកសរុប និង / ឬយ៉ាងហោចណាស់១៥ - ២០% នៃការចំណាយសាធារណៈសរុបលើវិស័យអប់រំ។

១៥. ដោយកត់សម្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍ ក្នុងការវិនិយោគបំពេញបន្ថែមដោយរដ្ឋាភិបាល។ យើងបានអំពាវនាវដល់បណ្តាប្រទេសអភិវឌ្ឍន៍ ក៏ដូចជាម្ចាស់ជំនួយទាំងថ្មី និងចាស់រួមទាំងប្រទេសកំពុងរីកចម្រើនដែលមានប្រាក់ចំណូលមធ្យម និងយន្តការអន្តរជាតិឲ្យចូលរួមក្នុងការបង្កើនមូលនិធិហិរញ្ញប្បទានលើវិស័យអប់រំ និងដើម្បីគាំទ្រដល់ការអនុវត្តរបៀបវារៈដោយយោងទៅតាមតម្រូវការ និងអាទិភាពរបស់ប្រទេសទាំងឡាយ។ យើងទទួលស្គាល់ថាការបំពេញនូវការប្តេជ្ញាចិត្តទាំងអស់ដែលទាក់ទងទៅនឹងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ជាការសំខាន់ណាស់ រួមទាំងការប្តេជ្ញាចិត្តនានារបស់ប្រទេសអភិវឌ្ឍន៍ជាច្រើន ដើម្បីសម្រេចបាននូវគោលដៅចំនួន ០,៧ ភាគរយនៃផលិតផលជាតិសរុប (GNP) សម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងការអនុលោមជាមួយនឹងការប្តេជ្ញាចិត្តរបស់ពួកគេ យើងជម្រុញឱ្យបណ្តាប្រទេសអភិវឌ្ឍដែលពុំទាន់បានធ្វើនៅឡើយ សូមអនុវត្តឱ្យកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតឆ្ពោះទៅរកគោលដៅចំនួនពី ០,៧ភាគរយនៃផលទុនជាតិសរុបសម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ចំពោះការអភិវឌ្ឍប្រទេស។ យើងប្តេជ្ញាបង្កើនការគាំទ្ររបស់យើងដល់បណ្តាប្រទេសអភិវឌ្ឍន៍តិចជាងគេ។ យើងទទួលស្គាល់ពីសារៈសំខាន់នៃការដាក់ធនធានមានសក្តានុពលទាំងអស់ដើម្បីគាំទ្រ ដល់សិទ្ធិទទួលបានការអប់រំផងដែរ។ យើងសូមផ្តល់អនុសាសន៍ឲ្យកែសម្រួលការប្រើប្រាស់ជំនួយប្រកបដោយប្រសិទ្ធភាព តាមរយៈការសម្របសម្រួលកាន់តែប្រសើរ និងប្រកបដោយសុខដុមនីយកម្ម និងការផ្តល់ហិរញ្ញប្បទាន និងជំនួយជាអាទិភាពដល់អនុវិស័យដែលមិនសូវទទួលបានការយកចិត្តទុកដាក់ និងនៅតាមបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប។ យើងក៏ផ្តល់អនុសាសន៍ឱ្យបង្កើននូវការគាំទ្រយ៉ាងខ្លាំងសម្រាប់ការអប់រំជាលក្ខណៈមនុស្សធម៌ និងវិបត្តិអូសបន្លាយ។ យើងក៏សូមស្វាគមន៍ផងដែរចំពោះកិច្ចប្រជុំកំពូលទីក្រុងអូស្លូ (Oslo)ស្តីពីការអប់រំដើម្បីការអភិវឌ្ឍ (ខែកក្កដាឆ្នាំ ២០១៥) និងអំពាវនាវការចំណាយសម្រាប់សន្និសីទការអភិវឌ្ឍនៅទីក្រុង Addis Ababa ដើម្បីគាំទ្រដល់គោលដៅអភិវឌ្ឍដោយចីរភាពទី៤ ។

១៦. យើងសូមអំពាវនាវឱ្យវេទិកាអប់រំពិភពលោកឆ្នាំ ២០១៥ និងជាពិសេសអង្គការយូណេស្កូ ក៏ដូចជាដៃគូទាំងអស់ ទោះជាលក្ខណៈបុគ្គល និងជាសមូលហភាពក្តី សូមគាំទ្រដល់បណ្តាប្រទេសក្នុងការអនុវត្តរបៀបវារៈអប់រំឆ្នាំ ២០៣០ ដោយផ្តល់នូវដំបូន្មានបច្ចេកទេស ការអភិវឌ្ឍសមត្ថភាពថ្នាក់ជាតិ និងការគាំទ្រផ្នែកហិរញ្ញវត្ថុដែលមានមូលដ្ឋានលើអាណត្តិរបស់ខ្លួន និងឧត្តមភាពដែលមានការប្រៀបធៀប និងការជួយបំពេញឲ្យគ្នាទៅវិញទៅមក។ ចុងក្រោយនេះ យើងផ្តល់ការជឿទុកចិត្តអង្គការយូណេស្កូ ឲ្យបង្កើតយន្តការសម្របសម្រួលថ្នាក់សកលមួយសម្រាប់ពិគ្រោះយោបល់ជាមួយរដ្ឋជាសមាជិក អ្នករៀបចំវេទិកាអប់រំពិភពលោកឆ្នាំ ២០១៥ និងដៃគូដ៏ទៃទៀត។ ការទទួលស្គាល់ចំពោះដៃគូជាសកលសម្រាប់វិស័យអប់រំ(GPE) គឺជាយន្តការហិរញ្ញប្បទានពហុភាគីសម្រាប់ការអប់រំដើម្បីគាំទ្រដល់ការអនុវត្តដែលយោងតាមសេចក្តីត្រូវការ និងអាទិភាពរបស់ប្រទេសនានាដែលយើងបានផ្តល់អនុសាសន៍ថាវាជាផ្នែកមួយនៃយន្តការសម្របសម្រួលជាសកលនាពេលអនាគតនេះ។

១៧. យើងទុកចិត្តបន្ថែមទៀតលើអង្គការយូណេស្កូ ដែលជាទីភ្នាក់ងារជំនាញ របស់អង្គការសហប្រជាជាតិសម្រាប់វិស័យអប់រំឱ្យបន្តអាណត្តិរបស់ខ្លួនដើម្បីមានតួនាទីដឹកនាំ និងសម្របសម្រួលរបៀបវារៈវិស័យអប់រំឆ្នាំ២០៣០ ជាពិសេសដោយៈ អនុវត្តការតស៊ូមតិដើម្បីឲ្យមានការប្តេជ្ញាចិត្តថ្នាក់នយោបាយ ការសម្របសម្រួលកិច្ចសន្ទនាគោលនយោបាយ ការចែករំលែកចំណេះដឹង និងការកំណត់ស្តង់ដារ ពិនិត្យតាមដានការរីកចម្រើនឆ្ពោះទៅរកគោលដៅអប់រំរៀបចំជំនួបអ្នកពាក់ព័ន្ធថ្នាក់ពិភពលោក ថ្នាក់តំបន់ និងថ្នាក់ជាតិដើម្បីណែនាំការអនុវត្តរបៀបវារៈ ហើយដំណើរការជាមួយជនបង្គោលសម្រាប់ការអប់រំនៅក្នុងក្របខ័ណ្ឌការសម្របសម្រួល SDG ទាំងមូល។

១៨. យើងតាំងចិត្តដោះស្រាយការអភិវឌ្ឍប្រព័ន្ធតាមដាន និងវាយតម្លៃថ្នាក់ជាតិក្នុងគោលបំណងដើម្បីបង្កើតភ័ស្តុតាងជាក់លាក់សម្រាប់ការបង្កើតគោលនយោបាយ និងការគ្រប់គ្រងប្រព័ន្ធអប់រំដើម្បីធានាឱ្យមានទំនួលខុសត្រូវខ្ពស់។ យើងបានស្នើសុំបន្ថែមទៀតដល់អ្នករៀបចំវេទិកាអប់រំពិភពលោកឆ្នាំ២០១៥ និងដៃគូដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពនៅក្នុងការប្រមូលទិន្នន័យ ការវិភាគ និងការធ្វើរបាយការណ៍ថ្នាក់ជាតិ។ បណ្តាប្រទេសទាំងឡាយគួរស្វែងរកការកែលម្អគុណភាពកម្រិតនៃបំណែងចែក និងការរាយការណ៍ឲ្យទាន់ពេលវេលាដល់ស្ថាប័ន យូណេស្កូទទួលបន្ទុកស្ថិតិ។ យើងក៏បានស្នើផងដែរថា របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា គួរបន្តតួនាទីជារបាយការណ៍ពិនិត្យតាមដានវិស័យអប់រំជាសកលដ៏ឯករាជ្យមួយ (GEMR) ដែលត្រូវបានរៀបចំ និងបោះពុម្ពដោយអង្គការយូណេស្កូ ដែលជាយន្តការសម្រាប់ការតាមដាន និងការរាយការណ៍គោលដៅអភិវឌ្ឍដោយចីរភាពទី៤ លើវិស័យអប់រំមួយ ក្នុងចំណោមយន្តការដ៏ទៃទៀតដែលត្រូវបានបង្កើតឡើងក្នុងការតាមដាន និងពិនិត្យមើលលើការអនុវត្តគោលដៅអភិឌ្ឍន៍ដោយចីរភាពនានាដែលបានស្នើឡើង។

១៩. យើងបានពិភាក្សា និងបានឯកភាពលើធាតុសំខាន់ៗនៃក្របខ័ណ្ឌសម្រាប់សកម្មភាពលើវិស័យអប់រំឆ្នាំ ២០៣០។ យោងលើស្មារតីនៃកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិ សម្រាប់ការអនុម័តរបៀបវារៈអភិវឌ្ឍក្រោយឆ្នាំ ២០១៥ (ទីក្រុងញូវយ៉ក ខែកញ្ញាឆ្នាំ ២០១៥) និងលទ្ធផលនៃសន្និសីទអន្តរជាតិលើកទីបីស្តីពីការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ (ទីក្រុង Addis Ababa ខែកក្កដា ឆ្នាំ ២០១៥) សម្រេចចុងក្រោយនឹងត្រូវបានបង្ហាញសម្រាប់ការអនុម័ត និងដាក់ឲ្យដំណើរការនៅក្នុងកិច្ចប្រជុំជាន់ខ្ពស់ពិសេសមួយដែលត្រូវបានរៀបចំរួមជាមួយសម័យប្រជុំទី៣៨នៃអង្គការយូណេស្កូ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៥។ យើងមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តលើក្របខ័ណ្ឌសម្រាប់សកម្មភាពលើវិស័យអប់រំឆ្នាំ ២០៣០ បន្ទាប់ពីការអនុម័តរបស់ខ្លួនក្នុងការជម្រុញ និងណែនាំបណ្តាប្រទេស និងដៃគូនានាដើម្បីធានាថារបៀបវារៈរបស់យើងត្រូវបានសម្រេចដោយជោគជ័យ។

២០. តាមរយៈការបន្តសកម្មភាពបន្ថែមលើកេរដំណែលដែលបានចាប់ផ្តើមឡើងនៅទីក្រុង Jomtien និង Dakar, សេចក្តីប្រកាសទីក្រុងអ៊ីនឈុននេះគឺជាការប្តេជ្ញាចិត្តជាប្រវត្តិសាស្ត្រមួយដោយយើងទាំងអស់គ្នា ដើម្បីផ្លាស់ប្តូរជីវិតឲ្យប្រសើរឡើងតាមរយៈចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំ ជាមួយនឹងសកម្មភាពប្រកបដោយភាពច្នៃប្រឌិត និងភាពជឿ ជាក់ដើម្បីឈានទៅដល់ការសម្រេចគោលដៅប្រកបដោយមហិច្ឆិតារបស់យើងត្រឹមឆ្នាំ ២០៣០។

ទីក្រុងអ៊ីនឈុន សាធារណៈរដ្ឋកូរ៉េ
ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៥

# សេចក្តីថ្លែងការណ៍របស់ប្រធានទីភ្នាក់ងារចាត់ចែងវេទិកាអប់រំពិភពលោក ២០១៥

*សេចក្តីប្រកាសនេះ គឺជាជំហានឆ្ពោះទៅមុខមួយដ៏ធំ។ វាឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងដើម្បីធានាថាកុមារ ទាំងអស់ មនុស្សវ័យក្មេង និងមនុស្សពេញវ័យទទួលបានចំណេះដឹង និងជំនាញដែលពួកគេត្រូវការ ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ បំពេញសក្តានុពលរបស់ខ្លួន និងចូលរួមចំណែកដល់សង្គមរបស់ពួកគេក្នុងនាមជាពលរដ្ឋសកលដែលមានការទទួលខុសត្រូវ។ សេចក្តីប្រកាសនេះលើកទឹកចិត្តឲ្យរដ្ឋាភិបាលក្នុងការផ្តល់ឱកាសរៀនសូត្រពេញមួយជីវិត ដូច្នេះមនុស្សអាចបន្តការរីកចំរើន និងមានការផ្លាស់ប្តូរវិជ្ជមានបាន។ សេចក្តីប្រកាសនេះបានបញ្ជាក់ថាវិស័យអប់រំ ដែលជាសិទ្ធិមូលដ្ឋានរបស់មនុស្ស គឺជាគន្លឹះសំខាន់ដល់សន្តិភាពពិភពលោក និងការអភិវឌ្ឍប្រកបដោយចីរភាព។*

Irina Bokova

Director-General of UNESCO

---

*ការអប់រំគឺជាគន្លឹះដែលធ្វើឲ្យជីវិតល្អប្រសើរសម្រាប់កុមារគ្រប់រូប និងជាមូលដ្ឋានគ្រឹះរបស់សង្គមដែលមានភាពរឹងមាំ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែមានកុមារដែលគេទុកចោលហើយមិនបានទទួលការយកចិត្តទុកដាក់។ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ទាំងអស់របស់យើង យើងត្រូវការឲ្យកុមារទាំងអស់នៅក្នុងសាលារៀន និងទទួលបានការរៀនសូត្រ។*

Anthony Lake

Executive Director, UNICEF

---

*ដើម្បីលុបបំបាត់ភាពក្រីក្រ បង្កើនវិបុលភាពរួម និងសម្រេចបានគោលដៅអភិវឌ្ឍន៍ដោយចីរភាព យើងត្រូវតែផ្តល់ហិរញ្ញវត្ថុដល់ការអភិវឌ្ឍ និងជំនាញបច្ចេកទេសដើម្បីការផ្លាស់ប្តូរពិត។ យើងត្រូវតែធ្វើការរួមគ្នា ដើម្បីធានាថាកុមារទាំងអស់មានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងការសិក្សាពេលមួយជីវិតរបស់ពួកគេដោយមិនគិតពីកន្លែងដែលពួកគេបានចាប់កំណើត យេនឌ័ររបស់ពួកគេ ឬ ប្រាក់ចំណូលគ្រួសាររបស់ពួកគេ។*

Jim Yong Kim

President of the World Bank Group

---

*យើងត្រូវតែរួមគ្នាលើកកម្ពស់ និងការពារសិទ្ធិរបស់មនុស្សទាំងអស់ក្នុងការទទួលការអប់រំ និងធានាថាពួកគេទទួលបានការអប់រំ ដែលមានគុណភាព ហើយឲ្យពួកគេទទួលបានតម្លៃនៃសន្តិភាព យុត្តិធម៌ សិទ្ធិមនុស្ស និងសមភាពយេនឌ័រ។ យើងមានមោទនភាពដែលបានចូលរួមចាត់ចែងវេទិកាអប់រំពិភពលោក និងបានសន្យាថានឹងចូលរួមធ្វើឲ្យរបៀបវារៈសកម្មភាពថ្មីលើវិស័យអប់រំសម្រាប់ទាំងអស់គ្នាទទួលជោគជ័យត្រឹមឆ្នាំ ២០៣០។*

Babatunde Osotimehin

UNFPA Executive Director

---

ix

*នៅក្នុងពិភពលោករបស់យើង ចំណេះដឹងគឺជាអំណាច ហើយការអប់រំផ្តល់សិទ្ធិអំណាច។ វាគឺជាផ្នែកមួយមិនអាចខ្វះបាននៃរូបមន្តអភិវឌ្ឍន៍។ វាមានតម្លៃចាំបាច់បែបធម្មជាតិដែលមានន័យហួសពីសេដ្ឋកិច្ចដើម្បីផ្តល់អំណាចដល់ប្រជាជនក្នុងការកំណត់ជោគវាសនារបស់ខ្លួនផ្ទាល់។ នោះហើយជាមូលហេតុថា ឱកាសដើម្បីទទួលការអប់រំគឺជាន័យចម្បងដើម្បីពន្លឿនការអភិវឌ្ឍធនធានមនុស្ស ។*

Helen Clark

UNDP Administrator

*សេចក្តីប្រកាសទីក្រុងអ៊ីនឈុន ពិតជាជម្រុញឲ្យយើងប្តេជ្ញាចិត្តផ្តល់ការអប់រំដោយមិនមានការរើស អើង ដែលទទួលស្គាល់ពីសារៈសំខាន់នៃសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការអភិវឌ្ឍដោយចីរភាព។ នេះជាឱកាសសំខាន់ណាស់ សម្រាប់ពួកយើងក្នុងការធ្វើការរួមគ្នាតាមគ្រប់វិស័យ ឆ្ពោះទៅរកការបំពេញពាក្យសន្យាចំពោះការផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នាជូនដល់សង្គមដែលមានសន្តិភាព យុត្តិធម៌ និងភាពស្មើគ្នា។ យើងអាចទទួលបានពិភពលោកមួយដែលមនុស្សមានសិទ្ធិស្មើគ្នាប្រសិនបើការអប់រំរបស់យើង បង្រៀនដល់ពួកគេក្នុងលក្ខណៈសកលដែរ។*

Phumzile Mlambo-Ngcuka

UN Women Executive Director and

UN Under-Secretary-General

*យើងមានការទទួលខុសត្រូវរួមមួយ ដើម្បីធានាឱ្យផែនការអប់រំគិតដល់តម្រូវការរបស់កុមារ និងយុវជនដែលងាយរងគ្រោះបំផុតនៅលើពិភពលោក ដូចជាជនភៀសខ្លួន កុមារផ្លាស់ទីលំនៅ កុមារដែលមិនបានទទួលស្គាល់ថាជាពលរដ្ឋរបស់ប្រទេសណាមួយ និងកុមារដែលមានសិទ្ធិទទួលបានការអប់រំតែវាត្រូវបានរំខានដោយសង្គ្រាម និងភាពអសន្តិសុខ។ កុមារទាំងនេះគឺជាគន្លឹះឆ្ពោះទៅរកអនាគតមួយប្រកបដោយសុវត្ថិភាព និងនិរន្តរភាព ហើយយើងទាំងអស់គ្នាត្រូវរកដំណោះស្រាយសម្រាប់ការអប់រំរបស់ពួកគេ។*

António Guterres

United Nations High Commissioner for Refugees

# វិស័យអប់រំឆ្នាំ ២០៣០

## ក្របខ័ណ្ឌសម្រាប់សកម្មភាព

ឆ្ពោះទៅរកការអប់រំមានគុណភាព
បែបបរិយាប័ន្ន សមធម៌ និង
ការសិក្សាពេញមួយជីវិត
សម្រាប់ទាំងអស់គ្នា

# មាតិកា


សេចក្តីផ្តើម ........ ៣

I. ចក្ខុវិស័យ បុព្វហេតុ និងគោលការណ៍ ........ ៤

II. គោលដៅ វិធីសាស្រ្តបែបយុទ្ធសាស្រ្ត ក្រុមគោលដៅ និងសូចនាករនានា ........ ៨

គោលដៅរួម ........ ៨

វិធីសាស្រ្តបែបយុទ្ធសាស្រ្តនានា ........ ៩

ក្រុមគោលដៅ និងយុទ្ធសាស្រ្តដែលចង្អុលបង្ហាញផ្សេងៗ ........ ១៤

សូចនាករនានា ........ ៣៣

III. បែបបទនៃការអនុវត្តផ្សេង ........ ៣៤

អភិបាលកិច្ច គណនេយ្យភាព និងភាពជាដៃគូ ........ ៣៥

ការសម្របសម្រួលមានប្រសិទ្ធិភាព ........ ៣៧

ការពិនិត្យ ការតាមដាន និងការពិនិត្យឡើងវិញសម្រាប់គោលនយោបាយ ផ្អែកលើភស្តុតាង ........ ៤១

ការផ្តល់ហិរញ្ញប្បទាន ........ ៤៣

សេចក្តីសន្និដ្ឋាន ........ ៤៨

ឧបសម្ព័ន្ធ ១ សូចនាករថ្នាក់សកល ........ ៤៩

ឧបសម្ព័ន្ធ ២ ក្របខ័ណ្ឌសូចនាករដែលបានស្នើឡើង (សេចក្តីព្រាង) ........ ៥០

# សេចក្តីផ្តើម

១. ពិភពលោកមានការរីកចម្រើនគួរឱ្យកត់សម្គាល់មួយចំនួន នៅក្នុងវិស័យអប់រំតាំងពីឆ្នាំ ២០០០ មក។ នៅពេលដែលគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា (EFA) ទាំងប្រាំមួយ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ (MDGs) ត្រូវបានបង្កើតឡើង ប៉ុន្តែគោលដៅទាំងនោះមិនត្រូវបានគេធ្វើបានសម្រេចក្នុងពេលកំណត់នៅឆ្នាំ២០១៥ និងសកម្មភាពបន្តទៀត ត្រូវការជាចាំបាច់ដើម្បីបំពេញរបៀបវារៈទាំងឡាយដែលមិនទាន់បានបញ្ចប់។ ជាមួយនឹងគោលដៅទី៤នៃ**ការធ្វើឲ្យពិភពលោករបស់យើងប្រសើរឡើង៖ របៀបវារៈឆ្នាំ ២០៣០ ដើម្បីការអភិវឌ្ឍដោយចីរភាព**[i]- ***"ធានាបាននូវគុណភាពអប់រំបែបបរិយាប័ន្ន សមភាព និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"*** (យោងតាម**វិស័យអប់រំឆ្នាំ ២០៣០**) និងគោលដៅដែលជាប់ទាក់ទងផ្សេងៗ។ ពិភពលោកទាំងមូល បានកំណត់របៀបវារៈអប់រំជាសកលមួយយ៉ាងមានមហិច្ឆតាសម្រាប់ឆ្នាំ ២០១៥ ដល់ ២០៣០។ ការខិតខំប្រឹងប្រែងទាំងឡាយ ត្រូវតែបានធ្វើឡើងដើម្បីធានាថា លើកនេះគោលដៅ និងអ្វីដែលបានកំណត់ នឹងត្រូវសម្រេចបាន។

២. វិស័យអប់រំឆ្នាំ ២០៣០ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់យ៉ាងទូលំទូលាយ និងគ្រប់គ្រងដោយរដ្ឋជាសមាជិក សម្របសម្រួលដោយអង្គការយូណេស្កូ ព្រមទាំងដៃគូផ្សេងទៀត និងដឹកនាំដោយគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា(EFA)[1]។ វិស័យអប់រំឆ្នាំ២០៣០ បានធ្វើការសិក្សាទៅលើប្រធានបទនៃការពិគ្រោះយោបល់ស្តីពីការអប់រំក្រោយឆ្នាំ២០១៥ ដោយផ្អែកលើអ្វីដែលបានកើតឡើងក្នុងឆ្នាំ ២០១២ និង២០១៣ ដែលដឹកនាំដោយអង្គការយូណេស្កូ និងអង្គការយូនីសេហ្វ ហើយកិច្ចប្រជុំលើការអប់រំជាសកលសម្រាប់ទាំងអស់គ្នា បានប្រារព្ធឡើងនៅទីក្រុង Muscat នៃប្រទេសOman ក្នុងខែ ឧសភា ឆ្នាំ ២០១៤ ដែលជាការពិគ្រោះយោបល់ជាមួយអង្គការក្រៅរដ្ឋាភិបាល។ សន្និសីទរដ្ឋមន្ត្រីកម្រិតតំបន់ចំនួន៥ បានរៀបចំដោយអង្គការយូណេស្កូ នៅឆ្នាំ ២០១៤ និង២០១៥ ហើយកិច្ចប្រជុំE-9 បានប្រារព្ធឡើងក្នុងទីក្រុងអ៊ីស្លាម៉ាបាត ក្នុងឆ្នាំ ២០១៤។[2] ព្រឹត្តិការណ៍សំខាន់នៅក្នុងការអភិវឌ្ឍនេះគឺជាកិច្ចព្រមព្រៀងទីក្រុង Muscat[ii] ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំការអប់រំសម្រាប់ទាំងអស់គ្នាជាសកលលោក នៅក្នុងខែឧសភា ឆ្នាំ២០១៤ ហើយដែលបានបង្ហាញពីគោលដៅអប់រំជាសកល និងចំណុចដៅដែលជាប់ទាក់ទងគ្នា ព្រមទាំងមធ្យោបាយនៃការអនុវត្តតាមសេចក្តីស្នើសុំពីក្រុមការងារបើកចំហនៃមហាសន្និបាតអង្គការសហប្រជាជាតិ សម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាព (OWG)។ ដំណើរការនេះបានបញ្ចប់ក្នុង **សេចក្តីប្រកាសទីក្រុងអ៊ីនឈុន (Incheon)** ដែលត្រូវបានអនុម័តនៅថ្ងៃទី២១ ខែឧសភាឆ្នាំ២០១៥ នៅឯវេទិកាអប់រំពិភពលោក បានប្រារព្ធឡើងនៅទីក្រុង Incheon ប្រទេសកូរ៉េខាងត្បូង។ សេចក្តីប្រកាសទីក្រុងអ៊ីនឈុនបង្កើតការប្តេជ្ញាចិត្តយ៉ាងខ្ពស់របស់សហគមន៍អប់រំដើម្បីការអប់រំ និងរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាពបានទទួលស្គាល់តួនាទីសំខាន់នៃ

1 គណៈកម្មាធិការដឹកនាំការអប់រំសម្រាប់ទាំងអស់គ្នា បង្ហាញថាការរៀបចំដោយអង្គការ UNESCO ត្រូវបានផ្សំឡើងដោយរដ្ឋជាសមាជិកតំណាងឱ្យក្រុមនានាក្នុងតំបន់ទាំងអស់ប្រាំមួយនៃអង្គការUNESCO ដែលជាអ្នកគំនិតផ្តួចផ្តើម E- 9* និងប្រទេសជាម្ចាស់ផ្ទះ នៃវេទិកាអប់រំពិភពលោកឆ្នាំ ២០១៥ ទីភ្នាក់ងារ EFA ទី៥ (មានអង្គការ UNESCO, UNICEF, UNDP, UNFPA និងWHO)។ អង្គការអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) សង្គមស៊ីវិល វិជ្ជាជីវៈបង្រៀន និងវិស័យឯកជន។

* ការផ្តួចផ្តើម E-9 គឺជាវេទិកា ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៣ ដើម្បីពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកការសំរេចបាននូវ EFA នេះ។ វាមានប្រទេសចំនួន ៩ដែលមានប្រជាជនច្រើនជាងគេបំផុតនៃភាគខាងត្បូង (បង់ក្លាដែស ប្រេស៊ីល ចិន អេស៊ីប ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ិកស៊ិក នីហ្សេរីយ៉ា និង ប៉ាគីស្ថាន)។

2 លទ្ធផលនៃសន្និសីទរដ្ឋមន្ត្រីក្នុងតំបន់ លើវិស័យអប់រំនៅក្រោយឆ្នាំ ២០១៥ និងកិច្ចប្រជុំ E-9 នេះ គឺជាសេចក្តីប្រកាសទីក្រុងបាងកក (២០១៤) សេចក្តីប្រកាសលីម៉ា (២០១៤ ) សេចក្តីប្រកាសទីក្រុង អ៊ីស្លាម៉ាបាត (២០១៤) សេចក្តីប្រកាសទីក្រុងគីហ្គាលី (២០១៤) សេចក្តីថ្លែងការណ៍ Sharm El Sheikh (២០១៥) និង សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស (២០១៥)។

ការអប់រំដែលជាវិស័យស្នូលនៃការអភិវឌ្ឍ។ **ក្របខ័ណ្ឌសកម្មភាពសម្រាប់ការអប់រំឆ្នាំ២០៣០** បានផ្តល់នូវការណែនាំសម្រាប់ការអនុវត្តការអប់រំឆ្នាំ២០៣០ ត្រូវបានពិភាក្សានៅក្នុងវេទិកាអប់រំទាំងអស់គ្នា ឆ្នាំ២០១៥ និងជាតុសំខាន់ត្រូវបានព្រមព្រៀងគ្នានៅក្នុងសេចក្តីប្រកាសទីក្រុងអ៊ីនឈុន។ ក្របខ័ណ្ឌសម្រាប់សកម្មភាពនេះបង្ហាញពីរបៀបអនុវត្តនៅកម្រិតឬថ្នាក់ប្រទេស/ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ជាសកល[3] ដែលការប្តេជ្ញាចិត្តទាំងអស់នេះ បានធ្វើឡើងនៅទីក្រុងអ៊ីនឈុន។ មានគោលបំណងក្នុងការបំផុសចលនាប្រទេសទាំងអស់ និងដៃគូនៅជុំវិញគោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDG) លើវិស័យអប់រំ និងគោលដៅរបស់ខ្លួន ហើយបានស្នើវិធីនៃការអនុវត្ត សម្របសម្រួល ផ្តល់ហិរញ្ញប្បទាន និងត្រួតពិនិត្យដល់ការអប់រំសម្រាប់ឆ្នាំ២០៣០ ដើម្បីធានាដល់ការអប់រំដែលមានគុណភាពបែបបរិយាប័ន្ន សមភាព និងឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់។ អ្វីៗទាំងនេះក៏បានស្នើឡើងនូវការវាស់វែងជាយុទ្ធសាស្ត្រដែលប្រទេសមួយចំនួន អាចមានបំណងដាក់បញ្ចូលក្នុងការរៀបចំផែនការ និងយុទ្ធសាស្ត្រទៅតាមបរិបទរបស់ខ្លួន យកចិត្តទុកដាក់លើភាពខុសគ្នានៃតថភាពជាក់ស្តែងថ្នាក់ជាតិ សមត្ថភាព កម្រិតនៃការអភិវឌ្ឍ ការគោរពគោលនយោបាយជាតិ និងបញ្ហាអាទិភាពនានា។

៣. ក្របខ័ណ្ឌសម្រាប់សកម្មភាពនេះមានបីផ្នែក។ ផ្នែកទី១ បង្ហាញពីចក្ខុវិស័យ បុព្វហេតុ និងគោលការណ៍នៃវិស័យអប់រំសម្រាប់ឆ្នាំ ២០៣០។ ផ្នែកទី២ រៀបរាប់អំពីគោលដៅអប់រំជាសកល និងចំនុចដៅជាប់ទាក់ទងផ្សេងៗចំនួន៧ និង វិធី៣យ៉ាងនៃការអនុវត្ត ក៏ដូចជាយុទ្ធសាស្ត្រដែលចង្អុលបង្ហាញផងដែរ។ ផ្នែកទី៣ ស្នើនូវរចនាសម្ព័ន្ធមួយ សម្រាប់ការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងការអប់រំជាសកល ព្រមទាំងអភិបាលកិច្ចការត្រួតពិនិត្យតាមដាន និងយន្តការពិនិត្យឡើងវិញផ្សេងៗទៀត។ វាក៏ត្រួតពិនិត្យអំពីរបៀបនៃការធានាថាការអប់រំសម្រាប់ឆ្នាំ ២០៣០ ត្រូវបានផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់ និងបង្ហាញពីភាពជាដៃគូដែលត្រូវការដើម្បីសម្រេចបាននូវរបៀបវារៈនៅក្នុងកម្រិតប្រទេស/ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់ពិភពលោក។

# I. ចក្ខុវិស័យ បុព្វហេតុ និងគោលការណ៍

៤. វិស័យអប់រំគឺជាបេះដូងនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព និងមានសារៈសំខាន់សម្រាប់ភាពជោគជ័យនៃគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់។ ការទទួលស្គាល់តួនាទីយ៉ាងសំខាន់នៃរបៀបវារៈនៃវិស័យអប់រំឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព បានគូសបញ្ជាក់ថាការអប់រំជាគោលដៅឯករាជ្យមួយ (SDG4) និងរួមបញ្ចូលទាំងចំណុចដៅលើវិស័យអប់រំស្ថិតនៅក្រោមគោលដៅផ្សេងទៀតជាច្រើន ជាពិសេសផ្តោតទៅលើផ្នែកសុខភាព កំណើននិងការផ្តល់ការងារ ការប្រើប្រាស់និងផលិតភាពដោយនិរន្តរភាព និងការប្រែប្រួលអាកាសធាតុ។ ជាការពិត វិស័យអប់រំអាចពន្លឿនការរីកចម្រើនឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់ដូច្នេះវាគួរតែស្ថិតនៅផ្នែកមួយនៃយុទ្ធសាស្ត្រទាំងឡាយដើម្បីសម្រេច

3 វាត្រូវបានទទួលស្គាល់ថា នៅក្នុងប្រព័ន្ធសហព័ន្ធការទទួលខុសត្រូវរបស់រដ្ឋាភិបាល ជាញឹកញាប់តែងតែស្ថិតនៅថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ការទទួលខុសត្រូវបែបវិមជ្ឈការ សម្រាប់អភិបាលកិច្ចវិស័យអប់រំ និងការផ្តល់ គឺជាការអនុវត្តជាទូទៅនៅក្នុងប្រទេសជាច្រើន ដែលមិនមានប្រព័ន្ធសហព័ន្ធ។ ជាកន្លែងដែលអាចធ្វើទៅបាន លក្ខខណ្ឌដែលសមស្រប ត្រូវបានប្រើដើម្បីឆ្លុះបញ្ចាំង ប៉ុន្តែនៅក្នុងករណីខ្លះ "ថ្នាក់ជាតិ" ត្រូវបានប្រើដើម្បីសំដៅលើប្រទេសដែល មានទាំងប្រព័ន្ធរដ្ឋាភិបាលកណ្តាល ឬវិមជ្ឈការ។

បាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងអស់នោះ។ របៀបវារៈវិស័យអប់រំជាថ្មីដែលបានរៀបរាប់ក្នុងគោលដៅទី៤ គឺមានភាពទូលំទូលាយពិស្ដារ មហិច្ឆតា សេចក្ដីប្រាថ្នាខ្ពស់និងសកល និងបានបំផុសគំនិតដោយទស្សនៈវិស័យនៃការអប់រំដែលធ្វើឲ្យជីវិតរបស់បុគ្គលកាន់តែប្រសើរឡើង ក៏ដូចជាសហគមន៍ និងសង្គមដោយគ្មានបន្សល់ទុកនរណាម្នាក់នៅពីក្រោយឡើយ។ របៀបវារៈទាំងនេះចូលរួមយ៉ាងសកម្មក្នុងកិច្ចការដែលមិនទាន់បានបញ្ចប់នៃគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលទាក់ទងនឹងការអប់រំខណៈពេលដែលមានការដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងនាពេលអនាគតនៃវិស័យអប់រំជាកម្រិតថ្នាក់ជាតិ និងសកល។ សិទ្ធិជាមូលដ្ឋានបានបំផុសគំនិត ដោយទស្សនៈវិស័យមនុស្សជាតិនៃការអប់រំ និងការអភិវឌ្ឍដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស និងសេចក្ដីថ្លៃថ្នូរ យុត្តិធម៌សង្គម សន្តិភាព បរិយាប័ន្ន និងការការពារព្រមទាំងភាពចម្រុះគ្នានៃវប្បធម៌ ភាសានិងជនជាតិភាគតិច និងចែករំលែកនូវការទទួលខុសត្រូវនិងគណនេយ្យភាព [iii] ។

៥. ការកសាង និងការបន្តចលនាការអប់រំសម្រាប់ទាំងអស់គ្នា វិស័យអប់រំឆ្នាំ ២០៣០ យកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅលើបទពិសោធន៍មេរៀនផ្សេងៗ តាំងពីឆ្នាំ ២០០០។ អ្វីដែលថ្មីអំពីវិស័យអប់រំឆ្នាំ ២០៣០ គឺជាការផ្ដោតលើការកើនឡើង និងពង្រីកការចូលរៀន បែបបរិយាប័ន្ននិងសមភាព គុណភាព និងលទ្ធផលរៀនសូត្រនៅគ្រប់កម្រិតទាំងអស់ ក្នុងវិធីសាស្ត្រការរៀនពេញមួយជីវិត។ មេរៀនសំខាន់មួយនៃឆ្នាំកន្លងមកនេះ គឺរបៀបវារៈអប់រំជាសកល គួរធ្វើការជាមួយក្របខ័ណ្ឌអភិវឌ្ឍន៍អន្តរជាតិរួមជាមួយនឹងទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងការឆ្លើយតប និងតម្រូវការរបស់មនុស្សជាតិ ជាជាងការងារដែលផ្ដោតទៅលើគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលទាក់ទងនឹងការអប់រំ។ ដោយអនុម័តសេចក្ដីប្រកាសទីក្រុងអ៊ីនឈុនសហគមន៍នៃការអប់រំ បានកំណត់គោលដៅការអប់រំជាថ្មីតែមួយនៅក្នុងការអនុលោមតាមក្របខ័ណ្ឌអភិវឌ្ឍន៍ទាំងមូល។ របៀបវារៈនៃការអប់រំថ្មី ផ្ដោតទៅលើការអប់រំបែបបរិយាប័ន្ន និងសមភាព សំដៅលើការផ្ដល់ឱ្យមនុស្សគ្រប់រូបនូវឱកាសស្មើគ្នា និងគ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ។ ការបង្ហាញសញ្ញាមេរៀនមួយផ្សេងទៀតៈគឺជាតម្រូវការសម្រាប់ ថាតើសិស្សទាំងនេះ កំពុងតែសិក្សា និងទទួលបានជំនាញដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងពិសេសក្នុងគោលបំណងបង្កើនការផ្ដល់ដល់អ្នកដែលបាត់បង់ឱកាស ឬក្នុងស្ថានភាពងាយរងគ្រោះ។ មនុស្សទាំងអស់ដោយមិនគិតពី ភេទ អាយុ សម្បុរ ជាតិសាសន៍ ជនជាតិភាគតិច ភាសា សាសនា គំនិតនយោបាយ ឬបញ្ហាផ្សេងទៀត ដើមកំណើត ជាតិឬប្រភពដើមនៃសង្គម ទ្រព្យសម្បត្តិឬកំណើត ជនពិការ ជនអន្តោប្រវេសន៍ ជនជាតិដើមភាគតិច កុមារ និងយុវជន ជាពិសេសអ្នកនៅក្នុងស្ថានភាពដែលងាយរងគ្រោះ ឬស្ថានភាពផ្សេងទៀត[4] គួរតែបានសម្រាប់ការអប់រំបែបបរិយាប័ន្ន មានគុណភាពប្រកបដោយសមភាព និងឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ពួកគេ។ ការយកចិត្តទុកដាក់លើការអប់រំប្រកបដោយគុណភាព ការរៀនសូត្រនិងជំនាញ បានបញ្ជាក់មេរៀនសំខាន់មួយទៀតថាៈ ជាសញ្ញាអវិជ្ជមានមួយនៃការផ្ដោតជាសំខាន់តែលើការទទួលបានការអប់រំ ដោយមិនមានការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់ ថាតើសិស្សត្រូវការរៀន

4 ពីពេលនេះតទៅ៖ "ក្រុមបាត់បង់ឱកាស និងងាយរងគ្រោះ" សំដៅទៅលើក្រុមទាំងអស់នៅក្នុងបញ្ជីនេះ។ វាគួរតែត្រូវបានកត់សម្គាល់ថាបញ្ជីនេះ ដែលរួមបញ្ចូលគ្នាកថាខណ្ឌទី ១៩ និង២៥ នៃ "ការផ្លាស់ប្ដូរពិភពលោករបស់យើង៖ របៀបវារៈឆ្នាំ ២០៣០ ដើម្បីការអភិវឌ្ឍដោយចីរភាព" មិនសូវទូលំទូលាយ ហើយប្រទេស និងតំបន់ អាចកំណត់អត្តសញ្ញាណ និងដោះស្រាយផ្សេងទៀតដែលទាក់ទងនឹងស្ថានភាពងាយរងគ្រោះ ការជួបប្រទះការលំបាក នឹងការរើសអើង ដែលមានមូលដ្ឋាន និងការផាត់ចេញក្នុងវិស័យអប់រំ។

សូត្រ និងទទួលបានជំនាញដែលពាក់ព័ន្ធ ពេលដែលពួកគេរៀននៅសាលាដែរឬទេ។ ការពិតគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា មិនទាន់បានសម្រេចដល់ការអនុវត្តនូវមេរៀនបន្ថែមទៀត៖ "ធ្វើដូចធម្មតា" នឹងមិននាំមកនូវការអប់រំប្រកបដោយគុណភាពដល់មនុស្សទាំងអស់ឡើយ។ ប្រសិនបើអត្រានៃការរីកចម្រើននាពេលបច្ចុប្បន្ននៅតែបន្ត ប្រទេសជាច្រើនដែលដើរឆ្ងាយនៅពីក្រោយ នឹងមិនឈានដល់គោលដៅថ្មីនៅឆ្នាំ ២០៣០ ឡើយ។ នេះមានន័យថា វាជាការសំខាន់បំផុត ដើម្បីផ្លាស់ប្តូរការអនុវត្តបច្ចុប្បន្ន និងគៀងគរនូវកិច្ចខិតខំប្រឹងប្រែង និងធនធាននានាដែលធ្លាប់មានពីមុន។ លក្ខណៈពិសេសថ្មីមួយទៀតនៃរបៀបវារៈវិស័យអប់រំឆ្នាំ ២០៣០ គឺមានទម្រង់ជាសកល និងជាកម្មសិទ្ធិរបស់ពិភពលោកទាំងមូល ព្រមទាំងប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍន៍ដូចគ្នា។

៦. វិស័យអប់រំឆ្នាំ ២០៣០ ត្រូវតែមើលឃើញក្នុងបរិបទទូលំទូលាយនៃការអភិវឌ្ឍសម្រាប់ពេលបច្ចុប្បន្ន។ ប្រព័ន្ធអប់រំត្រូវតែមានការពាក់ព័ន្ធ និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរទីផ្សារការងារ បច្ចេកវិទ្យាខ្ពស់ នគរូបនីយកម្ម ការធ្វើចំណាកស្រុក អស្ថេរភាពនយោបាយ ការរិចរិលបរិស្ថាន គ្រោះធម្មជាតិនិងគ្រោះមហន្តរាយ ការប្រកួតប្រជែងសម្រាប់ធនធានធម្មជាតិ បញ្ហាប្រឈមបែបប្រជាសាស្ត្រឡើងយ៉ាងឆាប់រហ័ស ការបង្កើនភាពគ្មានការងារធ្វើសកល ភាពក្រីក្រដែលមិនចេះចប់ កំណើនវិសមភាព និងការគំរាមដល់សន្តិភាព និងសុវត្ថិភាព។ នៅឆ្នាំ ២០៣០ ប្រព័ន្ធអប់រំ នឹងត្រូវការចុះឈ្មោះកុមារចូលរៀនរាប់រយលាននាក់ និងមនុស្សវ័យជំទង់បន្ថែមទៀតដើម្បីសម្រេចបាននូវការអប់រំជាមូលដ្ឋាន (នោះគឺមុនបឋមសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) សម្រាប់ទាំងអស់គ្នា[iv] ព្រមទាំងផ្តល់នូវការចូលរួមដំណើរការស្មើគ្នាដល់ផ្នែកមធ្យមសិក្សា និងក្រោយមធ្យមសិក្សាសម្រាប់ទាំងអស់គ្នា។ ក្នុងពេលជាមួយគ្នានេះដែរ វាជាការសំខាន់ដើម្បីផ្តល់ការថែទាំកុមារតូច និងកម្មវិធីអប់រំដល់ពួកគេ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍការរៀនសូត្ររបស់កុមាររយៈពេលវែង និងសុខភាពរបស់ពួកគេ។ ជាការសំខាន់ណាស់សម្រាប់ប្រព័ន្ធអប់រំដើម្បីធានាឱ្យបានថាកុមារ យុវជន និងមនុស្សពេញវ័យទាំងអស់កំពុងរៀន និងទទួលបាននូវជំនាញពាក់ព័ន្ធរួមទាំងជំនាញអក្ខរកម្ម។ ហើយវាក៏មានតម្រូវការបន្ទាន់សម្រាប់កុមារ យុវជន និងមនុស្សពេញវ័យ ដើម្បីអភិវឌ្ឍន៍ពេញមួយជីវិត ទៅលើជំនាញផ្សេងៗ និងសមត្ថភាពដែលអាចបត់បែនបានសម្រាប់ការរស់នៅ និងនិរន្តរភាពការងារ និរន្តរភាពឯករាជ្យភាព ចំណេះដឹងមូលដ្ឋាន និងចំណេះដឹងផ្នែកបច្ចេកវិទ្យាក្នុងពិភពលោក។ ការអប់រំឆ្នាំ ២០៣០ នឹងធានាថាបុគ្គលគ្រប់រូប ទទួលបាននូវចំណេះដឹងមូលដ្ឋានរឹងមាំ អភិវឌ្ឍជំនាញនៃការគិតបែបច្នៃប្រឌិត និងពិចារណាខ្ពស់ និងកសាងនូវភាពចង់ដឹង ចង់ឃើញ ភាពក្លាហាន និងភាពរឹងមាំ។

៧. ការយកចិត្តទុកដាក់ជាថ្មីចំពោះគោលបំណង និងភាពពាក់ព័ន្ធនៃវិស័យអប់រំ សម្រាប់ការអភិវឌ្ឍធនធានមនុស្សចីរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន គឺជាលក្ខណៈពិសេសនៃរបៀបវារៈវិស័យអប់រំឆ្នាំ ២០៣០។ នេះត្រូវបានបង្កប់នៅក្នុងទស្សនៈវិស័យរួម និងផ្តោតសំខាន់លើមនុស្សជាតិដែលរួមចំណែកដល់ទម្រង់ថ្មីមួយនៃការអភិវឌ្ឍ។ ទស្សនៈវិស័យនេះ ជាវិធីសាស្ត្រដ៏មានប្រយោជន៍សម្រាប់ការអប់រំ និងរួមបញ្ចូលទាំងផ្នែកផ្សេងៗជាច្រើននៃជីវិតរបស់មនុស្ស [v p.10]។ នេះបានពន្យល់យ៉ាងច្បាស់ថាការអប់រំជាការរួមបញ្ចូលគ្នា និងជាការលើកស្ទួយលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្សយ៉ាងសំខាន់ និងការលើកកម្ពស់ភាពជាពលរដ្ឋសកលការអត់ឱន និងការចូលរួមរបស់ពលរដ្ឋ ព្រមទាំងការអភិវឌ្ឍដោយចីរភាព។ ការអប់រំជួយសម្រួលដល់កិច្ចសន្ទនាចំរុះពូជសាសន៍ និងជួយលើកកម្ពស់ការគោរពចំពោះភាពសម្បូរបែបនៃវប្បធម៌ សាសនា និងភាសា

ដែលមានប្រយោជន៍សម្រាប់ការសម្រេចបាននូវការផ្សារភ្ជាប់សង្គម និងសុចរិតភាព។

៨. សម្រាប់បណ្ដាប្រទេស និងសហគមន៍នានា ដែលក្រសោបយកតម្រូវការដើម្បីនាំមកនូវគុណភាពវិស័យអប់រំសម្រាប់ទាំងអស់គ្នា ទទួលបានផលប្រយោជន៍យ៉ាងធំសម្បើម។ ភស្តុតាងនៃអំណាចដែលមិនអាចអ្វីប្រៀបបាននឹងការអប់រំក្នុងការធ្វើឱ្យជីវិតកាន់តែប្រសើរឡើង ជាពិសេសសម្រាប់ក្មេងស្រីនិងស្ត្រី បន្តកើនឡើង [vi] ។ **ការអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការលុបបំបាត់ភាពក្រីក្រ:** វាជួយប្រជាជនទទួលបានការងារសមរម្យ បង្កើនប្រាក់ចំណូល និងបង្កើនផលិតភាពលើផ្នែកអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងខ្លាំង។ ការអប់រំ គឺជាមធ្យោបាយដែលមានឥទ្ធិពលបំផុត ក្នុងការសម្រេចបាននូវសមភាពយេនឌ័រក្នុងការធ្វើឱ្យក្មេងស្រី និងស្ត្រីមានការចូលរួមពេញលេញក្នុងសង្គមនិងនយោបាយនិងការពង្រឹងសិទ្ធិអំណាចរបស់ពួកគេផ្នែកសេដ្ឋកិច្ចផងដែរ។ ការអប់រំ គឺជាផ្នែកមួយនៃវិធីដែលមានប្រសិទ្ធភាពបំផុត ដើម្បីលើកកម្ពស់សុខភាពរបស់បុគ្គល និងដើម្បីធ្វើឱ្យប្រាកដថាអត្ថប្រយោជន៍នឹងត្រូវបញ្ជូនទៅជំនាន់ក្រោយនាពេលអនាគត។ វាអាចសង្គ្រោះជីវិតម្ដាយ និងក្មេងរាប់លាននាក់អាចជួយការពារជម្ងឺ និងវាមានជាតុសំខាន់នៃកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយកង្វះអាហារូបត្ថម្ភ។ លើសពីនេះទៅទៀត ការអប់រំបានលើកកម្ពស់ការដាក់បញ្ចូលជនពិការ [vii]។ គឺជាការការពារជាមូលដ្ឋានសម្រាប់កុមារ មនុស្សវ័យជំទង់ និងមនុស្សពេញវ័យដែលមានជីវិតរស់នៅត្រូវបានបំផ្លិចបំផ្លាញដោយវិបត្តិនិងជម្លោះ និងផ្តល់ឱ្យពួកគេជាមួយនឹងឧបករណ៍ទាំងឡាយ ដើម្បីកសាងជីវិត និងសហគមន៍របស់ពួកគេឡើងវិញ។

៩. ការផ្ដល់អំណាចនៃការអប់រំសម្រាប់ទាំងអស់គ្នា នឹងតម្រូវឱ្យមានការបង្កើតឱកាសកាន់តែច្រើននៅគ្រប់ទីកន្លែង ជាពិសេសនៅក្នុងប្រទេស និងតំបន់ដែលមានជម្លោះ។ ភាគច្រើននៃគម្លាតធំជាងគេបំផុតនៃការអប់រំត្រូវបានរកឃើញនៅក្នុងស្ថានភាពជម្លោះ និងសង្គ្រោះបន្ទាន់។ ដូច្នេះសំខាន់ណាស់ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធអប់រំមួយដែលមានភាពបន្សាំ និងឆ្លើយតបទៅនឹងជម្លោះ ចលាចលសង្គមនិងគ្រោះធម្មជាតិ និងដើម្បីធានាឱ្យបានការអប់រំមួយដែលត្រូវបានរក្សាក្នុងអំឡុងពេលមានស្ថានភាពសង្គ្រោះបន្ទាន់ ជម្លោះ និងក្រោយជម្លោះ។ ភាពប្រសើរឡើងនៃការអប់រំ គឺមូលដ្ឋានគ្រឹះដើម្បីការពារ និងកាត់បន្ថយជម្លោះ និងវិបត្តិផ្សេងៗ ព្រមទាំងដើម្បីលើកកម្ពស់សន្តិភាព។

១០. គោលការណ៍ដែលបានជូនដំណឹងពីក្របខ័ណ្ឌនេះ ត្រូវបានដកចេញពីលក្ខខ័ណ្ឌ និងកិច្ចព្រមព្រៀងអន្តរជាតិរួមមាន: មាត្រា ២៦ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស [viii] អនុសញ្ញាប្រឆាំងនឹងការរើសអើងនៅក្នុងការអប់រំ [ix] អនុសញ្ញាស្ដីពីសិទ្ធិកុមារ [x] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ [xi] អនុសញ្ញា អង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ [xii] អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ [xiii] អនុសញ្ញាដែលទាក់ទងទៅនឹងស្ថានភាពនៃជនភៀសខ្លួន [xiv] និងសេចក្ដីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ ស្ដីពីសិទ្ធិអប់រំនៅក្នុងស្ថានភាពបន្ទាន់ [xv]។គោលការណ៍ទាំងនោះរួមមាន:

- **ការអប់រំ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងជាសិទ្ធិដែលអាចជម្រុញឲ្យមានសិទ្ធិផ្សេងទៀត។** ដើម្បីបំពេញសិទ្ធិនេះប្រទេសទាំងអស់ត្រូវតែធានាសិទ្ធិស្មើគ្នាជាសកល ដើម្បីការអប់រំនិងរៀនសូត្រប្រកបដោយគុណភាពបែបបរិយាប័ន្ន និងសមភាព ហើយដែលគួរតែ**មិនគិតថ្លៃ និងជាកាតព្វកិច្ច**សម្រាប់ទាំងអស់គ្នា។ ការអប់រំមានគោលបំណងនៅក្នុងការអភិវឌ្ឍពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងការលើកកម្ពស់ការ

យល់ដឹងរវាងគ្នាទៅវិញទៅមក ការអត់ឱន មិត្តភាព និងសន្តិភាព។

- **ការអប់រំ គឺសម្បត្តិសាធារណៈ** រដ្ឋគឺអ្នកកាន់កាតព្វកិច្ចក្នុងការផ្តល់ជូនសាធារណៈជន។ ការអប់រំ គឺជាការខិតខំចែករំលែកសង្គមដែលបានបញ្ជាក់ពីដំណើរការនៃការរួមបញ្ចូលនៃការបង្កើតគោលនយោបាយសាធារណៈនិងការអនុវត្ត។ សង្គមស៊ីវិល គ្រូបង្រៀននិងអ្នកអប់រំ វិស័យឯកជន សហគមន៍ ក្រុមគ្រួសារ យុវជន និងកុមារទាំងអស់ មានតួនាទីសំខាន់ក្នុងការសម្រេចបានសិទ្ធិក្នុងការអប់រំប្រកបដោយគុណភាព។ តួនាទីរបស់រដ្ឋគឺមានសារៈសំខាន់ក្នុងការកំណត់ និងការគ្រប់គ្រងស្តង់ដា និងបទដ្ឋាន [xvi]។
- **សមភាពយេនឌ័រ** ត្រូវបានផ្សារភ្ជាប់ទៅនឹងសិទ្ធិក្នុងការអប់រំសម្រាប់ទាំងអស់គ្នា។ ការសម្រេចបាននូវសមភាពយេនឌ័រតម្រូវឱ្យមានវិធីសាស្រ្តផ្អែកទៅលើសិទ្ធិ ដែលធានាថា កុមារា កុមារី ស្រ្តី និងបុរសមិនមែនត្រឹមតែទទួលបាននូវការរៀនសូត្រពេញលេញនៃវដ្តអប់រំប៉ុណ្ណោះទេ ថែមទាំងត្រូវបានផ្តល់សិទ្ធិអំណាចស្មើភាពនៅក្នុង និងតាមរយៈការអប់រំ។

# II. គោលដៅ វិធីសាស្រ្តជាយុទ្ធសាស្រ្ត ចំណុចដៅ និងសូចនាករនានា

## គោលដៅរួម

*"ធានាបាននូវការអប់រំដែលមានគុណភាពតាមបែបបរិយាប័ន្ននិងសមភាព និងលើកកម្ពស់ឱកាសក្នុងការរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"*

១១. របៀបវារៈរួមឆ្នាំ ២០៣០ សម្រាប់គោលដៅអប់រំនៃការអភិវឌ្ឍដោយចីរភាព (SDG4) ប្តេជ្ញាចិត្តផ្តល់នូវការអប់រំប្រកបដោយគុណភាពតាមបែបបរិយាប័ន្ននិងសមភាពនៅគ្រប់កម្រិត និងបង្ហាញពីលក្ខណៈពិសេសថ្មីមួយនៃការអប់រំឆ្នាំ ២០៣០ ដែលបានពង្រឹងក្របខ័ណ្ឌសម្រាប់ការអនុវត្តសកម្មភាព។

១២. ធានាបាននូវ**ការចូលរៀន** និងបញ្ចប់ការអប់រំជូនដល់កុមារ និងយុវជន យ៉ាងហោចណាស់១២ឆ្នាំ ដោយឥតគិតថ្លៃ ដែលផ្តល់មូលនិធិដោយរដ្ឋ ការអប់រំដែលមានគុណភាពកម្រិតបឋមសិក្សា និងមធ្យមសិក្សាដោយមានបរិយាប័ន្ន និងសមភាពដែលយ៉ាងហោចណាស់ពួកគេត្រូវទទួលបានការអប់រំ៩ឆ្នាំជាកំហិត ព្រមទាំងការទទួលបានការអប់រំដែលមានគុណភាពសម្រាប់ក្មេង និងយុវជនមិនបានចូលរៀនតាមរយៈគំរូផ្សេងៗគ្នា។ ធានាការផ្តល់ឱកាសរៀនសូត្រ ដូច្នេះយុវជន និងមនុស្សពេញវ័យទាំងអស់ ទទួលបានចំណេះដឹងលើផ្នែកមូលដ្ឋានគ្រឹះជាអក្សរ និងលេខ ហើយក៏ដើម្បីជម្រុញឱ្យមានការចូលរួមយ៉ាងពេញលេញដល់ពួកគេក្នុងនាមជាប្រជាពលរដ្ឋសកម្ម។ ការផ្តល់ឲ្យយ៉ាងហោចណាស់១ឆ្នាំដោយឥតគិតថ្លៃ នូវការអប់រំកំរិតមត្តេយ្យសិក្សាដែលមានគុណភាពល្អ គួរតែត្រូវបានលើកទឹកចិត្ត ។

១៣. ធានា**សមភាព និងបរិយាប័ន្ន**នៅក្នុង និងតាមរយៈការអប់រំ និងដោះស្រាយគ្រប់ទម្រង់ទាំងអស់នៃការផាត់ចេញ និងការជួបប្រទះការលំបាកភាពខុសគ្នា ភាពងាយរងគ្រោះ និងវិសមភាពក្នុងការទទួលបានការអប់រំ ការចូលរួម ការរក្សាទុកការបញ្ចប់ និងលទ្ធផលនៃការរៀនសូត្រ។ ការអប់រំបែបបរិយាប័ន្ន សម្រាប់ទាំងអស់គ្នា គួរតែត្រូវ

បានធានាដោយការបង្កើត និងអនុវត្តគោលនយោបាយសាធារណៈសម្រាប់ការផ្លាស់ប្តូរដើម្បីឆ្លើយតបនឹងភាពចម្រុះ តម្រូវការ និងដើម្បីដោះស្រាយទម្រង់ជាច្រើននៃការរើសអើង ព្រមទាំងស្ថានភាពរួមទាំងការសង្គ្រោះបន្ទាន់ដែលនឹងប៉ះពាល់ដល់ការបំពេញនៃសិទ្ធិទទួលបានការអប់រំផងដែរ។ **ខណៈសមភាពយេនឌ័រ** គឺជាលក្ខណៈពិសេសសំខាន់មួយផ្សេងទៀតនៃការអប់រំឆ្នាំ ២០៣០ របៀបវារៈនេះ ត្រូវយកចិត្តទុកដាក់ជាពិសេសទៅនឹងការរើសអើងយេនឌ័រ ក្រុមដែលងាយរងគ្រោះ និងដើម្បីធានាមានការចូលរួមទាំងអស់គ្នា។ គ្មានចំណុចដៅនៃការអប់រំណាមួយត្រូវបានសន្និដ្ឋានថាជោគជ័យ លុះត្រាណាតែចំណុចដៅបានសម្រេចព្រមគ្នាទាំងអស់។

១៤. ផ្នែករួមមួយនៃសិទ្ធិទទួលបានការអប់រំ គឺជានាបានថា ការអប់រំ គឺទាក់ទងនឹង**គុណភាព**គ្រប់គ្រាន់ដើម្បីនាំឱ្យមានលទ្ធផលនៃការសិក្សាដែលមានប្រសិទ្ធភាពនិងសមភាពនានានៅគ្រប់កម្រិត និងគ្រប់ស្ថានភាពទាំងអស់។ យ៉ាងហោចណាស់ គុណភាពអប់រំចាំបាច់ធ្វើឲ្យអ្នកសិក្សាទាំងនោះ អាចអភិវឌ្ឍន៍នូវជំនាញជាមូលដ្ឋាននៃអក្ខរកម្ម និងគិតលេខដែលជាការកសាងឃ្លាំងសម្រាប់អនាគតការរៀនសូត្រដ៏វែងឆ្ងាយជាងនេះបន្ថែមទៀត។ នេះតម្រូវឱ្យមានវិធីសាស្ត្រនៃការបង្រៀន និងការរៀនដែលពាក់ព័ន្ធ ព្រមទាំងខ្លឹមសារដែលបំពេញតម្រូវការរបស់សិស្សទាំងអស់ ហើយបង្រៀនដោយគ្រូដែលមានលក្ខណៈសម្បត្តិល្អ ការទទួលបានការបណ្តុះបណ្តាលគ្រូដែលមានការលើកទឹកចិត្ត និងប្រាក់ឈ្នួលគ្រប់គ្រាន់ ដោយប្រើវិធីសាស្ត្រគរុកោសល្យសមរម្យ និងត្រូវបានគាំទ្រដោយការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ព្រមទាំងបង្កើតឲ្យមានសុវត្ថិភាពសុខភាព បញ្ហាយេនឌ័រដែលមានការឆ្លើយតប បរិយាប័ន្ន និងមានធនធានបរិស្ថានគ្រប់គ្រាន់ដែលជួយសម្រួលដល់ការរៀនសូត្រ។

១៥. សិទ្ធិទទួលបានការអប់រំ ចាប់ផ្តើមតាំងពីកំណើត និងបន្តរហូតពេញមួយជីវិត ហេតុនេះហើយបានជាទស្សនៈទាននៃ**ការសិក្សាពេញមួយជីវិត**[5] បានដឹកនាំទៅរកគោលដៅវិស័យអប់រំឆ្នាំ ២០៣០។ ដើម្បីឲ្យមានភាពស៊ីសង្វាក់ និងបំពេញនូវចន្លោះខ្វះខាតសម្រាប់ការអប់រំក្នុងប្រព័ន្ធ ឱកាសនៃការសិក្សាពេញមួយជីវិតដែលមានភាពបត់បែន និងទូលំទូលាយគួរតែត្រូវបានផ្តល់បន្ថែមទៀត តាមរយៈការអប់រំក្រៅប្រព័ន្ធដែលមានយន្តការនិងធនធានគ្រប់គ្រាន់ និងតាមរយៈការជម្រុញការអប់រំក្រៅប្រព័ន្ធដោយរួមទាំងការប្រើប្រាស់ ICT ។

## វិធីសាស្ត្រជាយុទ្ធសាស្ត្រ

១៦. ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពលើវិស័យអប់រំ និងចំណុចដៅអប់រំ ព្រមទាំម SDGs ផ្សេងទៀតសំខាន់ណាស់ដើម្បីគៀងគរនូវកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោកដែលមានគោលបំណងលើះ

- ការសម្រេចបាននូវភាពជាដៃគូដែលមានប្រសិទ្ធិភាព និងបរិយាប័ន្ន
- ការកែលម្អគោលនយោបាយអប់រំ និងវិធីដែលពួកគេអាចធ្វើការរួមគ្នាបាន

5 នៅក្នុងខ្លឹមសាររួម សិក្សាពេញមួយជីវិត ត្រូវបានចាក់ឫសគល់ក្នុងការធ្វើសមាហរណកម្មនៃការសិក្សា និងការរស់នៅ ដោយគ្របដណ្តប់ សកម្មភាពសិក្សាសម្រាប់មនុស្សគ្រប់វ័យ (កុមារ មនុស្សវ័យក្មេង មនុស្សពេញវ័យ និងក្មេងស្រី ដែលមានវ័យចំណាស់ និងកុមារា ស្ត្រី និងបុរស) នៅបរិបទជីវិតទាំងអស់ (ជាលក្ខណៈ គ្រួសារ សាលារៀន សហគមន៍ កន្លែងការងារ ជាដើម) និងតាមរយៈភាពខុសគ្នានៃបែបបទ (ផ្លូវការ និងមិនផ្លូវការ និងក្រៅប្រព័ន្ធ) ដែលរួមគ្នាក្នុងការបំពេញនូវតម្រូវការនៃការរៀនមួយ។ ប្រព័ន្ធអប់រំដែលជម្រុញការរៀនសូត្រពេញមួយជីវិត ទទួលយកវិធីសាស្ត្រវិស័យទាំងមូល ពាក់ព័ន្ធនឹងគ្រប់អនុវិស័យនិងកម្រិត ដើម្បីធានាឱ្យមានការផ្តល់ឱកាសរៀនសម្រាប់បុគ្គលទាំងអស់" (វិទ្យាស្ថានអង្គការយូណេស្កូ សម្រាប់ការសិក្សាពេញមួយជីវិតះ http : / /uil.unesco.org/fileadmin/keydocuments/LifelongLearning/en/UNESCOTechNotesLLL.pdf ) ។

- ការធានាប្រព័ន្ធអប់រំដែលមានសមភាពខ្ពស់ បរិយាប័ន្ន និងមានគុណភាពសម្រាប់ទាំងអស់គ្នា
- ការកៀងគរធនធានសម្រាប់ការផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ការអប់រំ
- ធានាការត្រួតពិនិត្យ តាមដាន និងពិនិត្យឡើងវិញនៃចំណុចដៅទាំងអស់នេះ។

សំណុំនៃវិធីសាស្ត្រជាយុទ្ធសាស្ត្រ (ដូចគូសបញ្ជាក់ខាងក្រោម) ត្រូវបានផ្តល់ជាអនុសាសន៍ដើម្បីចែកចាយពីគោលដៅអប់រំជាសកលឆ្នាំ ២០៣០ និងរបៀបវារៈកាន់តែច្រើន និងប្រកបដោយមហិច្ឆតាខ្ពស់ ព្រមទាំងដើម្បីត្រួតពិនិត្យវឌ្ឍនភាព។ ការកសាងនៅបទពិសោធន៍នានាដែលទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) និង (EFA) រដ្ឋគួរតែវិនិយោគ និងពង្រីកការច្នៃប្រឌិតថ្មី វិធីសាស្ត្រភស្តុតាងជាមូលដ្ឋាន និងការចំណាយមានប្រសិទ្ធិភាព ដែលអាចឱ្យបុគ្គលគ្រប់រូបអាចទទួលបាន អាចចូលរួមបាន អាចរៀនសូត្របាន និងអាចបញ្ចប់ការអប់រំដែលមានគុណភាពមួយបានដោយផ្តោតជាពិសេសដល់អ្នកដែលមានការលំបាកបំផុតដើម្បីការឈានដល់បរិបទទាំងអស់នេះ។ លើសពីនេះទៀត យុទ្ធសាស្ត្រដែលចង្អុលបង្ហាញយ៉ាងជាក់លាក់ ទៅលើចំណុចដៅនីមួយៗ ត្រូវបានរៀបរាប់ក្រោមគោលដៅផ្សេងៗ។ អ្វីៗគួរតែត្រូវបានកត់សម្គាល់ថាយុទ្ធសាស្ត្រទាំងនេះគឺមានលក្ខណៈទូទៅហើយនឹងតម្រូវឱ្យមានការសម្របតាមឲ្យបានសមរម្យ ដោយរដ្ឋាភិបាលលើបរិបទ និងអាទិភាពរបស់ប្រទេសនីមួយៗ។

## ការពង្រឹងគោលនយោបាយ ផែនការ ច្បាប់ និងប្រព័ន្ធ

១៧. ឧបករណ៍ស្តង់ដារអន្តរជាតិមួយចំនួនការពារសិទ្ធិមនុស្សជាមូលដ្ឋានលើការអប់រំ។ ឧបករណ៍ផ្លូវច្បាប់ទាំងអស់ដូចជាសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងពិធីការព្រមទាំងឧបករណ៍អន្តរជាតិមួយចំនួនទៀតរួមមានអនុសាសន៍ និងសេចក្តីប្រកាសនានា [xvii] ដែលមានកម្លាំងនយោបាយ និងសីលធម៌បានបង្កើតឡើងនូវក្របខ័ណ្ឌបទដ្ឋានអន្តរជាតិយ៉ាងរឹងមាំសម្រាប់សិទ្ធិទទួលបានការអប់រំដោយគ្មានការរើសអើង ឬការផាត់ចេញ។ ការត្រួតពិនិត្យលើការចូលរួមនៃភាគីពាក់ព័ន្ធ ដែលដឹកនាំដោយរដ្ឋាភិបាល គួរតែត្រូវបានអនុវត្ត ដើម្បីបង្កើតវិធានការក្នុងការបំពេញកាតព្វកិច្ចរបស់ពួកគេ និងដើម្បីធានាឱ្យបាននូវច្បាប់រឹងមាំ ក្របខ័ណ្ឌគោលនយោបាយដែលបង្ហាញពីមូលដ្ឋានគ្រឹះ លក្ខខ័ណ្ឌសម្រាប់ការចែកចាយ និងនិរន្តរភាពនៃគុណភាពអប់រំ។

១៨. នៅក្នុងការអនុវត្តរបៀបវារៈថ្មីនេះ គួរផ្តោតសំខាន់ទៅលើតម្លាភាព ប្រសិទ្ធិភាព និងសមភាពនៃប្រព័ន្ធអប់រំទាំងអស់។ ប្រព័ន្ធអប់រំទាំងអស់ គួរឈានដល់កម្រិតដែលមានភាពទាក់ទាញ និងរក្សាបាននូវក្រុមដែលមិនបានរាប់បញ្ចូលនាពេលបច្ចុប្បន្ន ឬស្ថិតក្នុងស្ថានភាពហានិភ័យនៃការបាត់បង់ឱកាស។ លើសពីនេះទៀត ដើម្បីធានាឱ្យមានគុណភាពអប់រំ និងលក្ខខណ្ឌសម្រាប់លទ្ធផលអប់រំប្រកបដោយប្រសិទ្ធិភាព រដ្ឋាភិបាលគួរពង្រឹងប្រព័ន្ធអប់រំដោយរៀបចំ និងលើកកម្ពស់យន្តការនៃការទទួលខុសត្រូវ និងអភិបាលកិច្ចដែលមានការចូលរួមប្រកបដោយប្រសិទ្ធិភាព និងសមរម្យ ការធានាគុណភាព ប្រពន្ធ័គ្រប់គ្រងព័ត៌មានអប់រំ នីតិវិធីហិរញ្ញប្បទានប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព ព្រមទាំងយន្តការដ៏ទៃទៀត ហើយរៀបចំគ្រប់គ្រងស្ថាប័នក៏ដូចជាធានាថាមានទិន្នន័យដ៏រឹងមាំរួចជាស្រេច និងអាចប្រើប្រាស់បានទាន់ពេលវេលា។ ការច្នៃប្រឌិត និងICT ត្រូវតែបានយកចិត្តទុកដាក់ដើម្បីពង្រឹងប្រព័ន្ធអប់រំ ការផ្សព្វផ្សាយចំណេះដឹង ទទួលបានការផ្តល់ព័ត៌មាន លើកកម្ពស់គុណភាពសិក្សា និងផ្តល់សេវាមានប្រសិទ្ធភាពជាងមុន។ ការពង្រឹងប្រព័ន្ធ គួរយកចិត្តទុកដាក់លើកិច្ចប្រតិបត្តិ

ការរវាងប្រទេសកំពុងអភិវឌ្ឍន៍សិក្សាពីប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នាដែលត្រូវបានទទួលការគាំទ្រដោយប្រទេសអភិវឌ្ឍរួចហើយ (South-South និង triangular cooperation) និងការចែករំលែកបទពិសោធន៍ល្អដែលអនុឡោមទៅតាមបរិបទកម្រិតប្រទេស និងក្នុងតំបន់។

**ការផ្តោតលើសមធម៌ បរិយាប័ន្ន និងសមភាពយេនឌ័រ**

១៩. គោលនយោបាយ និងផែនការអន្តរវិស័យគួរតែត្រូវបានអភិវឌ្ឍន៍ ឬធ្វើឲ្យមានភាពប្រសើរឡើងស្របជាមួយនឹងរបៀបវារៈរួមឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព ដើម្បីដោះស្រាយឧបសគ្គសង្គម វប្បធម៌ និងសេដ្ឋកិច្ចដែលមិនបានយកចិត្តទុកដាក់លើការអប់រំកុមារ យុវជន និងមនុស្សពេញវ័យរាប់លាននាក់ ព្រមទាំងគុណភាពរៀនសូត្ររបស់ពួកគេ។ ស្តង់ដារកម្រិតមធ្យម និងដំណើរការដ៏ជាក់លាក់ហើយពោរពេញដោយប្រកដនិយមដែលពាក់ព័ន្ធនានា គួរតែត្រូវបានកំណត់នៅថ្នាក់ជាតិ។ នេះត្រូវតែរួមបញ្ចូលទាំងការផ្លាស់ប្តូរឲ្យបានសមរម្យនៅក្នុងមាតិកាអប់រំ វិធីសាស្រ្ត រចនាសម្ព័ន្ធ និងយុទ្ធសាស្រ្តនៃការផ្តល់មូលនិធិដើម្បីដោះស្រាយស្ថានភាពកុមារ យុវជន និងមនុស្សពេញវ័យជាច្រើនដែលត្រូវបានផាត់ចេញ។ គោលនយោបាយ និងយុទ្ធសាស្រ្តដែលផ្អែកលើភស្តុតាងដើម្បីដោះស្រាយការផាត់ចេញ អាចរួមបញ្ចូលសម្រាប់ការលុបបំបាត់ឧបសគ្គក្នុងការចំណាយផ្សេងៗ តាមរយៈឧទាហរណ៍មួយចំនួនដូចជា៖ កម្មវិធីផ្ទេរសាច់ប្រាក់ ការផ្តល់អាហារនៅសាលា / អាហារូបត្ថម្ភនិងសេវាសុខភាព សម្ភារៈសិក្សានិងការបង្រៀន សេវាដឹកជញ្ជូន កម្មវិធីដែលផ្តល់ឱកាស/ចូលរៀនឡើងវិញជាលើកទីពីរ សម្ភារៈសាលាបែបបរិយាប័ន្ន ការបណ្តុះបណ្តាលគ្រូអប់រំបរិយាប័ន្ន និងគោលនយោបាយភាសាដើម្បីដោះស្រាយបញ្ហាផាត់ចេញ។ ដើម្បីវាស់វែងពីការជួបប្រទះការលំបាកក្នុងវិស័យអប់រំវាត្រូវបានកំណត់ទិសដៅច្បាស់លាស់ ដើម្បីកាត់បន្ថយវិសមធម៌ និងតាមដានការរីកចម្រើនឆ្ពោះទៅរកចំណុចដៅទាំងនេះ ហើយបណ្តាប្រទេសទាំងអស់គួរតែប្រមូល វិភាគ និងប្រើប្រាស់ទិន្នន័យបំណែងចែកលម្អិតនូវដោយលក្ខណៈជាក់លាក់នៃក្រុមប្រជាពលរដ្ឋដែលបានផ្តល់ឲ្យ និងធានាឲ្យបានថាសូចនាករវាស់ស្ទង់ការរីកចម្រើនឆ្ពោះទៅរកការកាត់បន្ថយវិសមភាព។

២០. ដើម្បីធានាឱ្យមានសមភាពយេនឌ័រ ប្រព័ន្ធអប់រំត្រូវតែធ្វើសកម្មភាពឱ្យបានច្បាស់ ដើម្បីលុបបំបាត់ភាពលំអៀងយេនឌ័រ និងការរើសអើងពីឥរិយាបទសង្គមនិងវប្បធម៌ និងការអនុវត្តព្រមទាំងស្ថានភាពសេដ្ឋកិច្ច។ រដ្ឋាភិបាលនិងដៃគូនានាត្រូវមានជាចាំបាច់លើគោលនយោបាយភាពងាយទទួលរងគ្រោះនៃបញ្ហាយេនឌ័រ ការធ្វើផែនការនិងបរិស្ថានសិក្សា បញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងដំណើរការបណ្តុះបណ្តាលគ្រូបង្រៀន និងត្រួតពិនិត្យកម្មវិធីសិក្សា ព្រមទាំងលុបបំបាត់ការរើសអើងយេនឌ័រ និងអំពើហឹង្សានៅក្នុងស្ថាប័នអប់រំ ដើម្បីធានាឱ្យបាននូវការបង្រៀន និងការរៀនមានឥទ្ធិពលស្មើគ្នានៅលើកុមារី កុមារា ស្ត្រី និងបុរស ព្រមទាំងដើម្បីលុបបំបាត់ផ្នត់គំនិតមិនល្អពីយេនឌ័រ និងភាពជឿនលឿននៃសមភាពយេនឌ័រ។ វិធានការពិសេសគួរតែត្រូវបានអនុវត្តន៍ដើម្បីធានាឱ្យបាននូវសន្តិសុខផ្ទាល់ខ្លួនរបស់ក្មេងស្រី និងស្ត្រីនៅក្នុងស្ថាប័នអប់រំ និងនៅលើការធ្វើដំណើរទៅមករបស់ពួកគេក្នុងគ្រប់ស្ថានភាពទាំងអស់ ជាពិសេសក្នុងអំឡុងពេលមានជម្លោះ និងវិបត្តិ ។

២១. យោងលើឧបសគ្គសំខាន់ៗដែលជនពិការជួបប្រទះក្នុងការទទួលបានឱកាសការអប់រំប្រកបដោយគុណភាព និងកង្វះទិន្នន័យដើម្បីគាំទ្រដល់កិច្ចអន្តរាគមន៍ដ៏មានប្រសិទ្ធិភាព ជាពិសេសត្រូវយកចិត្តទុកដាក់លើការធានាឲ្យទទួលបាន និងមានលទ្ធផលនៃគុណភាពអប់រំ ព្រមទាំងការរៀនសូត្រសម្រាប់កុមារ យុវជន និងមនុស្សពេញវ័យដែលមានពិការភាព។

## ការផ្តោតសំខាន់លើគុណភាព និងការរៀនសូត្រ

២២. ការកើនឡើងនៃការទទួលបានការអប់រំត្រូវតែបានភ្ជាប់មកដោយវិធានការមួយចំនួន ដើម្បីកែលម្អគុណភាព និងការទាក់ទងនៃការអប់រំ និងការរៀន។ ស្ថាប័ន និងកម្មវិធីអប់រំគួរតែត្រូវបានផ្តល់ធនធានគ្រប់គ្រាន់ និងសមភាពជាមួយនឹងសុវត្ថិភាព បរិស្ថានដ៏ស្និតស្នាល និងផ្តល់ភាពងាយស្រួលក្នុងការទទួលបានការផ្គត់ផ្គង់នានា គ្រូមានចំនួនគ្រប់គ្រាន់ និងមានគុណភាពអប់រំបែបសិស្សមជ្ឈមណ្ឌលសកម្ម និងប្រើប្រាស់វិធីសាស្ត្រគរុកោសល្យបែបសហការគ្នា មានសៀវភៅសិក្សា សំភារៈសិក្សាផ្សេងៗ ធនធានអប់រំដ៏ទូលំទូលាយ និងបច្ចេកវិទ្យាដែលមិនមានការរើសអើង អំណោយផលដល់ការរៀន រៀនស្រួល បរិបទដាក់លាក់ ចំណាយមានប្រសិទ្ធិភាព និងអាចរកបានសម្រាប់អ្នកសិក្សាទាំងអស់រួមមាន កុមារ យុវជន និងមនុស្សពេញវ័យ។ គោលនយោបាយ និងបទបញ្ញត្តិគ្រូបង្រៀនគួរតែមាន ដើម្បីធានាថាគ្រូបង្រៀន និងអ្នកអប់រំត្រូវបានផ្តល់អំណាចគ្រប់គ្រាន់ក្នុងការជ្រើសរើសនិងផ្តល់ប្រាក់ឈ្នួល ទទួលបានការបណ្តុះបណ្តាលល្អ មានសមត្ថភាពវិជ្ជាជីវៈ មានការជម្រុញលើកទឹកចិត្តបានដាក់ពង្រាយដោយសមភាព និងប្រសិទ្ធិភាពនៅក្នុងប្រព័ន្ធអប់រំទាំងមូល និងបានគាំទ្រតាមប្រព័ន្ធគ្រប់គ្រងដែលមានប្រសិទ្ធិភាព និងមានធនធានគ្រប់គ្រាន់។ ប្រព័ន្ធ និងការអនុវត្តសម្រាប់ការវាយតម្លៃលើគុណភាពសិក្សាដែលរួមមានការវាយតម្លៃមានធាតុចូល បរិស្ថាន ដំណើរការ និងលទ្ធផលដែលគួរតែត្រូវបានបង្កើត ឬធ្វើឱ្យប្រសើរឡើង។ លទ្ធផលនៃការសិក្សាដែលពាក់ព័ន្ធត្រូវតែកំណត់ឲ្យបានល្អទាំងនៅក្នុងដែននៃការយល់ដឹងដោយប្រើការគិត និងមិនប្រើការគិត ហើយបន្តវាយតម្លៃជាបន្តបន្ទាប់ ដោយវាជាផ្នែករួមមួយនៃដំណើរការនៃការបង្រៀន និងរៀន។ គុណភាពអប់រំ រួមមានការអភិវឌ្ឍជំនាញផ្សេងៗ គុណតម្លៃ អាកប្បកិរិយា និងចំណេះដឹងដែលធ្វើឱ្យប្រជាពលរដ្ឋអាចដឹកនាំជីវិត ប្រកបដោយការពេញចិត្តនិងសុខភាពល្អ និងផ្តល់នូវការសម្រេចចិត្ត និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនៅកម្រិតតំបន់ និងសកល។ ការផ្តោតសំខាន់ទៅលើគុណភាព និងភាពច្នៃប្រឌិត នឹងតម្រូវឱ្យមានការពង្រឹងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងការអប់រំគណិតវិទ្យា (STEM)។

## ការលើកកម្ពស់ការសិក្សាពេញមួយជីវិត

២៣. ក្រុមអាយុទាំងអស់រួមទាំងមនុស្សពេញវ័យ គួរតែមានឱកាសក្នុងការរៀនសូត្រ និងបន្តការរៀនសូត្ររបស់ពួកគេ។ ការចាប់ផ្តើមតាំងពីពេលចាប់កំណើត សម្រាប់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា នៅគ្រប់បរិបទ និងនៅ គ្រប់កម្រិតទាំងអស់នៃការអប់រំគួរតែត្រូវបានបង្កប់នៅក្នុងប្រព័ន្ធអប់រំតាមរយៈយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ស្ថាប័ន កម្មវិធីដែលមានធនធានគ្រប់គ្រាន់ និងភាពជាដៃគូរឹងមាំនៅកម្រិតមូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងអន្តរជាតិ។ នេះ តម្រូវឱ្យមានការផ្តល់នូវរបៀបរៀនសូត្រអាចបត់បែនបាន និងមានភាពចំរុះ និងចំណុចចូល និងចំណុចចូលរៀនឡើងវិញនៅគ្រប់វ័យ និងគ្រប់កម្រិតនៃការអប់រំទាំងអស់ដែលបានពង្រឹងទំនាក់ទំនងរវាងរចនាសម្ព័ន្ធផ្លូវការ និងមិនផ្លូវការ និងការទទួលស្គាល់សុពលភាព និងគុណភាពអប់រំនៃចំណេះដឹង ជំនាញ និងសមត្ថភាពដែលទទួលបានតាមរយៈការអប់រំក្រៅប្រព័ន្ធ និងមិនផ្លូវការ។ ការសិក្សាពេញមួយជីវិតរួមបញ្ចូលទាំងការចូលរៀនប្រកបដោយសមភាព និងការកើនឡើងដល់ការអប់រំបែបច្ចេកទេសដែលមានគុណភាព វិជ្ជាជីវៈ ការបណ្តុះបណ្តាល ការអប់រំក្រោយឧត្តមសិក្សា និងការស្រាវជ្រាវដោយមានការយកចិត្តទុកដាក់លើការធានាគុណភាពពាក់ព័ន្ធ។

២៤. វិធានការពិសេស និងការកើនឡើងហិរញ្ញវត្ថុ ត្រូវការជាចាំបាច់ដើម្បីដោះស្រាយតម្រូវការរបស់អ្នកសិក្សាពេញវ័យនិងកុមារ យុវជននិងមនុស្សពេញវ័យរាប់លាននាក់ដែលមិនចេះអក្សរ។ លើសពីនេះទៅទៀត យុវជន និងមនុស្សពេញវ័យជាពិសេសក្មេងស្រី និងស្ត្រីគួរតែត្រូវបានផ្តល់ឱកាស ដើម្បីសម្រេចបាននូវការទទួលស្គាល់កម្រិតសមត្ថភាពផ្នែកអក្ខរកម្មនិងការគិតលេខ ទទួលបាននូវជំនាញសម្រាប់ជីវិត និងការងារសមរម្យ។ អ្វីដែលសំខាន់នោះ ការផ្តល់ឱកាសអប់រំ និងបណ្តុះបណ្តាដល់មនុស្សពេញវ័យត្រូវតែធានាឲ្យបាន។ វិធីសាស្ត្រអន្តរវិស័យ ដូចជាវិស័យអប់រំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ក្រុមគ្រួសារ ការងារ ការអភិវឌ្ឍសេដ្ឋកិច្ចនិងឧស្សាហកម្ម ការធ្វើចំណាកស្រុកនិងការធ្វើសមាហរណកម្ម ពលរដ្ឋ សុខុមាលភាពសង្គម និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គួរត្រូវបានប្រើប្រាស់។

## ការដោះស្រាយការអប់រំក្នុងស្ថានភាពអាសន្ន

២៥. គ្រោះមហន្តរាយធម្មជាតិ ជំងឺឆ្លងនិងជម្លោះ និងការផ្លាស់ទីលំនៅខាងក្នុងនិងឆ្លងដែន អាចធ្វើឲ្យមនុស្សមួយជំនាន់ប៉ះទង្គិចផ្លូវចិត្ត មិនបានទទួលការអប់រំ និងមិនបានត្រៀមខ្លួន ដើម្បីរួមចំណែកដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច និងសង្គមនៃប្រទេសឬតំបន់របស់ពួកគេ។ វិបត្តិ ជាឧបសគ្គធំមួយក្នុងការទទួលបានការអប់រំ ក្នុងករណីខ្លះអាចបញ្ឈប់ ឬបន្ថយការរីកចម្រើនដែលផ្ទុយពីគោលដៅអប់រំសម្រាប់ទាំងអស់គ្នា នៅក្នុងទសវត្សរ៍ចុងក្រោយនេះ។ ការអប់រំនៅក្នុងបរិបទអាសន្ន មានការការពារភ្លាមៗ ដោយផ្តល់នូវចំណេះដឹងក្នុងការសង្គ្រោះជីវិតនិងជំនាញ និងការគាំទ្រផ្លូវចិត្តដល់អ្នករងផលប៉ះពាល់ដោយវិបត្តិទាំងនោះ។ ការអប់រំ បំពាក់ដល់កុមារ យុវជន និងមនុស្សពេញវ័យនូវអនាគតប្រកបដោយនិរន្តរភាពមួយ ជាមួយនឹងជំនាញជាច្រើន ដើម្បីបង្ការគ្រោះមហន្តរាយ ជម្លោះ និងជំងឺផ្សេងៗ។

២៦. ដូច្នេះ បណ្តាប្រទេសទាំងអស់ ត្រូវតែមានវិធានការដើម្បីអភិវឌ្ឍន៍ប្រព័ន្ធអប់រំបែបបរិយាប័ន្នដ៏រឹងមាំ និងមានការឆ្លើយតប ដើម្បីបំពេញតម្រូវការរបស់កុមារ យុវជន និងមនុស្សពេញវ័យនៅក្នុងបរិបទដែលមានវិបត្តិទាំងនោះ រួមទាំងការផ្លាស់ទីលំនៅខាងក្នុងប្រទេស និងជនភៀសខ្លួន។ គោលការណ៍នៃការបង្ការ ការត្រៀមខ្លួន ការឆ្លើយតប និងគោលការណ៍ណែនាំអន្តរជាតិ ដែលបានបង្កើតឡើងដូចជា បទដ្ឋានអប្បបរមារបស់បណ្តាញអន្តរទីភ្នាក់ងារសម្រាប់ការអប់រំក្នុងស្ថានភាពអាសន្ន (INEE) គួរណែនាំការធ្វើផែនការ និងការឆ្លើយតប។ ផែនការវិស័យអប់រំ និងគោលនយោបាយគួរពិនិត្យមើលហានិភ័យ និងរួមបញ្ចូលវិធានការផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអប់រំរបស់កុមារ និងមនុស្សពេញវ័យនៅក្នុងស្ថានភាពមានវិបត្តិ។ ពួកគេគួរតែលើកកម្ពស់សុវត្ថិភាព ភាពរឹងមាំ និងការផ្សារភ្ជាប់សង្គម ជាមួយនឹងគោលបំណងនៃការកាត់បន្ថយហានិភ័យនៃជម្លោះ និងគ្រោះមហន្តរាយធម្មជាតិ។ សមត្ថភាពរបស់រដ្ឋាភិបាល និងសង្គមស៊ីវិលសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការអប់រំសន្តិភាព ការសម្របនឹងការប្រែប្រួលអាកាសធាតុនិងការត្រៀមសង្គ្រោះបន្ទាន់ និងការឆ្លើយតបផ្សេងៗ គួរតែត្រូវបានពង្រឹងនៅគ្រប់កម្រិតទាំងអស់ ដើម្បីធានាថាហានិភ័យទាំងឡាយត្រូវបានបន្ធូរបន្ថយ និងការអប់រំត្រូវបានថែរក្សា ក្នុងគ្រប់ដំណាក់កាលទាំងអស់ ចាប់ពីការឆ្លើយតបបន្ទាន់ដល់ការស្តារឡើងវិញ។ ការឆ្លើយតបដែលសម្របសម្រួលបានយ៉ាងល្អនៅថ្នាក់ជាតិ តំបន់ និងពិភពលោក ហើយនិងប្រព័ន្ធនានា គឺតម្រូវឲ្យមានការត្រៀមរៀបចំសម្រាប់ឆ្លើយតបទៅនឹងភាពអាសន្ន និងការកសាងឡើងវិញឲ្យល្អប្រសើរជាងមុន ឆ្ពោះទៅរកប្រព័ន្ធអប់រំមានសុវត្ថិភាព និងប្រកបដោយសមភាពជាងមុន។

២៧. អ្នកពាក់ព័ន្ធនានា គួរតែខិតខំប្រឹងប្រែង ដើម្បីធានាថាស្ថាប័នអប់រំត្រូវបានការពារជាតំបន់សន្តិភាពគ្មានអំពើហឹង្សា រួមទាំងអំពើហឹង្សាយេនឌ័រដែលទាក់ទងនឹងសាលា។ វិធានការពិសេស គួរតែត្រូវមាននៅនឹងកន្លែង ដើម្បីការពារស្ត្រី និងក្មេងស្រីនៅក្នុងតំបន់ជម្លោះ។ សាលារៀន និងស្ថាប័នអប់រំ ព្រមទាំងផ្លូវទៅនិងមករបស់ពួកគេ ត្រូវតែគ្មានការវាយប្រហារ ការជ្រើសរើសដោយបង្ខំ ការចាប់ជំរិត និងអំពើហឹង្សាផ្លូវភេទ។ ត្រូវចាត់ការបញ្ចប់និទណ្ឌភាពសម្រាប់បុគ្គល និងក្រុមប្រដាប់អាវុធដែលវាយប្រហារស្ថាប័នអប់រំ។

# ចំណុចដៅ និងយុទ្ធសាស្ត្រដែលចង្អុលបង្ហាញនានា

២៨. ចំណុចដៅនៃវិស័យអប់រំឆ្នាំ ២០៣០ គឺមានភាពជាក់លាក់ អាចវាស់វែងបាន និងបានចូលរួមចំណែកដោយផ្ទាល់ដល់ការសម្រេចបាននូវគោលបំណងរួមខាងលើនេះ។ ចំណុចដៅទាំងនេះ បានពន្យល់ពីកម្រិតជាសកលនៃមហិច្ឆតាដែលគួរលើកទឹកចិត្តឱ្យបណ្តាប្រទេសព្យាយាមឱ្យមានការរីកចម្រើនកើនឡើង។ ចំណុចដៅទាំងនេះ អាចអនុវត្តបានសម្រាប់ប្រទេសទាំងអស់ ដោយយកការគិតផ្សេងគ្នានៃតថភាពថ្នាក់ជាតិ សមត្ថភាព និងកម្រិតនៃការអភិវឌ្ឍ ការគោរពគោលនយោបាយជាតិ និងអាទិភាពនានា។ សកម្មភាពដែលដឹកនាំដោយប្រទេស នឹងជម្រុញឱ្យមានការផ្លាស់ប្តូរដែលបានគាំទ្រដោយភាពជាដៃគូ និងការផ្តល់ហិរញ្ញប្បទាន។ រដ្ឋាភិបាលត្រូវបានគេរំពឹងថានឹងអាចយកចំណុចដៅថ្នាក់សកលក្នុងការសម្រេចចំណុចដៅថ្នាក់ជាតិ ដោយផ្អែកលើអាទិភាពនៃវិស័យអប់រំ យុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍន៍ជាតិ វិធីដែលប្រព័ន្ធអប់រំត្រូវបានរៀបចំ សមត្ថភាពស្ថាប័ន និងលទ្ធភាពនៃធនធានរបស់ពួកគេ។ នេះតម្រូវឱ្យមានការបង្កើតការដៅទុកកំរិតមធ្យមដែលសមស្របមួយចំនួន (ឧទាហរណ៍សម្រាប់ឆ្នាំ ២០២០ និង២០២៥) តាមរយៈដំណើរការបញ្ចូលគ្នា ដោយមានតម្លាភាព និងការទទួលខុសត្រូវពេញលេញ ការចូលរួមពីដៃគូទាំងអស់ ដូច្នេះវាមានភាពជាម្ចាស់របស់ប្រទេសនីមួយៗ និងការយល់ដឹងជាទូទៅ។ ការដៅទុកកម្រិតមធ្យមអាចកំណត់សម្រាប់គោលដៅនីមួយៗ ដើម្បីបម្រើដល់ការដៅទុកចម្បងបែបបរិមាណ ដើម្បីការពិនិត្យឡើងវិញនៃការរីកចម្រើនជាសកលដែលពាក់ព័ន្ធគោលដៅរយៈពេលវែង។ ការដៅទុកបែបនេះ គួរតែកសាងនៅលើយន្តការក្នុងការរាយការណ៍សមស្របដែលមានស្រាប់។ ការដៅទុកកម្រិតមធ្យម គឺចាំបាច់សម្រាប់ដោះស្រាយឱនភាពនៃការទទួលខុសត្រូវដែលផ្សារភ្ជាប់ជាមួយនឹងចំណុចដៅរយៈពេលវែង។

**ចំណុចដៅ ៤.១**: ត្រឹមឆ្នាំ ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ បញ្ចប់ការសិក្សាដោយឥតគិតថ្លៃ ប្រកបដោយសមភាព និងគុណភាពនៃការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាដែលនាំមកនូវលទ្ធផលការសិក្សាដែលពាក់ព័ន្ធ និងមានប្រសិទ្ធិភាព។

២៩. ទោះបីជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ ២០០០មក កុមារប្រមាណជា៥៩លាននាក់ដែលមានអាយុរៀននៅសាលាបឋមសិក្សា និង៦៥លាននាក់នៃក្មេងជំទង់មានអាយុរៀននៅអនុវិទ្យាល័យ ហើយក្មេងស្រីភាគច្រើននៅមិនទាន់បានចូលរៀនក្នុងឆ្នាំ ២០១៣ [xviii] ។ លើសពីនេះទៀត មនុស្សជាច្រើនដែលនៅក្នុងសាលារៀន មិនទទួលបានចំណេះដឹងជាមូលដ្ឋាន និងជំនាញឡើយ។ យ៉ាងហោចណាស់ កុមារ ២៥០ លាននាក់ មានអាយុរៀននៅបឋមសិក្សាជាង ៥០% នៃអ្នកដែលបានចំណាយពេលយ៉ាងហោចណាស់បួនឆ្នាំ

នៅសាលា មិនអាចអាន សរសេរ ឬរាប់បានល្អគ្រប់គ្រាន់ ដើម្បីបំពេញតាមបទដ្ឋានអប្បបរមានៃការរៀនសូត្រឡើយ [xix] ។

៣០. ការផ្តល់ការអប់រំចំនួន១២ឆ្នាំដោយឥតគិតថ្លៃ ផ្តល់ហិរញ្ញវត្ថុពីរដ្ឋ ប្រកបដោយបរិយាប័ន្ន សមភាពសម្រាប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាដែលមានគុណភាព ដែលយ៉ាងហោចណាស់ប្រាំបួនឆ្នាំ[6] ជាកាតព្វកិច្ចដែលនាំឱ្យមានលទ្ធផលសិក្សាពាក់ព័ន្ធ គួរត្រូវបានធានាគ្រប់យ៉ាងដោយគ្មានការរើសអើង។ ការផ្តល់ការអប់រំដោយឥតគិតថ្លៃ រួមមានទាំងការបំបាត់ចោលនៃឧបសគ្គដែលទាក់ទងនឹងការចំណាយក្នុងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាផងដែរ។ សកម្មភាពបន្ទាន់ដែលចំគោលដៅ និងប្រកបដោយចីរភាព គឺផ្តល់ការអប់រំ និងឱកាសបណ្តុះបណ្តាលដែលមានអត្ថន័យសម្រាប់ប្រជាជនភាគច្រើន កុមារ និងក្មេងជំទង់ដែលនៅក្រៅសាលា។

៣១. ពេលបញ្ចប់វដ្តនៃការអប់រំបឋមសិក្សា និងមធ្យមសិក្សាពេញលេញ កុមារទាំងអស់គួរតែទទួលបាននូវកម្រិតជំនាញអក្ខរកម្មជាមូលដ្ឋាន និងជំនាញគិតលេខ ព្រមទាំងសម្រេចបាននូវលទ្ធផលសិក្សាដែលពាក់ព័ន្ធដូចបានកំណត់ដោយវង្វាស់ធៀបទៅនឹងស្តង់ដារកម្មវិធីសិក្សាដែលបង្កើតឡើងជាផ្លូវការ និងរួមបញ្ចូលទាំងចំណេះដឹងគោល ជំនាញបច្ចេកទេស និងជំនាញទន់[7] [xx] ដែលនាំឱ្យកុមារមានការអភិវឌ្ឍសក្តានុពលពេញលេញរបស់ខ្លួន។

៣២. លទ្ធផលនៃការសិក្សាដែលមានប្រសិទ្ធិភាព និងមានភាពពាក់ព័ន្ធ អាចសម្រេចបានតាមរយៈការផ្តល់ធនធានដែលមានគុណភាព និងដំណើរការណែនាំដែលនាំឲ្យអ្នកសិក្សាទាំងអស់ ទទួលបាននូវចំណេះដឹងពាក់ព័ន្ធជំនាញ និងសមត្ថភាព។ សំខាន់ដូចគ្នាដែរនោះ គឺសមាសភាពបែបសមភាព៖ គោលនយោបាយគួរត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហានៃការបែងចែកឱកាសរៀនសូត្រ និងលទ្ធផលនៅតាមតំបន់ គ្រួសារ ក្រុមជនជាតិដើមភាគតិច ឬសង្គមសេដ្ឋកិច្ច និងសំខាន់បំផុតនោះគឺនៅតាមសាលា និងថ្នាក់រៀនចម្រុះ។ ការដោះស្រាយវិសមភាព និងធានាឲ្យបាននូវការអប់រំបរិយាប័ន្ននៅក្នុងការផ្តល់ឲ្យ និងនៅក្នុងការអប់រំប្រកបដោយគុណភាព ទាមទារឱ្យមានការយល់ដឹងយ៉ាងស៊ីជម្រៅនៃការបង្រៀននិងការរៀននៅក្នុងបរិយាកាសសិក្សាមួយដែលត្រូវផ្តល់ទៅឱ្យសិស្ស។ នៅក្នុងបរិបទពហុភាសា តាមតែអាចធ្វើបាន និងចាត់ទុកតថភាពពិតនៃថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សមត្ថភាព គោលនយោបាយ ការបង្រៀន និងរៀនភាសាជាលើកដំបូង ឬភាសាកំណើតគួរត្រូវបានលើកទឹកចិត្តជាចាំបាច់។ ស្ថិតក្នុងការពឹងផ្អែកគ្នាទៅវិញទៅមកលើផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គមដែលកើនឡើងលើសកលលោក គេបានផ្តល់អនុសាសន៍ផងដែរថា ភាសាបរទេសយ៉ាងហោចណាស់គួរត្រូវបានផ្តល់ជូនជាមុខវិជ្ជាមួយសម្រាប់ការសិក្សា។

៣៣. លើសពីនេះទៅទៀត តម្រូវការចាំបាច់សម្រាប់ការយល់ដឹងរួម និងយុទ្ធសាស្ត្រមួយដែលអាចសម្រេចបានក្នុងការវាស់វែងការរៀននៅក្នុងវិធីដែលធានាថាកុមារ និងយុវជនទាំងអស់ដោយមិនគិតពីកាលៈទេសៈរបស់ពួកគេ

6 ប្រាំបួនឆ្នាំដំបូងនៃការអប់រំជាផ្លូវការ ពោល គឺកើនឡើងនៃរយៈពេល ISCED ទី១ និង ២៖ ISCEDទី ១ គឺជាកម្រិតបឋម ជាធម្មតា មានរយៈពេល ៦ឆ្នាំ (បម្រែបម្រួលនៅទូទាំងប្រទេសចាប់ពី ៤ទៅ ៧ឆ្នាំ ) និង ISCED ទី២ គឺកម្រិតអនុវិទ្យាល័យ ជាធម្មតាមានរយៈពេល ៣ឆ្នាំ (ដូចដែលបាននិយាយហើយ គឺមានបម្រែបម្រួល)។ ( UIS ឆ្នាំ ២០១២ ចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃការអប់រំ៖ ISCED ឆ្នាំ 2011៖ www.uis.unesco.org/Education/Documents/ isced - 2011- en.pdf )។

7 ត្រូវកត់សម្គាល់ថា មានការជជែកពិភាក្សាគ្នាជុំវិញជំនាញទន់(non-cognitive skills) ដូចនឹងពាក្យផ្សេងទៀត ត្រូវបានប្រើមានដូចជា ជំនាញសម្រាប់សតវត្សទី ២១ ជំនាញទន់ ជំនាញដែលពាក់ព័ន្ធ និងជំនាញផ្ទេរ។ ក្នុងឯកសារនេះការប្រើពាក្យ (non-cognitive skills) រួមបញ្ចូល ជំនាញការត្រិះរិះពិចារណា និងប្រកបដោយភាពច្នៃប្រឌិត ជំនាញទំនាក់ទំនង មានជំនាញទំនាក់ទំនងផ្ទាល់ខ្លួន ជំនាញជាពលរដ្ឋសកល ប្រព័ន្ធផ្សព្វផ្សាយ និងអក្ខរកម្មព័ត៌មានជាដើម។

ទទួលបានគុណភាពមួយគ្រប់គ្រាន់ និងការអប់រំដែលមានភាពពាក់ព័ន្ធរួមមានដូចជាៈ សិទ្ធិមនុស្ស សិល្បៈ និងភាពជាពលរដ្ឋជាដើម។ ការយល់ដឹងបែបនេះអាចត្រូវបានគាស់កកាយតាមរយៈការធ្វើឱ្យប្រសើរឡើងព័ត៌មានទិន្នន័យដែលអាចរកបាន អាចទុកចិត្តបាន មានបច្ចុប្បន្នភាព ទទួលបានតាមការវាយតម្លៃជាបន្តបន្ទាប់នៃដំណើរការរៀន (នៅថ្នាក់រៀន) និងការវាយតម្លៃសរុបនៅកម្រិតផ្សេងៗគ្នា។ ជាចុងក្រោយ គុណភាពក៏តម្រូវឱ្យមានប្រព័ន្ធសម្រាប់គ្រប់គ្រងគ្រូបង្រៀន អភិបាលកិច្ច យន្តការគណនេយ្យភាព និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរឹងមាំ។

## ៣៤. យុទ្ធសាស្ត្រដែលចង្អុលបង្ហាញៈ

- បង្កើតគោលនយោបាយ និងច្បាប់ដែលធានាការអប់រំដោយឥតគិតថ្លៃចំនួន ១២ឆ្នាំផ្តល់មូលនិធិជាសាធារណៈ បែបបរិយាប័ន្ន មានសមភាព គុណភាពអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលយ៉ាងហោចណាស់ប្រាំបួនឆ្នាំជាកាតព្វកិច្ចសម្រាប់កុមារទាំងអស់ដែលនាំឲ្យមានលទ្ធផលសិក្សាដែលពាក់ព័ន្ធសមស្រប។ ប្រទេសនានា គួរបង្កើនចំនួនឆ្នាំនៃការអប់រំដោយឥតគិតថ្លៃ និងជាកាតព្វកិច្ចស្របតាមការដៅទុករបស់ពិភពលោកដោយយកចិត្តទុកដាក់តថភាពថ្នាក់ជាតិផ្សេងៗ សមត្ថភាព កម្រិតនៃការអភិវឌ្ឍ ការគោរពគោលនយោបាយ និងអាទិភាពជាតិ។
- កំណត់ស្តង់ដារ និងពិនិត្យកម្មវិធីសិក្សា ដើម្បីធានាបាននូវគុណភាព និងភាពពាក់ព័ន្ធទៅនឹងបរិបទនេះរួមទាំងជំនាញសមត្ថភាព គុណតម្លៃ វប្បធម៌ ចំណេះដឹង និងការឆ្លើយតបបញ្ហាយេនឌ័រ។
- ពង្រឹងប្រសិទ្ធិភាព និងប្រសិទ្ធផលនៃស្ថាប័ន ភាពជាអ្នកដឹកនាំរបស់សាលារៀន និងអភិបាលកិច្ចតាមរយៈការចូលរួមកាន់តែច្រើនពីសហគមន៍ រួមទាំងយុវជន និងឪពុកម្តាយក្នុងការគ្រប់គ្រងសាលារៀន។
- បម្រុងទុកធនធានបន្ថែមទៀតប្រកបដោយសមភាពដល់សាលារៀន ដែលមានសេដ្ឋកិច្ចសង្គមល្អក៏ដូចជាសាលារៀនដែលជួបការលំបាកដែរ។
- នៅក្នុងបរិបទពហុភាសាជម្រុញការអប់រំពីរភាសា និងពហុភាសាដោយចាប់ផ្តើមរៀនសូត្រដំបូងនៅក្នុងភាសាកំណើតរបស់ពួកគេ។
- ផ្តល់នូវរបៀបរៀនបែបផ្សេងៗគ្នា និងការអប់រំសម្រាប់កុមារ និងមនុស្សវ័យជំទង់ ដែលមិនបានចូលសាលារៀនទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ហើយដាក់នៅក្នុងកម្មវិធីសមមូលនឹងកម្មវិធីស្ពានចម្លងសម្រាប់ពួកគេ ដែលទទួលស្គាល់ និងឲ្យតម្លៃដោយរដ្ឋដើម្បីធានាការរៀនសូត្រអាចបត់បែនបានទាំងក្នុង និងក្រៅប្រព័ន្ធរួមទាំងនៅក្នុងស្ថានភាពអាសន្នផងដែរ។
- អភិវឌ្ឍន៍ប្រព័ន្ធវាយតម្លៃគ្រប់ជ្រុងជ្រោយឲ្យរឹងមាំជាងមុន ដើម្បីវាយតម្លៃលទ្ធផលនៃការសិក្សានៅចំណុចសំខាន់រួម ទាំងក្នុងអំឡុងពេល ទាំងនៅចុងបញ្ចប់នៃការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិដែលជាការឆ្លុះបញ្ចាំងពីការយល់ដឹងទាំងជំនាញបច្ចេកទេស និងជំនាញទន់។ ទាំងនេះគួររួមបញ្ចូលទាំងការវាយតម្លៃនៃជំនាញមូលដ្ឋានក្នុងការអាន ការសរសេរ និងការគិតលេខ ក៏ដូចជាជំនាញទន់។ ដាក់បញ្ចូលការវាយតម្លៃលើដំណើរការជាផ្នែករួមមួយនៃដំណើរការបង្រៀន និងការរៀន នៅគ្រប់កម្រិតទាំងអស់ជាមួយនឹងតំណភ្ជាប់ដោយផ្ទាល់ទៅនឹងគរុកោសល្យ។

**គោលដៅ ៤.២៖** ត្រឹមឆ្នាំ ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ ទទួលបានការអប់រំកម្រិតមត្តេយ្យ ការថែរក្សា ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតបឋមសិក្សា។

៣៥. ចាប់ផ្តើមតាំងពីកំណើតមក ការថែទាំ និងការអប់រំកុមារតូច (ECCE) បានទុកជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍយូរអង្វែងសុខុមាលភាព និងសុខភាពរបស់កុមារ។ ការថែទាំ និងការអប់រំកុមារតូចកសាងនូវសមត្ថភាព និងជំនាញដែលអនុញ្ញាតឱ្យបុគ្គលនោះ ដើម្បីរៀនសូត្រពេញមួយជីវិត និងរៀនសូត្រពីជីវភាពរស់នៅរបស់ពួកគេ។ ការវិនិយោគលើកុមារតូច ជាពិសេសអ្នកដែលមកពីក្រុមដែលងាយរងគ្រោះ មានផលប៉ះពាល់រយៈពេលវែងយ៉ាងខ្លាំងទៅលើលទ្ធផលនៃការអភិវឌ្ឍ និងការអប់រំ [xxi] ។ ការថែទាំ និងការអប់រំកុមារតូច ធ្វើអោយយើងអាចកំណត់អត្តសញ្ញាណជាបឋមនៃពិការភាព និងកុមារដែលមានហានិភ័យនៃពិការភាព ដែលឲ្យឪពុកម្តាយ អ្នកផ្តល់សេវាថែទាំសុខភាព និងអ្នកអប់រំរៀបចំផែនការល្អប្រសើរជាងមុន សម្រាប់ការអភិវឌ្ឍ និងអន្តរាគមន៍ទាន់ពេលវេលា ក្នុងការដោះស្រាយសេចក្តីត្រូវការរបស់កុមារពិការ កាត់បន្ថយការលូតលាស់ប្រាជ្ញាយឺត ការកែលម្អលទ្ធផលការរៀន បរិយាប័ន្ន និងបង្ការភាពងាយរងគ្រោះ។ ចាប់តាំងពីឆ្នាំ ២០០០ ការចុះឈ្មោះចូលរៀនមុនបឋមបានកើនឡើងស្ទើរតែពីរភាគបី នឹងផលធៀបចុះឈ្មោះចូលរៀនសរុប ត្រូវបានព្យាករណ៍ថានឹងកើនឡើងពី ៣៥% ក្នុងឆ្នាំ ២០០០ ដល់ ៥៨% នៅក្នុងឆ្នាំ ២០១៥ [xxii]។ ទោះបីជាមានការរីកចម្រើនយ៉ាងនេះក៏ដោយ កុមារតូចជាច្រើននៅក្នុងពិភពលោកមិនបានទទួលការថែទាំ និងការអប់រំដែលបណ្តាលឲ្យពួកគេមិនអាចអភិវឌ្ឍន៍សក្តានុពលពេញលេញរបស់ពួកគេបានឡើយ។

៣៦. ការថែទាំ និងការអប់រំកុមារតូច រួមបញ្ចូលទាំងសុខភាព និងអាហារូបត្ថម្ភគ្រប់គ្រាន់ដែលជួយជម្រុញពីគ្រួសារ បរិយាកាសសហគមន៍និងសាលារៀន ការការពារពីអំពើហឹង្សា និងការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍនៃការយល់ដឹង ភាសា សង្គម ផ្លូវអារម្មណ៍ និងរាងកាយ។ នេះគឺស្ថិតក្នុងពីរបីឆ្នាំដំបូងនៃជីវិតដែលការអភិវឌ្ឍខួរក្បាលសំខាន់បំផុតបានកើតឡើង ហើយកុមារតូចចាប់ផ្តើមចូលរួមក្នុងការបង្កើតអត្ថន័យដោយខ្លួនឯង និងបរិស្ថានជុំវិញដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ភាពមានសុខភាពល្អ ការថែទាំ សមត្ថភាព និងជាប្រជាពលរដ្ឋដែលមានការរួមចំណែក។ ការថែទាំ និងការអប់រំកុមារតូច ក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្រពេញមួយជីវិត និងការគាំទ្រសុខុមាលភាព ព្រមទាំការរៀបចំការរីកចម្រើនសម្រាប់ការចូលរៀននៅសាលាបឋមសិក្សា ហើយវាជាការផ្លាស់ប្តូរសំខាន់មួយ ដែលត្រូវជាញឹកញាប់អមដោយការបង្កើនការរំពឹងទុកលើអ្វីដែលកុមារគួរដឹង និងអាចធ្វើបាន។ "ការត្រៀមជាស្រេចសម្រាប់សាលាបឋមសិក្សា" សំដៅទៅលើសមិទ្ធិផលនៃការវិវត្តមជ្ឈដ្ឋានរួមមួយដែលមានដូចជា ស្ថានភាពអាហារូបត្ថម្ភគ្រប់គ្រាន់និងសុខភាពល្អ និងភាសាអាយុសមរម្យ ការអភិវឌ្ឍផ្លូវចិត្ត សង្គម និងការយល់ដឹងផ្នែកខួរក្បាល។ ដើម្បីសម្រេចបាន វាជាការសំខាន់ណាស់ដែលគ្រប់កុមារតូចទាំងអស់មានសិទ្ធិចូលរួមក្នុងដំណើរការអភិវឌ្ឍន៍គុណភាពសម្រាប់កុមារតូច ការថែរក្សា និងការអប់រំសម្រាប់មនុស្សគ្រប់វ័យ។ ការផ្តល់យ៉ាងហោចណាស់មួយឆ្នាំដោយមិនគិតថ្លៃ និងជាកាតព្វកិច្ចនូវការអប់រំដែលមានគុណភាពមុនបឋមសិក្សា ត្រូវបានលើកទឹកចិត្ត ដែលនឹងត្រូវបានផ្តល់ឲ្យដោយអ្នកបណ្តុះបណ្តាលអប់រំល្អ។ នេះ គួរតែត្រូវបានពិចារណាទៅលើតថភាពសង្គមជាក់ស្តែង សមត្ថភាព កម្រិតនៃការអភិវឌ្ឍធនធានផ្សេងគ្នា

និងហេដ្ឋារចនាសម្ព័ន្ធ។ លើសពីនេះទៀត វាជាការសំខាន់ណាស់ដែលថាការអភិវឌ្ឍ និងការរៀនសូត្ររបស់កុមារតូច ត្រូវបានតាមដានត្រួតពិនិត្យពីដំណាក់កាលដំបូងទាំងកម្រិតបុគ្គល និងប្រព័ន្ធ។ ជាការសំខាន់ផងដែរថា សាលារៀន ត្រៀមខ្លួនជាស្រេចសម្រាប់កុមារតូច និងអាចផ្តល់ឱកាសក្នុងការបង្រៀន និងការរៀនសមស្របទៅនឹងការអភិវឌ្ឍរបស់កុមារតូច ដែលជាផលប្រយោជន៍យ៉ាងសំខាន់បំផុតសម្រាប់កុមារ។

៣៧. **យុទ្ធសាស្ត្រដែលចង្អុលបង្ហាញ៖**

- ត្រូវមានគោលនយោបាយសមាហរណកម្មបរិយាប័ន្ន និងបទបញ្ញត្តិដែលធានានូវការផ្តល់ការអប់រំមានគុណភាពយ៉ាងហោចណាស់មួយឆ្នាំដោយមិនគិតថ្លៃ និងជាកាតព្វកិច្ចសម្រាប់ការអប់រំមុនបឋមសិក្សាផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់កុមារតូចក្រីក្រ និងជួបការលំបាកខ្លាំងបំផុតតាមរយៈសេវាការថែទាំ និងអប់រំកុមារតូច។ នេះរួមបញ្ចូលទាំងការវាយតម្លៃនៃគោលនយោបាយ និងកម្មវិធីអប់រំកុមារតូចក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវគុណភាពរបស់ខ្លួន។
- ត្រូវមានគោលនយោបាយ និងយុទ្ធសាស្ត្រពហុវិស័យលើការថែទាំ និងអប់រំកុមារតូចដែលបានគាំទ្រដោយការសម្របសម្រួល ក្នុងចំណោមក្រសួងទទួលខុសត្រូវផ្សេងៗ សម្រាប់អាហារូបត្ថម្ភ សុខភាព កិច្ចគាំពារសង្គម ការការពារកុមារ ទឹក/អនាម័យ យុត្តិធម៌ ការអប់រំ និងការធានាឲ្យមានធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្ត។
- បង្កើតគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ សម្រាប់បណ្តុះបណ្តាលបុគ្គលិកអាជីពសម្រាប់ការថែទាំ និងអប់រំកុមារតូចដោយពង្រឹង និងត្រួតពិនិត្យនូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈនៃស្ថានភាពរបស់ពួកគេ និងលក្ខខណ្ឌការងារ។
- រៀបគម្រោង និងអនុវត្តកម្មវិធីអប់រំបរិយាប័ន្ន ដែលអាចទទួលបានព្រមទាំងសមាហរណកម្មសេវា និងហេដ្ឋារចនាសម្ព័ន្ធ ដែលមានគុណភាពសម្រាប់កុមារតូច ផ្តោតលើសុខភាព អាហារូបត្ថម្ភ ការការពារ និងតម្រូវការអប់រំជាពិសេស សម្រាប់កុមារពិការ ហើយគាំទ្រក្រុមគ្រួសារជាអ្នកមើលថែទាំទីមួយរបស់កុមារ។

***ចំណាំ៖ ខណៈពេលដែលចំណុចដៅ ៤.៣ និង ៤.៤ ត្រូវបានពិភាក្សាដាច់ដោយឡែកពីគ្នា វាគួរតែត្រូវបានកត់សម្គាល់ថា ពួកគេត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។***

**ចំណុចដៅ ៤.៣**: ត្រឹមឆ្នាំ ២០៣០ ធានាបាននូវការទទួលបានស្មើគ្នា ទាំងបុរស និងស្ត្រីទាំងអស់ ដើម្បីការអប់រំបច្ចេកទេស, វិជ្ជាជីវៈ, ឧត្តមសិក្សាប្រកបដោយគុណភាព រួមទាំងសកលវិទ្យាល័យផងដែរ។

៣៨. ឱកាសសម្រាប់ទទួលបានការអប់រំកម្រិតខ្ពស់ ជាញឹកញាប់មិនទាន់គ្រប់គ្រាន់នៅឡើយ ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍតិច ហើយជាលទ្ធផលឃើញថាមានគម្លាតចំណេះដឹង មានផលវិបាកធ្ងន់ធ្ងរដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចទាំងមូល។ ដូច្នេះ វាគឺជាការចាំបាច់ ដើម្បីកាត់បន្ថយឧបសគ្គដល់ការអភិវឌ្ឍជំនាញការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការបណ្តុះបណ្តាល (TVET) ដោយចាប់ផ្តើមពីកម្រិតមធ្យមសិក្សា ព្រមទាំងឧត្តមសិក្សារួមមាននៅកម្រិតសាកលវិទ្យាល័យ និងដើម្បីផ្តល់ឱកាសឲ្យការរៀនសូត្រពេញមួយជីវិតសម្រាប់យុវជន និងមនុស្សពេញវ័យ។

៣៩. ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការបណ្តុះបណ្តាល (TVET) ត្រូវបានផ្តល់ជូននៅកម្រិតផ្សេងគ្នានៃការអប់រំ។ នៅឆ្នាំ ២០១៣ TVET បានជួយសម្រួលដល់ការចុះឈ្មោះចូលរៀនមកម្រិតទុតិយភូមិប្រហែល ២៣%។ ប្រទេសមួយចំនួនបានចាត់វិធានការ ដើម្បីពង្រីកការអប់រំវិជ្ជាជីវៈដល់កម្រិតថ្នាក់ឧត្តមសិក្សា (ISCED កម្រិត ៥)។

៤០. ការអប់រំកម្រិតឧត្តមសិក្សានៅគ្រប់ទម្រង់ទាំងអស់[8] ត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ជាមួយនឹងការចុះឈ្មោះចូលរៀនសរុបចំនួនកើនឡើងពី ១០០លាននាក់ក្នុងឆ្នាំ ២០០០ ដល់ ១៩៩លាននាក់នៅឆ្នាំ ២០១៣ [xxiii]។ ប៉ុន្តែភាពខុសគ្នាក្នុងការទទួលបានការអប់រំថ្នាក់ឧត្តមសិក្សា ជាពិសេសនៅថ្នាក់សាកលវិទ្យាល័យទាក់ទងទៅនឹងយេនឌ័រ ស្ថានភាពជនជាតិដើមភាគតិច សាសនា សង្គមរស់នៅ អាយុ និងជនពិការនៅតែមានច្រើននៅឡើយ។ គុណវិបត្តិសម្រាប់ស្ត្រីកើតមានឡើងពិសេសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងសម្រាប់បុរសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

៤១. លើសពីការផ្តល់ជំនាញការងារ ការអប់រំថ្នាក់ឧត្តមសិក្សា និងសាកលវិទ្យាល័យដើរតួនាទីយ៉ាងសំខាន់ក្នុងការជាស់តឿនដល់ការត្រិះរិះពិចារណា ការច្នៃប្រឌិត ការបង្កើត និងផ្សព្វផ្សាយចំណេះដឹងនៃការអភិវឌ្ឍសង្គម វប្បធម៌ និងសេដ្ឋកិច្ច។ ការអប់រំថ្នាក់ឧត្តមសិក្សា និងសាកលវិទ្យាល័យ គឺសំខាន់សម្រាប់វិស័យអប់រំ អ្នកវិទ្យាសាស្ត្រ អ្នកជំនាញ និងអ្នកដឹកនាំនាពេលអនាគត។ តាមរយៈមុខងារនៃការស្រាវជ្រាវ ពួកគេដើរតួនាទីជាមូលដ្ឋានក្នុងការបង្កើតចំណេះដឹង និងការពង្រឹងការអភិវឌ្ឍនៃសមត្ថភាពច្នៃប្រឌិត និងការវិភាគ ដែលអនុញ្ញាតឲ្យរកបាននូវដំណោះស្រាយសម្រាប់បញ្ហាក្នុងតំបន់ និងពិភពលោកក្នុងគ្រប់វិស័យទាំងអស់នៃការអភិវឌ្ឍដោយចីរភាព។

៤២. និន្នាការមួយទៀត គឺជាការចល័តដែលមានការកើនឡើងរបស់បុគ្គលិក អ្នកសិក្សា និងលំហូរនៃសិស្សនិស្សិតផ្លាស់ប្តូរពីបរទេស ដើម្បីបង្កើនកម្រិតនៃការសិក្សារបស់ពួកគេ។ ជាលទ្ធផល ការប្រៀបធៀបការទទួលស្គាល់ និងធានាគុណភាពនៃសមត្ថភាព បានក្លាយទៅជាក្តីកង្វល់កាន់តែកើនឡើង ជាពិសេសនៅក្នុងប្រទេសដែលមានប្រព័ន្ធរដ្ឋបាលទន់ខ្សោយ។ ជាមួយគ្នានេះដែរ ការចល័តនៅក្នុងវិស័យអប់រំឧត្តមសិក្សា គឺជាទ្រព្យសម្បត្តិ និងជាឱកាសមួយដែល និងគួរតែត្រូវបានធ្វើឲ្យប្រសើរឡើងក្នុងការអភិវឌ្ឍសមត្ថភាពរបស់សិស្ស និងការប្រកួតប្រជែងជាសកល។

៤៣. ការបង្កើតប្រព័ន្ធអប់រំឧត្តមសិក្សាឲ្យបានត្រឹមត្រូវមួយ ដែលបានគាំទ្រដោយបច្ចេកវិទ្យា និងការបើកចំហធនធានអប់រំ ព្រមទាំងការអប់រំពីចម្ងាយ អាចបង្កើននូវការទទួលបាននូវការអប់រំ សមត្ថភាព គុណភាព ដែល និងភាពពាក់ព័ន្ធ នឹងអាចកាត់បន្ថយគម្លាតរវាងអ្វីដែលត្រូវបានបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា រួមទាំងសាកលវិទ្យាល័យទៅនឹងអ្វីដែលសេដ្ឋកិច្ចនិងសង្គមត្រូវការ។ ការផ្តល់ការអប់រំថ្នាក់ឧត្តមសិក្សា គួរតែត្រូវបានធ្វើឡើងដោយឥតគិតថ្លៃស្របតាមកិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់។

---

8 ការសិក្សាកម្រិតឧត្តម បានកសាងនៅលើមធ្យមសិក្សា ដែលបានផ្តល់នូវសកម្មភាពសិក្សានៅក្នុងឯកទេសផ្សេងៗ។ វា មានបំណងក្នុងការរៀននៅកម្រិតខ្ពស់ដែលមានភាពស្មុគស្មាញ និងជំនាញ។ ការអប់រំកម្រិតឧត្តមសិក្សា រួមបញ្ចូលអ្វីដែល ត្រូវបានគេយល់ថា ជាទូទៅថា ការសិក្សាអប់រំ ហើយថែមទាំងមាន វិជ្ជាជីវៈកម្រិតខ្ពស់ការអប់រំជំនាញវិជ្ជាជីវៈ។ វាមាននៅក្នុងកម្រិត ISCED ៥ ( វដ្តខ្លីនៃការសិក្សាកម្រិតឧត្តម) ៦(ថ្នាក់បរិញ្ញាបត្រ ឬសមមូល) ៧(បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ) និង ៨ (ថ្នាក់បណ្ឌិត ឬសមមូល )។ មាតិកានៃកម្មវិធីកម្រិត ឧត្តមសិក្សា គឺមានកម្រិតស្មុគស្មាញ និងខ្ពស់ជាងនៅកម្រិតទាប។ ( UIS ឆ្នាំ ២០១២ ចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃការអប់រំ។ ISCED ឆ្នាំ ២០១១ ឯកសារ៖ www.uis.unesco.org/Education/ / isced - 2011- en.pdf)

៤៤. ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការបណ្តុះបណ្តាលព្រមទាំងការអប់រំថ្នាក់ឧត្តមសិក្សា មានដូចជាសាកលវិទ្យាល័យ ព្រមទាំងការរៀនសូត្រសម្រាប់មនុស្សពេញវ័យ អប់រំ និងបណ្តុះបណ្តាល គឺជាធាតុសំខាន់មួយនៃការសិក្សាពេញមួយជីវិត។ ការលើកកម្ពស់ការសិក្សាពេញមួយជីវិត តម្រូវឱ្យមានវិធីសាស្ត្រក្នុងវិស័យទាំងមូល ដែលរួមទាំងការរៀនសូត្របែបផ្លូវការ មិនផ្លូវការ និងក្រៅប្រព័ន្ធ សម្រាប់មនុស្សគ្រប់វ័យ ជាពិសេសចំពោះការរៀនសូត្ររបស់មនុស្សពេញវ័យ ឱកាសបណ្តុះបណ្តាល និងការអប់រំ។ វាជាការចាំបាច់ដើម្បីផ្តល់នូវឱកាសសម្រាប់ការទទួលបានការអប់រំសមធម៌ដល់សាកលវិទ្យាល័យ សម្រាប់មនុស្សចាស់ដោយយកចិត្តទុកដាក់ជាពិសេសដល់ក្រុមដែលងាយរងគ្រោះ។

៤៥. **យុទ្ធសាស្ត្រដែលចង្អុលបង្ហាញ៖**

- អភិវឌ្ឍន៍គោលនយោបាយអន្តរវិស័យ សម្រាប់ការអភិវឌ្ឍនូវជំនាញ សម្រាប់និងរវាង វិជ្ជាជីវៈ TVET និងការអប់រំថ្នាក់ឧត្តមសិក្សា ពង្រឹងទំនាក់ទំនងរវាងវិទ្យាសាស្ត្រ និងការអភិវឌ្ឍគោលនយោបាយ ដើម្បីរក្សាល្បឿនការផ្លាស់ប្តូរតាមបរិបទ និងកសាងភាពជាដៃគូដែលមានប្រសិទ្ធភាព ជាពិសេសរវាងវិស័យសាធារណៈ និងឯកជន រួមទាំងនិយោជក និងសហជីពក្នុងការអនុវត្តរបស់ពួកគេ។
- ធានាបាននូវការធានាគុណភាព ការប្រៀបធៀប និងការទទួលស្គាល់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃការអប់រំថ្នាក់ឧត្តមសិក្សា និងជួយសម្រួលដល់ការផ្ទេរឥណទានរវាងគ្រឹះស្ថានឧត្តមសិក្សាដែលគេទទួលស្គាល់។
- អភិវឌ្ឍគោលនយោបាយ និងកម្មវិធីសម្រាប់ការផ្តល់ការសិក្សាពីចម្ងាយដែលមានគុណភាពក្នុងវិស័យអប់រំថ្នាក់ឧត្តមសិក្សាជាមួយនឹងការផ្តល់ហិរញ្ញប្បទាន ការប្រើប្រាស់បច្ចេកវិទ្យាសមស្របដែលរួមមានអ៊ីនធឺណិត វគ្គសិក្សាដោយបើកចំហតាមបណ្តាញអ៊ីនធឺណិត និងបែបបទផ្សេងទៀតដែលបំពេញតាមបទដ្ឋានដែលមានគុណភាពអាចទទួលយកបាន ដើម្បីកែលម្អដល់ការទទួលបានការអប់រំ។
- អភិវឌ្ឍគោលនយោបាយ និងកម្មវិធីដែលពង្រឹងមុខងារស្រាវជ្រាវនៅក្នុងវិស័យឧត្តមសិក្សា និងសាកលវិទ្យាល័យតាមរយៈការទទួលការចូលរៀនលឿនផ្នែក STEM ជាពិសេសចំពោះកុមារី និងស្ត្រី។
- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការអភិវឌ្ឍកម្មវិធីអប់រំឧត្តមសិក្សា និងសាកលវិទ្យាល័យ និងស្រាវជ្រាវរួមទាំងក្នុងក្របខ័ណ្ឌនៃមហាសន្និបាតពិភពលោក និងតំបន់ស្តីពីការទទួលស្គាល់លក្ខណៈសម្បត្តិការអប់រំថ្នាក់ឧត្តមសិក្សា ដើម្បីគាំទ្រដល់ការកើនឡើងនៃការទទួលបានការអប់រំ និងការធានាគុណភាពល្អប្រសើរជាងមុន ព្រមទាំងការអភិវឌ្ឍសមត្ថភាព។
- លើកកម្ពស់ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងការបណ្តុះបណ្តាលការអប់រំថ្នាក់ឧត្តមសិក្សា និងសាកលវិទ្យាល័យ ព្រមទាំងការរៀនសូត្រសម្រាប់មនុស្សពេញវ័យ ការអប់រំ និងឱកាសបណ្តុះបណ្តាសម្រាប់មនុស្សវ័យក្មេង និងមនុស្សគ្រប់វ័យ ដែលមានប្រវត្តិ វប្បធម៌ សង្គមផ្សេងៗគ្នា ដូច្នេះដើម្បីអាចឱ្យពួកគេបន្តធ្វើឱ្យប្រសើរឡើង និងការសម្របជំនាញរបស់ខ្លួនដោយមានការយកចិត្តទុកដាក់ជាពិសេសដល់សមភាពយេនឌ័រ រួមមានការលុបបំបាត់ឧបសគ្គយេនឌ័រ និងក្រុមងាយរងគ្រោះដូចជាអ្នកដែលមានភាពពិការជាដើម។
- ស្ថាប័នឧត្តមសិក្សារួមទាំងសាកលវិទ្យាល័យគួរគាំទ្រ និងជម្រុញការអភិវឌ្ឍគោលនយោបាយ និងការផ្តល់ឱកាសរៀនសូត្រពេញមួយជីវិតប្រកបដោយគុណភាព និងសមភាព។

**ចំណុចដៅ ៤.៤៖** ត្រឹមឆ្នាំ ២០៣០ បង្កើនឲ្យបានច្រើននូវចំនួនយុវជន និងមនុស្សពេញវ័យដែលមានជំនាញពាក់ព័ន្ធរួមមាន ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឱកាសទទួលបានការងារ ការងារសមរម្យ និងសហគ្រិនភាព។

៤៦. ដែលឆ្លុះបញ្ចាំងទៅនឹងប្រវត្តិនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃទីផ្សារការងារ ការកើនឡើងអត្រាគ្មានការងារធ្វើជាពិសេសក្នុងចំណោមយុវជន ដែលមានអាយុមានកម្លាំងពលកម្មខ្លាំងនៅក្នុងប្រទេសមួយចំនួន ការធ្វើចំណាកស្រុក និងការរីកចម្រើនបច្ចេកវិទ្យាប្រទេសទាំងអស់ កំពុងប្រឈមមុខនឹងតម្រូវការធ្វើការអភិវឌ្ឍចំណេះដឹង ជំនាញ និងសមត្ថភាពរបស់មនុស្សសម្រាប់ការងារសមរម្យ ភាពជាសហគ្រិន និងជីវិត [xxiv]។ នៅក្នុងប្រទេសជាច្រើន គោលនយោបាយអប់រំ និងបណ្តុះបណ្តាល ត្រូវបានគេរំពឹងថានឹងមានការផ្លាស់ប្តូរតម្រូវការយ៉ាងឆាប់រហ័សសម្រាប់យុវជន និងមនុស្សពេញវ័យ ដើម្បីបង្កើនជំនាញរបស់ពួកគេ និងរៀននូវអ្វីដែលថ្មីផងដែរ។ ហេតុដូច្នេះ វាជាការចាំបាច់ដើម្បីបង្កើន និងធ្វើឲ្យឱកាសរៀនសូត្រមានភាពសម្បូរបែប ការប្រើគំរូនៃការបណ្តុះបណ្តាលទូលំទូលាយ ដូច្នេះយុវជន និងមនុស្សពេញវ័យជាពិសេសក្មេងស្រី និងស្ត្រីអាចទទួលបាននូវចំណេះដឹងពាក់ព័ន្ធ ជំនាញ និងសមត្ថភាពសម្រាប់ការងារ និងជីវិតសមរម្យ។

៤៧. ការទទួលបានប្រកបដោយសមភាពលើ TVET តម្រូវឱ្យមានការពង្រីកបន្ថែម ខណៈពេលគុណភាព ត្រូវបានធានាយ៉ាងច្បាស់លាស់។ យុទ្ធសាស្ត្រ និងអាទិភាពសមស្រប ត្រូវការអភិវឌ្ឍដើម្បីភ្ជាប់ទំនាក់ទំនងល្អជាងមុនជាមួយ TVET ទៅនឹងពិភពការងារទាំងក្នុងវិស័យការងារផ្លូវការ និងក្រៅផ្លូវការ ដើម្បីកែលម្អស្ថានភាពរបស់ខ្លួនក្នុងការកសាងផ្លូវរៀនសូត្ររវាងវិស័យអប់រំផ្សេងៗគ្នា និងដើម្បីជួយសម្រួលដល់ការផ្លាស់ប្តូរសាលារៀន និងការងារ។ ប្រព័ន្ធ TVET ត្រូវទទួលស្គាល់ និងឲ្យតម្លៃដល់ជំនាញដែលចាំបាច់ តាមរយៈបទពិសោធន៍ ឬនៅក្នុងបរិបទមិនផ្លូវការ និងក្រៅប្រព័ន្ធ មានដូចជានៅកន្លែងធ្វើការ និងតាមរយៈអ៊ីនធឺណិត។

៤៨. ការផ្តោតអារម្មណ៍ខ្លាំងលើជំនាញការងារជាក់លាក់ កាត់បន្ថយសមត្ថភាពរបស់និស្សិតបញ្ចប់ការសិក្សា ដើម្បីសម្របខ្លួនទៅនឹងតម្រូវការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃទីផ្សារការងារ។ ហេតុនេះហើយ ក្រៅពីមានជំនាញការងារជាក់លាក់ ការផ្តោតសំខាន់ ត្រូវតែដាក់នៅលើការអភិវឌ្ឍជំនាញកម្រិតខ្ពស់ និងជំនាញផ្ទេរ [xxv] មានដូចជាការដោះស្រាយបញ្ហា ការត្រិះរិះពិចារណា គំនិតច្នៃប្រឌិត ការងារជាក្រុមជំនាញក្នុងការទំនាក់ទំនង និងការដោះស្រាយជម្លោះ ដែលអាចត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយទៅលើការងារយ៉ាងច្រើន។ លើសពីនេះទៅទៀត អ្នកសិក្សាគួរតែត្រូវបានផ្តល់ឱកាសដើម្បីធ្វើបច្ចុប្បន្នភាពលើជំនាញរបស់ពួកគេតាមរយៈការសិក្សាពេញមួយជីវិតជាបន្តបន្ទាប់។

៤៩. វាជាការសំខាន់ ដើម្បីវាយតម្លៃពីផលជះ និងលទ្ធផលនៃគោលនយោបាយ កម្មវិធីអប់រំ TVET និងដើម្បីប្រមូលទិន្នន័យនៅលើការផ្លាស់ប្តូរពីការរៀនទៅពិភពការងារ និងនៅលើភាពទទួលបានការងាររបស់និស្សិតបញ្ចប់ការសិក្សា ដោយយកចិត្តទុកដាក់ទៅលើភាពផ្សេងគ្នា។

៥០. **យុទ្ធសាស្ត្រដែលចង្អុលបង្ហាញ៖**

- ប្រមូល និងប្រើភស្តុតាងអំពីការផ្លាស់ប្តូរតម្រូវការជំនាញ ដើម្បីណែនាំការអភិវឌ្ឍជំនាញកាត់បន្ថយភាពផ្សេងគ្នា និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរទីផ្សារការងារ និងតម្រូវការរបស់សង្គម បរិបទក៏ដូចជាតម្រូវការនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងការអភិវឌ្ឍជនបទ។
- ទាក់ទាញឲ្យមានការចូលរួមពីដៃគូសង្គមក្នុងការបង្កើត និងការផ្តល់កម្មវិធីអប់រំ បណ្តុះបណ្តាលដែលជាភស្តុតាងបែបមូលដ្ឋាន និងមានលក្ខណៈរួម។ ធានាឱ្យបាននូវកម្មវិធី TVET និងកម្មវិធីបណ្តុះបណ្តាលដែលមានគុណភាពខ្ពស់ និងបញ្ចូលទាំងជំនាញដែលទាក់ទងនឹងការងារ និងជំនាញដែលមិនទាក់ទងនឹងការគិត/ជំនាញផ្ទេរ មានដូចជា ជំនាញជាសហគ្រិនមូលដ្ឋាន និងជំនាញ ICT ហើយអ្នកដឹកនាំស្ថាប័ន TVET និងបុគ្គលិកបង្រៀន រួមទាំងគ្រូបណ្តុះបណ្តាល និងក្រុមហ៊ុន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងជំនាញច្បាស់លាស់។
- ជម្រុញការអភិវឌ្ឍទម្រង់ផ្សេងៗគ្នានៃការបណ្តុះបណ្តាលដែលមានមូលដ្ឋានបែបការងារ ថ្នាក់រៀន និងការរៀនសូត្រនៅកន្លែងដែលសមស្រប។
- ធានានូវប្រព័ន្ធធានាគុណភាព TVET ដែលមានប្រសិទ្ធិភាព តម្លាភាព និងអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិ។
- លើកកម្ពស់កិច្ចសហការគ្នាលើការបង្កើនតម្លាភាព និងការទទួលស្គាល់ទូលំទូលាយនៃក្របខណ្ឌគុណវុឌ្ឍិរបស់ TVET ដើម្បីលើកកម្ពស់គុណភាពនៃកម្មវិធី TVET និងចល័តភាពរបស់កម្មករ និងអ្នកសិក្សា ដើម្បីធានាថាកម្មវិធី TVET រក្សាល្បឿនការផ្លាស់ប្តូរតម្រូវការទីផ្សារការងារបានត្រឹមត្រូវ។
- លើកកម្ពស់របៀបរៀនសូត្រដែលអាចបត់បែនបានទាំងនៅក្នុងបរិបទជាផ្លូវការ និងមិនផ្លូវការអនុញ្ញាតឱ្យអ្នកសិក្សាអាចប្រមូល និងផ្ទេរឥណទានសម្រាប់កម្រិតនៃសមិទ្ធផលដែលទទួលបានការទទួលស្គាល់ ធ្វើឱ្យមានសុពលភាព និងការទទួលស្គាល់ការរៀនសូត្រជាអាទិភាព និងបង្កើតកម្មវិធីស្ពានចម្លង និងសេវាកម្មណែនាំពីការងារ និងសេវាប្រឹក្សាយោបល់។

**ចំណុចដៅ ៤.៥៖** ត្រឹមឆ្នាំ២០៣០ លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាឱ្យបាននូវភាពស្មើគ្នាក្នុងការចូលរៀនគ្រប់កម្រិតទាំងអស់នៃការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនងាយរងគ្រោះ រួមទាំងជនពិការ ជនជាតិដើមភាគតិច និងកុមារនៅក្នុងស្ថានភាពងាយរងគ្រោះ។

៥១. ទោះបីជាមានភាពរីកចម្រើននៃការចុះឈ្មោះ កុមារា និងកុមារីជាច្រើននៅក្នុងសាលាបឋមសិក្សា មិនមានការយកចិត្តទុក ដាក់គ្រប់គ្រាន់ទៅលើការលុបបំបាត់វិសមភាពនៅក្នុងការអប់រំនៅគ្រប់កម្រិត ឧទាហរណ៍៖ កុមារដែលមកពីគ្រួសារក្រីក្រជាងគេបំផុតមានចំនួន ២០% នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមមិនបានបញ្ចប់សាលាបឋមសិក្សាពេញលេញឡើយ គឺច្រើនជាង៥ដងនៃក្មេងមកពីប្រទេសអភិវឌ្ឍបំផុតចំនួន ២០% នៅក្នុងអំឡុងឆ្នាំ ២០០៩ [xxvi]។ លើសពីនេះទៅទៀត ភាពក្រីក្រធ្វើឲ្យការផាត់ចេញកាន់តែធ្ងន់ធ្ងរ ឧទាហរណ៍ដូចជាការពង្រីកគម្លាតយេនឌ័រ។

៥២. ការយកចិត្តទុកដាក់លើភាពក្រីក្រត្រូវតែនៅជាអាទិភាពមួយ ព្រោះភាពក្រីក្រនៅតែជាឧបសគ្គធំបំផុតដើម្បីដាក់រួមបញ្ចូលគ្នានៅគ្រប់កម្រិត និងនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ការវិនិយោគនៅក្នុងវិស័យអប់រំអាចបន្ថយគម្លាតនៃប្រាក់ចំណូល និងកម្មវិធីអប់រំជាច្រើនបានរកឃើញមធ្យោបាយថ្មី ដើម្បីជួយដល់ក្រុមគ្រួសារ និងអ្នកសិក្សាក្នុងការយកឈ្នះឧបសគ្គហិរញ្ញវត្ថុក្នុងការអប់រំ។ វិធីសាស្ត្រនេះត្រូវបានធ្វើវិនិយោគ និងពង្រីក។

៥៣. ដើម្បីសម្រេចបាននូវការអប់រំបរិយាប័ន្ន គោលនយោបាយ គួរតែមានគោលបំណង ដើម្បីផ្លាស់ប្តូរប្រព័ន្ធអប់រំដូច្នេះ ពួកគេអាចឆ្លើយតបបានល្អប្រសើរជាងមុនទៅនឹងតម្រូវការ និងភាពចម្រុះគ្នារបស់អ្នកសិក្សា។ នេះគឺជាការសំខាន់ក្នុងការបំពេញនូវសិទ្ធិទទួលបានការអប់រំដោយសមភាព ហើយវាទាក់ទងមិនត្រឹមតែការទទួលបានការចូលរៀនទេហើយថែមទាំងបានចូលរួម និងសមិទ្ធិផលរបស់សិស្សទាំងអស់ ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសដល់អ្នកដែលត្រូវបានផាត់ចេញងាយរងគ្រោះ ឬមានហានិភ័យនៃការបាត់បង់ឱកាសដែលមានលំអិតនៅក្នុងកថាខណ្ឌទី៥។

៥៤. វិសមភាពយេនឌ័រ ជាការព្រួយបារម្ភយ៉ាងខ្លាំង។ មានតែប្រទេស៦៩%ប៉ុណ្ណោះ ត្រូវបានគេព្យាករណ៍ថានឹងសម្រេចបាននូវយេនឌ័រនៅក្នុងការទទួលបានការអប់រំនៅកម្រិតបឋមសិក្សា ការចុះឈ្មោះចូលរៀនចំនួនស្មើគ្នានៃក្មេងស្រី និងក្មេងប្រុសក្នុងឆ្នាំ ២០១៥ និង ៤៨%នៅក្នុងកម្រិតមធ្យមសិក្សា [xxvii]។ លើសពីនេះទៅទៀតខណៈពេលដែលភាពស្មើគ្នាផ្នែកយេនឌ័រ មានប្រយោជន៍ក្នុងការវាស់វែងនៃភាពរីកចម្រើនការខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវការធានាឱ្យមានសមភាពយេនឌ័រ។ សមភាព គឺជាគោលដៅមានមហិច្ឆតាបន្ថែមទៀត៖ វាមានន័យថាកុមារី និងកុមារា ទាំងស្ត្រី និងបុរសទាំងអស់ មានឱកាសស្មើគ្នាដើម្បីរីករាយជាមួយការអប់រំគុណភាពខ្ពស់ ទទួលបាននៅកម្រិតស្មើគ្នា ហើយទទួលបានអត្ថប្រយោជន៍ស្មើគ្នាពីការអប់រំ។ កុមារីវ័យជំទង់ និងស្ត្រីវ័យក្មេងដែលអាចជាកម្មវត្ថុទៅនឹងអំពើហឹង្សាយេនឌ័រ អាពាហ៍ពិពាហ៍កុមារ ការមានផ្ទៃពោះទាំងវ័យក្មេង និងការធ្វើការងារផ្ទះធ្ងន់ពេក ក៏ដូចជាអ្នកដែលរស់នៅក្នុងតំបន់ជនបទក្រីក្រ តម្រូវឱ្យមានការយកចិត្តទុកដាក់ពិសេស។ វាមានបរិបទជាច្រើន ដែលក្មេងប្រុសជួបការលំបាកផងដែរ។ ឧទាហរណ៍៖ នៅក្នុងតំបន់មួយចំនួន ការចុះឈ្មោះចូលរៀនរបស់ក្មេងប្រុសនៅកម្រិតមធ្យម និងឧត្តមសិក្សា គឺមានតិចជាងក្មេងស្រី។ វិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ ជាញឹកញាប់ឆ្លុះបញ្ចាំងបរិបទទូទៅ និងការរើសអើងយេនឌ័រនៅក្នុងសង្គមទូលំទូលាយមួយ ដូច្នេះគោលនយោបាយ ដែលមានគោលបំណងសំខាន់ដើម្បីយកឈ្នះលើវិសមភាពបែបនេះ មានប្រសិទ្ធិភាពនៅពេលដែលវាជាផ្នែកនៃកញ្ចប់រួមដែលជម្រុញដល់សុខភាព យុត្តិធម៌ អភិបាលកិច្ចល្អ និងសេរីភាពពីពលកម្មកុមារ។ បរិបទ និងឫសគល់នៃភាពងាយរងគ្រោះ ការរើសអើង និងការផាត់ចេញនៅមានទំហំធំធេងនៅឡើយ។ ក្រុមងាយរងគ្រោះដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស និងយុទ្ធសាស្ត្រចំគោលដៅ មានដូចជាជនពិការ ជនជាតិដើមភាគតិច ជនជាតិភាគតិច និងជនក្រីក្រ។

៥៥. កិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសមត្ថភាព និងការវិនិយោគនឹងត្រូវទាមទារឲ្យមាន ដើម្បីធានានូវការបញ្ជ្រាបយេនឌ័រនៅទូទាំងប្រព័ន្ធអប់រំ និងកម្មវិធីនៅក្នុងការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃរបស់ពួកគេ និងការតាមដាន។ វិធានការពិសេស គួរតែត្រូវបានដាក់នៅកន្លែង ដើម្បីធានាឱ្យបាននូវសន្តិសុខផ្ទាល់ខ្លួនសម្រាប់កុមារី និងស្ត្រីទាំងនៅក្នុង និងនៅលើការធ្វើដំណើរទៅ និងមកពីស្ថាប័នអប់រំ និងដើម្បីលុបបំបាត់អំពើហឹង្សាយេនឌ័រនៅ

ក្នុងសាលា ជាមួយគោលនយោបាយប្រឆាំងគ្រប់ទម្រង់ទាំងអស់នៃអំពើហឹង្សាផ្លូវភេទ យេនឌ័រ និងការយាយីផ្សេងៗ។

៥៦. ឱកាសអប់រំរបស់កុមារជាច្រើន ត្រូវបានបែកខ្ញាត់ខ្ញាយគ្នាដោយជម្លោះ ជំងឺរាតត្បាត និងគ្រោះមហន្តរាយធម្មជាតិ។ កុមារប្រហែល ២១លាននាក់ក្នុងពិភពលោកមិនបានចូលសាលា ឬ ៣៦% រស់នៅក្នុងតំបន់រងគ្រោះដោយសារជម្លោះក្នុងឆ្នាំ ២០១២ ដែលកើនឡើងពី ៣០% នៅក្នុងឆ្នាំ ២០០០ [xxviii]។ វាជាការសំខាន់ណាស់ក្នុងការរក្សាការអប់រំអំឡុងពេលមានស្ថានភាពសង្គ្រោះបន្ទាន់ ជម្លោះ ក្រោយជម្លោះ និងក្រោយគ្រោះមហន្តរាយ និងដោះស្រាយនូវតម្រូវការអប់រំរបស់អ្នកផ្លាស់ទីលំនៅ (IDPs) និងជនភៀសខ្លួន។ បន្ថែមទៅនឹងវិធានការដែលបានស្នើសម្រាប់ធានាថា សមធម៌ បរិយាប័ន្ន និងសមភាពយេនឌ័រ ត្រូវបានបង្កប់នៅក្នុងគោលដៅអប់រំទាំងអស់។ ដូចយុទ្ធសាស្ត្រដែលត្រូវបានស្នើឡើងៈ

៥៧. **យុទ្ធសាស្ត្រដែលចង្អុលបង្ហាញៈ**

- ធានាថាគោលនយោបាយវិស័យអប់រំ ផែនការតាមវិស័យ និងថវិការបស់វា ធានាដល់គោលការណ៍នៃការមិនរើសអើង និងសមភាពនៅក្នុង តាមរយៈការអប់រំ និងការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រចំគោលដៅបន្ទាន់ សម្រាប់ក្រុមដែលងាយរងគ្រោះ និងក្រុមដែលគេផាត់ចេញ។ រៀបចំសូចនាករ ដើម្បីវាស់វែងការរីកចម្រើនឆ្ពោះទៅរកសមភាព។
- ធានាថាគោលនយោបាយវិស័យអប់រំ ផែនការតាមវិស័យ និងការរៀបចំថវិការួមបញ្ចូលការវាយតម្លៃហានិភ័យ ការត្រៀមខ្លួន និងការឆ្លើយតបទៅនឹងស្ថានភាពសង្គ្រោះបន្ទាន់សម្រាប់ការអប់រំ និងគំនិតផ្តួចផ្តើមដែលឆ្លើយតបទៅនឹងតម្រូវការនៃវិស័យអប់រំរបស់កុមារ យុវជន និងមនុស្សពេញវ័យដែលមានរងផលប៉ះពាល់ដោយគ្រោះមហន្តរាយ ជម្លោះ ការរត់ភៀសខ្លួន និងរោគរាតត្បាតដែលរួមទាំងជនផ្លាស់ទីលំនៅ និងជនភៀសខ្លួន។ គាំទ្រយន្តការ និងយុទ្ធសាស្ត្រថ្នាក់អនុតំបន់ និងតំបន់ដែលបំពេញតម្រូវការការអប់រំនៃជនផ្លាស់ទីលំនៅ និងជនភៀសខ្លួន។
- កំណត់ ត្រួតពិនិត្យ និងកែលម្អនូវការទទួលបានការចូលរៀនរបស់កុមារី និងស្ត្រីទៅនឹងការអប់រំដែលមានគុណភាព ក៏ដូចជាកម្រិតនៃការចូលរួម សមិទ្ធិផល និងការបញ្ចប់របស់ពួកគេ។ នៅក្នុងបរិបទដែលកុមារាមានជួបការលំបាកត្រូវធ្វើសកម្មភាពផ្តោតសំខាន់ទៅលើពួកគេ។
- កំណត់ឧបសគ្គដែលធ្វើឲ្យកុមារ និងយុវជនដែលងាយរងគ្រោះចេញពីកម្មវិធីអប់រំដែលមានគុណភាព និងចាត់វិធានការខ្លាំងក្លាក្នុងការលុបបំបាត់ឧបសគ្គទាំងនោះ។
- គាំទ្រវិធីសាស្ត្រទូលំទូលាយ ដើម្បីធ្វើឱ្យសាលាទប់ទល់ទៅនឹងផលប៉ះពាល់ពីគ្រោះមហន្តរាយគ្រប់ទំហំទាំងអស់។ នេះរួមមាន សម្ភារៈបរិក្ខារដែលមានសុវត្ថិភាពរបស់សាលា ការគ្រប់គ្រងគ្រោះមហន្តរាយរបស់សាលារៀន ការកាត់បន្ថយហានិភ័យ និងការអប់រំមានភាពអត់ធន់។
- ផ្តល់នូវការសិក្សាពីចម្ងាយ ការបណ្តុះបណ្តាល ICT ការទទួលបានបច្ចេកវិទ្យាសមស្រប និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីជួយសម្រួលដល់បរិស្ថានដែលរៀននៅផ្ទះ ក្នុងតំបន់មានជម្លោះ និងតំបន់ដាច់ស្រយាល ជាពិសេសសម្រាប់ក្មេងស្រី ស្ត្រី ក្មេងប្រុសដែលងាយរងគ្រោះ យុវជន និងក្រុមបាត់បង់ឱកាសដ៏ទៃទៀត។
- ធានាបាននូវការពិនិត្យឡើងវិញ របស់រដ្ឋាភិបាលលើផែនការវិស័យអប់រំ ថវិកា កម្មវិធីសិក្សា និងសៀវភៅ

សិក្សា [xxix] រួមជាមួយនឹងការបណ្តុះបណ្តាលគ្រូ និងការគ្រប់គ្រង ដូច្នេះពួកគេមិនមានផ្នត់គំនិតទាក់ទងនឹងយេនឌ័រ និងការលើកកម្ពស់សមភាព ភាពមិនរើសអើង និងសិទ្ធិមនុស្ស ព្រមទាំងជម្រុញការអប់រំអន្តរវប្បធម៌។

- ធានាបាននូវការប្រើប្រាស់ប្រភពទិន្នន័យ និងព័ត៌មានជាច្រើនដោយរួមបញ្ចូលពីប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ និងការស្ទង់មតិនៅតាមសាលារៀន និងតាមគ្រួសារដែលពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ការត្រួតពិនិត្យ និងការផាត់ ចេញរបស់សង្គមនៅក្នុងការអប់រំ។ ប្រព័ន្ធទិន្នន័យវិសមភាពពិភពលោកស្តីពីការអប់រំគឺជាឧទាហរណ៍ មួយនៃរបៀបដែលព័ត៌មានត្រូវបានបង្កើតឡើង ដើម្បីធ្វើឲ្យអ្នកសម្រេចចិត្តចាត់វិធានការ។[9]
- ប្រមូលទិន្នន័យដែលមានគុណភាពល្អប្រសើរជាងមុននៅលើកុមារពិការ ដាក់បញ្ជីផ្សេងៗគ្នានៃពិការភាព និងអ្នកមានបញ្ហាពិការផ្សេងៗ និងវាយតម្លៃនៃភាពធ្ងន់ធ្ងររបស់ពួកគេ។ សូចនាករត្រូវតែបង្កើតឡើង និងទិន្នន័យគួរត្រូវបានប្រើ ដើម្បីបង្កើតមូលដ្ឋានភស្តុតាងមួយ ជាព័ត៌មានដល់ការរៀបចំកម្មវិធី និងគោលនយោបាយ។

**ចំណុចដៅ ៤.៦៖** ត្រឹមឆ្នាំ ២០៣០ ធានាថាយុវជន និងមនុស្សពេញវ័យភាគច្រើន ទាំងបុរស និងស្ត្រីសម្រេចបាននូវអក្ខរភាព និងចេះគិតលេខ។

៥៨. អក្ខរកម្ម[10] ជាផ្នែកមួយនៃសិទ្ធិក្នុងការអប់រំ និងសម្បត្តិសាធារណៈ។ វាគឺជាចំណុចស្នូលនៃការអប់រំមូលដ្ឋាន និងជាគ្រឹះមិនអាចខ្វះបានសម្រាប់ការសិក្សាឯករាជ្យ [xxx ]។ អត្ថប្រយោជន៍នៃអក្ខរកម្ម ជាពិសេសសម្រាប់ស្ត្រីត្រូវបានចងក្រងជាឯកសារយ៉ាងល្អ។ វាមានការចូលរួមកាន់តែច្រើនក្នុងទីផ្សារការងារ អាពាហ៍ពិពាហ៍ពន្យារពេល និងធ្វើឲ្យប្រសើរឡើងនូវ សុខភាពកុមារ ក្រុមគ្រួសារ និងអាហារូបត្ថម្ភ ទាំងនេះ វាជួយកាត់បន្ថយភាពក្រីក្រ និងការពង្រីកឱកាសជីវិតរបស់ពួកគេ។ ការចេះគិតលេខ គឺជាជំនាញសំខាន់៖ ការគណនាលេខ គណនី ការវាស់ផលធៀប និងបរិមាណជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតដែលទាមទារឲ្យមាននៅគ្រប់ទីកន្លែង[xxxi]។ ប៉ុន្តែការបង្កើនអក្ខរកម្ម និងចំនេះដឹងគិតលេខ សម្រាប់យុវជន និងមនុស្សពេញវ័យនៅតែជាបញ្ហាប្រឈមជាសកលនៅឡើយ។ នៅទូទាំងពិភពលោកក្នុងឆ្នាំ ២០១៣ មនុស្សពេញវ័យចំនួន ៧៥៧លាននាក់ (អាយុ ១៥ឆ្នាំនិងខ្ពស់ជាងនេះ) ដែលក្នុងនោះ ២ ភាគ៣ ជាស្ត្រីដែលមិនអាចអាន និងសរសេរបាន [xxxii]។ ជំនាញអក្ខរកម្មទាប គឺជាការព្រួយបារម្ភមួយនៅទូទាំងពិភពលោករួមទាំងនៅក្នុងបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម និងខ្ពស់ផងដែរ។ មនុស្សពេញវ័យប្រហែល ២០%នៅក្នុងតំបន់អឺរ៉ុបខ្វះជំនាញអក្ខរកម្មដែលពួកគេត្រូវការដើម្បីចូលរួមឲ្យបានពេញលេញនៅក្នុងសង្គម [xxxiii]។ មនុស្សពេញវ័យដែលមានជំនាញអក្ខរកម្ម និងគិតលេខទាបប្រឈម

9 ប្រព័ន្ធទិន្នន័យនេះ អាចត្រូវបានរកឃើញនៅ www.education-inequalities.org

10 អក្ខរកម្ម ត្រូវបានកំណត់ជា សមត្ថភាពដើម្បីកំណត់ យល់ដឹង បកប្រែ បង្កើត ទំនាក់ទំនង និងគណនា ដោយប្រើសម្ភារៈ ដែលបានបោះពុម្ព និងសរសេរ ដោយផ្សារភ្ជាប់ជាមួយនឹងបរិបទចម្រុះ។ អក្ខរកម្ម ពាក់ព័ន្ធនឹងការបន្តនៃការរៀននៅក្នុងការធ្វើឱ្យបុគ្គលទាំងអស់ ដើម្បីសម្រេចបាននូវគោលដៅ របស់ខ្លួន ក្នុងការអភិវឌ្ឍចំណេះដឹង និងសក្តានុពលរបស់ពួកគេ និងបានចូលរួមយ៉ាងពេញលេញនៅក្នុងសហគមន៍ និងសង្គម។ (UNESCO ឆ្នាំ ២០០៥ ទិដ្ឋភាពនៃការវាយតំលៃនៃអក្ខរកម្ម៖ ប្រធានបទ និងបញ្ហាពីកិច្ចប្រជុំក្រុមអ្នកជំនាញ UNESCO ថ្ងៃទី ១០-១២ ខែមិថុនា ឆ្នាំ ២០០៣៖
http://unesdoc.unesco.org/images/0014/001401/140125eo.pdf )។

មុខនឹងប្រភពនៃគុណវិបត្តិជាច្រើន។ ពួកគេទំនងជាគ្មានការងារធ្វើ និងអ្នកដែលត្រូវបានជួល និងទទួលបានប្រាក់ឈ្នួលទាបជាង។ ពួកគេបានរកឃើញវាជាការលំបាកបន្ថែមទៀត ដើម្បីធ្វើឱ្យការប្រើប្រាស់ឱកាសក្នុងសង្គម និងដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន។ ពួកគេក៏ទំនងនិងមានសុខភាពទន់ខ្សោយផងដែរ។

៥៩. ត្រឹមឆ្នាំ ២០៣០ យុវជន និងមនុស្សពេញវ័យទាំងអស់នៅទូទាំងពិភពលោក គួរតែសម្រេចបានកម្រិតខ្ពស់ដែលពាក់ព័ន្ធនឹងការទទួលស្គាល់នូវជំនាញ[11] អក្ខរកម្ម និងការគិតលេខដែលមានប្រយោជន៍ ដែលមានតម្លៃស្មើទៅនឹងការបញ្ចប់ដោយជោគជ័យនៃការអប់រំជាមូលដ្ឋាន។ គោលការណ៍ យុទ្ធសាស្រ្ត និងសកម្មភាពសម្រាប់គោលដៅនេះ គឺត្រូវបង្កើតជាមូលដ្ឋានដោយការយល់ដឹងបច្ចុប្បន្នភាពអក្ខរកម្ម មិនមែនជាការបែងចែកជាពីរយ៉ាងសាមញ្ញនៃ "ការចេះអានចេះសរសេរ" ធៀបនឹង "មិនចេះអក្សរនោះទេ" ប៉ុន្តែជាការបន្តកម្រិតខ្ពស់មួយ។ កម្រិតដែលត្រូវការ និងរបៀបដែលប្រជាជនត្រូវបានអនុវត្តជំនាញក្នុងការអាន និងការសរសេរ គឺពឹងផ្អែកលើបរិបទជាក់លាក់។ ការយកចិត្តទុកដាក់ជាពិសេស គួរតែត្រូវបានផ្តោតទៅលើតួនាទីនៃភាសាទីមួយ ដែលអ្នកសិក្សាអាចក្លាយជាអ្នកចេះអក្សរ និងអាចរៀនសូត្របាន។ កម្មវិធីអក្ខរកម្ម និងវិធីសាស្រ្តគួរឆ្លើយតបនឹងតម្រូវការ និងបរិបទនៃការសិក្សា រួមទាំងតាមរយៈការផ្តល់កម្មវិធីអក្ខរកម្មអន្តរវប្បធម៌ពីរភាសាដែលទាក់ទងគ្នាក្នុងក្របខ័ណ្ឌនៃការរៀនសូត្រពេញមួយជីវិតនោះ។ ការផ្តល់ចំណេះដឹង ការគិតលេខនិងតម្រូវឱ្យមានការពង្រឹង គួរតែជាផ្នែកមួយនៃកម្មវិធីអក្ខរកម្ម។ វិស័យ ICT ជាពិសេសបច្ចេកវិទ្យាចល័ត បានសន្យាយ៉ាងច្បាស់សម្រាប់ជួយបង្កើនល្បឿនវឌ្ឍនភាពឆ្ពោះទៅរកចំណុចដៅ។

៦០. **យុទ្ធសាស្រ្តដែលចង្អុលបង្ហាញ៖**

- បង្កើតវិធីសាស្រ្តតាមវិស័យឲ្យធំទូលាយ និងបែបពហុវិស័យសម្រាប់រៀបចំគោលនយោបាយអក្ខរកម្ម និងផែនការសម្រាប់ធ្វើកញ្ចប់ថវិកាដោយការពង្រឹងការសហការ និងសម្របសម្រួលក្នុងចំណោមក្រសួងពាក់ព័ន្ធរួមទាំងការដោះស្រាយជាមួយនឹងវិស័យអប់រំ សុខាភិបាល សុខុមាលភាពសង្គម ការងារ ឧស្សាហកម្ម និងកសិកម្ម ថែមទាំងជាមួយនឹងសង្គមស៊ីវិល ដែលមានវិស័យឯកជន និងដៃគូទ្វេភាគី និងពហុភាគីគាំទ្រដល់ការផ្តល់វិមជ្ឈការក្នុងការអនុវត្ត។
- ធានាថាកម្មវិធីអក្ខរកម្ម និងចំនេះដឹងគិតលេខ គឺមានគុណភាពខ្ពស់ ដោយយោងតាមយន្តការវាយតម្លៃថ្នាក់ជាតិឆ្លើយតបតម្រូវការអ្នកសិក្សា និងដោយផ្អែកលើចំណេះដឹង និងបទពិសោធពីមុនរបស់ពួកគេ។ នេះ តម្រូវឱ្យមានការយកចិត្តទុកដាក់យ៉ាងជិតស្និទ្ធទៅនឹងវប្បធម៌ ភាសា ទំនាក់ទំនងសង្គមនិងនយោបាយ និងសកម្មភាពសេដ្ឋកិច្ច ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសទៅលើកុមារី ស្រ្តី និងក្រុម ជនងាយរងគ្រោះព្រមទាំងការតភ្ជាប់នឹងការបញ្ចូលកម្មវិធីនេះ ជាមួយនឹងការអភិវឌ្ឍជំនាញសម្រាប់ការងារសមរម្យ និងជីវភាព ដែលជាធាតុសំខាន់មួយនៃការសិក្សាពេញមួយជីវិត។

---

11 មនុស្សម្នាក់ ត្រូវបានកំណត់ថា ចេះអក្សរត្រឹមត្រូវ ដែលអាចចូលរួមក្នុងសកម្មភាពទាំងអស់ជាតម្រូវការសម្រាប់ការដើរតួប្រកបដោយប្រសិទ្ធិភាពសម្រាប់ក្រុម និងសហគមន៍របស់ពួកគាត់ ហើយក៏អាចការធ្វើឱ្យពួកគាត់អាចបន្តប្រើប្រាស់ ការអាន ការសរសេរ និងការគណនា សម្រាប់ការអភិវឌ្ឍខ្លួន និងសហគមន៍ របស់ពួកគេ។ (UNESCO ឆ្នាំ ២០០៦ របាយការណ៍ត្រួតពិនិត្យការអប់រំជាសកលនៅ ឆ្នាំ ២០០៦-អក្ខរកម្មសម្រាប់ជីវិត៖ http://www.unesco.org/education/GMR2006/full/chapt6_eng.pdf ) ។

- ពង្រីកកម្មវិធីជំនាញ អក្ខរកម្ម និងការគិតលេខសម្រាប់មនុស្សពេញវ័យប្រកបដោយប្រសិទ្ធិភាព ដោយធ្វើការជាមួយសង្គមស៊ីវិលដែលដើរតួជាដៃគូក្នុងការកសាងបទពិសោធរបស់ពួកគេ និងការអនុវត្តល្អ។
- ជម្រុញការប្រើប្រាស់ ICT ជាពិសេសបច្ចេកវិទ្យាចល័ត សម្រាប់កម្មវិធីអក្ខរកម្ម និងរៀនលេខ។
- អភិវឌ្ឍក្របខណ្ឌការវាយតម្លៃអក្ខរកម្ម និងឧបករណ៍នានា ដើម្បីវាយតម្លៃកម្រិតជំនាញដោយផ្អែកលើលទ្ធផលនៃការសិក្សា។ នេះនឹងតម្រូវឱ្យមានការកំណត់នូវជំនាញដោយឆ្លងកាត់នូវបរិបទជាច្រើន ដែលរួមមានជំនាញក្នុងការងារ និងក្នុងជីវិតប្រចាំថ្ងៃ។
- បង្កើតប្រព័ន្ធ ដើម្បីប្រមូល វិភាគ និងចែករំលែកទិន្នន័យពាក់ព័ន្ធ និងទាន់ពេលវេលាលើកម្រិតអក្ខរកម្ម និងតម្រូវការអក្ខរកម្ម និងលេខ ដែលបែងចែកតាមយេនឌ័រ និងសូចនាករផ្សេងទៀតនៃភាពងាយរងគ្រោះ។

**ចំណុចដៅ ៤.៧៖** ត្រឹមឆ្នាំ២០៣០ ធានាថាអ្នកសិក្សាទាំងអស់ ទទួលបាននូវចំណេះដឹង និងជំនាញដែលត្រូវការដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព ដោយរួមបញ្ចូលទាំងចំណោមអ្នកដ៏ទៃទៀត តាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព និងរបៀបរស់នៅដែលប្រកបដោយចីរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ លើកកម្ពស់វប្បធម៌សន្តិភាព អហឹង្សា ភាពជាពលរដ្ឋសកល និងការទទួលយកភាពចម្រុះនៃវប្បធម៌ និងការចូលរួមចំណែកដើម្បីការអភិវឌ្ឍដោយចីរភាព។

៦១. បញ្ហាប្រឈមផ្នែកសង្គម នយោបាយ សេដ្ឋកិច្ច និងបរិស្ថាន ដែលមិនអាចដោះស្រាយបាននៅក្នុងពិភពលោកទាំងអស់ ការអប់រំដែលជួយកសាងសង្គមដែលមានសន្តិភាព និងមានចីរភាព គឺជារឿងសំខាន់។ ប៉ុន្តែប្រព័ន្ធអប់រំ កម្រនឹងបានរួមបញ្ចូលពេញលេញនូវវិធីសាស្ត្រការផ្លាស់ប្តូរបែបនេះឡើយ។ ដូច្នេះ វាជាការសំខាន់ណាស់ក្នុងការផ្តល់នូវទីតាំងចំនុចកណ្តាលមួយនៅឆ្នាំ ២០៣០ ក្នុងការពង្រឹងការរួមចំណែកនៃការអប់រំ ដើម្បីបំពេញនូវសិទ្ធិមនុស្ស សន្តិភាព និងភាពជាពលរដ្ឋដែលមានទំនួលខុសត្រូវពីកម្រិតក្នុងស្រុក ទៅកម្រិតសកល សមភាពយេនឌ័រ និងការអភិវឌ្ឍដោយចីរភាព និងសុខភាព។

៦២. មាតិកានៃការអប់រំបែបនេះ ត្រូវតែមានការពាក់ព័ន្ធដោយផ្តោតសំខាន់ទាំងលើទិដ្ឋភាពនៃជំនាញបច្ចេកទេស និងជំនាញទន់នៃការរៀនសូត្រ។ ចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបទត្រូវបានទាមទារដោយប្រជាពលរដ្ឋដើម្បីដឹកនាំជីវិតរស់នៅឲ្យកាន់តែមានផលិតភាព ធ្វើការសម្រេចចិត្តច្បាស់លាស់ និងដើរតួនាទីសកម្មទាំងក្នុងតំបន់ និងពិភពលោក។ ការប្រឈមមុខ និងការដោះស្រាយជាសកល អាចត្រូវទទួលបានតាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព (ESD)[12] និងការអប់រំជាពលរដ្ឋសកល (GCED)[13] ដែលរួមមានសន្តិភាព និង

---

12 ESD ផ្តល់អំណាចដល់អ្នកសិក្សាឲ្យទទួលយកការសម្រេចចិត្ត ជូនដំណឹង និងសកម្មភាពទទួលខុសត្រូវចំពោះបូរណភាពបរិស្ថាន លទ្ធភាពជោគជ័យសេដ្ឋកិច្ច និងសង្គសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងពេលអនាគត ខណះពេលមានការគោរពដល់វប្បធម៌ចម្រុះ។ ការទាក់ទងនឹងរៀនសូត្រពេញមួយជីវិត ហើយវាជាផ្នែកមួយសំខាន់នៃការអប់រំប្រកបដោយគុណភាព។ ESD គឺជាការអប់រំនៃការផ្លាស់ប្តូរទាំងមូលដែលដោះស្រាយលើខ្លឹមសារការរៀន និងលទ្ធផល គរុកោសល្យ និងបរិស្ថាន។ ការសម្រេចនូវគោលបំណងរបស់ខ្លួន ដោយការផ្លាស់ប្តូរសង្គម។ (UNESCO ឆ្នាំ 2014 ផែនទីចង្អុលផ្លូវសម្រាប ការអនុវត្ត សកម្មភាពជាសកល កម្មវិធីអប់រំសម្រាបការអភិវឌ្ឍប្រកបដោយចីរភាព http://unesdoc.unesco.org/images/0023/002305/230514e.pdf)

13 GCED មានគោលបំណង ដើម្បីផ្តល់អ្នកសិក្សាជាមួយនឹងសមត្ថភាពស្នូលដូចខាងក្រោម៖ ក) ចំណេះជ្រៅជ្រះអំពីបញ្ហាសកល និងគុណតម្លៃសាកលដូចជា៖ យុត្តិធម៌ សមភាព សេចក្តីថ្លៃថ្នូរ និងការគោរព ខ) ជំនាញវិភាគពិចារណាបែបស៊ីជម្រៅ បែបជាប្រព័ន្ធ និងបែបច្នៃប្រឌិត រួមទាំងការទទួលយកនូវវិធីសាស្ត្រពហុទស្សនវិស័យ ដែលទទួលស្គាល់វិមាត្រ ទស្សនៈនិងមុំនៃបញ្ហាខុសៗគ្នា) ជំនាញទន់ (non-cognitive) រួមទាំងជំនាញសង្គមដូចជា ការយល់ចិត្ត និងការដោះស្រាយជម្លោះ និងជំនាញទំនាក់ទំនង និងសម្បទានសម្រាប់ការភ្ជាប់បណ្តាញនឹងការប្រាស្រ័យទាក់ទងជាមួយមនុស្ស ដែលមានប្រវត្តិ ដើមកំណើត ទំនៀមទម្លាប់ និងទស្សនៈវិស័យផ្សេងៗគ្នា និងឃ) សមត្ថភាពអាកប្បកិរិយា ដើម្បីធ្វើសកម្មភាពសហការគ្នា និងមានការទទួលខុសត្រូវ និងដើម្បីព្យាយាមធ្វើឱ្យបានល្អ។ (UNESCO ឆ្នាំ ២០១៣៖លទ្ធផលនៃបច្ចេកទេសពិគ្រោះយោបល់ស្តីពីការអប់រំពលរដ្ឋសកល៖ ការអប់រំពលរដ្ឋសកល - ទស្សនៈវិស័យរួមបញ្ចូលគ្នា។http://unesdoc.unesco.org/images/0022/002241/224115E.pdf)

ការអប់រំសិទ្ធិមនុស្សព្រមទាំងការអប់រំអន្តរវប្បធម៌ និងការអប់រំសម្រាប់ការយល់ដឹងជាអន្តរជាតិ។ ខណៈពេលដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ត្រូវបានធ្វើឡើងនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ មានតែ ៥០% នៃរដ្ឋជាសមាជិករបស់អង្គការយូណេស្កូបានបង្ហាញថា ពួកគេបានធ្វើការសមាហរណកម្មការអប់រំជាពលរដ្ឋសកលទៅក្នុងគោលនយោបាយដែលពាក់ព័ន្ធ [xxxiv]។

## ៦៣. យុទ្ធសាស្ត្រដែលចង្អុលបង្ហាញ៖

- រៀបចំគោលនយោបាយ និងកម្មវិធីដើម្បីលើកកម្ពស់ការអប់រំដោយចីរភាព (ESD) និងការអប់រំជាពលរដ្ឋសកល (GCED) ហើយដាក់ចូលក្នុងការបញ្ជ្រាបនៃការអប់រំជាផ្លូវការ មិនផ្លូវការ និងក្រៅប្រព័ន្ធតាមរយៈអន្តរាគមន៍ប្រព័ន្ធយ៉ាងទូលាយ ការបណ្តុះបណ្តាលគ្រូបង្រៀន ការធ្វើកំណែទម្រង់កម្មវិធីសិក្សា និងការគាំទ្រគរុកោសល្យ។ នេះរួមបញ្ចូលទាំងការអនុវត្តកម្មវិធីសកម្មភាពជាសកល ESD[14] និងដោះស្រាយប្រធានបទរួមមាន ដូចជា សិទ្ធិមនុស្ស សមភាពយេនឌ័រ សុខភាព ការអប់រំផ្លូវភេទទូលំទូលាយ ការផ្លាស់ប្តូរអាកាសធាតុការចិញ្ចឹមជីវិតប្រកបដោយចីរភាព ការទទួលខុសត្រូវ និងការចូលរួមរបស់ប្រជាពលរដ្ឋ ដោយផ្អែកលើបទពិសោធន៍ជាតិ និងសមត្ថភាព។
- ផ្តល់ដល់អ្នកសិក្សាទាំងពីរភេទ និងគ្រប់វ័យទាំងអស់នូវឱកាសក្នុងជីវិតរបស់ពួកគេក្នុងការទទួលបាននូវចំណេះដឹងជំនាញ តម្លៃ និងឥរិយាបទ ដែលជាតម្រូវការចាំបាច់សម្រាប់កសាងសង្គមមួយប្រកបដោយសន្តិភាព សុខភាព និងចីរភាព។
- អភិវឌ្ឍ និងផ្សព្វផ្សាយបន្តនូវការអនុវត្តល្អៗទៅលើ ESD និង GCED ទាំងក្នុង និងរវាងបណ្តាប្រទេសដើម្បីពង្រឹងការអនុវត្តកម្មវិធីអប់រំទាំងអស់ឲ្យបានប្រសើរជាងមុន បង្កើនកិច្ចសហប្រតិបត្តិការ និងការយល់ដឹងជាលក្ខណៈអន្តរជាតិ។
- លើកកម្ពស់កម្មវិធីតាមបែបចូលរួមសម្រាប់អ្នកសិក្សា និងអ្នកបង្រៀនដែលទាក់ទងទៅនឹង ESD និង GCED ក្នុងគោលបំណងពង្រឹងទំនាក់ទំនងរវាងសហគមន៍ និងសង្គមទាំងមូល។
- ធានាថាការអប់រំទទួលស្គាល់នូវតួនាទីយ៉ាងសំខាន់មួយ ដែលវប្បធម៌ដើរតួនៅក្នុងការសម្រេចបាននូវចីរភាពតាមរយៈការយកចិត្តទុកដាក់លើលក្ខខណ្ឌក្នុងតំបន់ និងវប្បធម៌ ព្រមទាំងពង្រឹងនូវការយល់ដឹងនូវការសំដែងចេញពីវប្បធម៌ បេតិកភ័ណ្ឌ និងភាពសម្បូរបែបរបស់ពួកគេ ខណៈដែលសារៈសំខាន់នៃការគោរពសិទ្ធិមនុស្សកំពុងតែមានការយកចិត្តទុកដាក់។
- គាំទ្រដល់ការអភិវឌ្ឍឲ្យមាននូវប្រព័ន្ធការវាយតម្លៃដែលមានភាពរឹងមាំបន្ថែមទៀតសម្រាប់ ESD និង GCED ដើម្បីវាយតម្លៃលើការយល់ដឹង លទ្ធផលការសិក្សាលើផ្នែកសង្គមផ្លូវចិត្ត និងអាកប្បកិរិយាដោយប្រើឧបករណ៍ដែលមានស្រាប់ និងបានបញ្ជាក់រួចនៅពេលអាចធ្វើទៅបាន កំណត់នូវតម្រូវការសម្រាប់ការអភិវឌ្ឍនៃឧបករណ៍ថ្មី រួមទាំងប្រទេស និងតំបន់ជាច្រើនដែលយកការងាររបស់វិទ្យាស្ថានស្ថិតិអង្គការយូណេស្កូ (UIS) និងដៃគូដទៃទៀត។

14 អនុម័តដោយសន្និសីទ UNESCO (27C / Resolution 12) និងទទួលស្គាល់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ (A / RES / 69 / 211 ) ជាការតាមដានរបស់អង្គការសហប្រជាជាតិនៃ ESD ។

- លើកកម្ពស់នូវអន្តរជំនាញ និងវិធីសាស្ត្រពហុភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យបាន ESD និង GCED នៅគ្រប់កម្រិត និងនៅគ្រប់ទម្រង់នៃការអប់រំ រួមទាំងតាមរយៈការអប់រំសិទ្ធិមនុស្ស និងការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់វប្បធម៌សន្តិភាព និងអហឹង្សា។

## មធ្យោបាយនៃការអនុវត្ត

**ចំណុចដៅ ៤.កៈ** កសាង និងធ្វើឱ្យប្រសើរឡើងនូវសម្ភារៈបរិក្ខារអប់រំ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារជាពិការភាព ការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ និងផ្តល់នូវបរិយាកាសសិក្សាដែលមានសុវត្ថិភាព អហឹង្សា បរិយាប័ន្ន និងបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធិភាព សម្រាប់ទាំងអស់គ្នា។

៦៤. ចំណុចដៅនេះ គឺដោះស្រាយតម្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់គ្រាន់ និងមានសុវត្ថិភាព បរិស្ថានរួមបញ្ចូលគ្នាដែលជួយដល់ការរៀនសូត្រសម្រាប់ទាំងអស់ដោយមិនគិតពីសាវតា ឬស្ថានភាពពិការភាព។[15] បរិយាកាសសិក្សាប្រកបដោយគុណភាព គឺជាការចាំបាច់ណាស់ក្នុងការគាំទ្រដល់អ្នកសិក្សាទាំងអស់ គ្រូបង្រៀន និងបុគ្គលិកអប់រំផ្សេងទៀត។ គ្រប់បរិយាកាសសិក្សា គួរតែអាចទទួលបានសម្រាប់ទាំងអស់គ្នា មានធនធាន និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ដើម្បីធានាឱ្យមានទំហំថ្នាក់សមរម្យ និងផ្តល់សម្ភារៈមានអនាម័យត្រឹមត្រូវ។ បើទោះជាភាគរយជាមធ្យមនៃសាលាបឋមសិក្សាមានអនាម័យគ្រប់គ្រាន់កើនឡើងពី ៥៩% នៅឆ្នាំ ២០០៨ ដល់ ៦៨% នៅក្នុងឆ្នាំ ២០១២ ក្នុង១២៦ ប្រទេសកំពុងអភិវឌ្ឍន៍ក៏ដោយ មានតែសាលារៀនមួយក្នុងចំណោមសាលាពីរប៉ុណ្ណោះដែលបំពេញតាមស្តង់ដារក្នុង ៥២ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត និងប្រទេសមានចំណូលទាប [xxxv]។

៦៥. ការធានាថាកុមារី និងស្ត្រីទទួលបានសុវត្ថិភាពក្នុងបរិយាកាសសិក្សារបស់ពួកគេ គឺជាគន្លឹះក្នុងការបន្តការសិក្សារបស់ពួកគេ [xxxvi]។ ការចាប់ផ្តើមនៃការពេញវ័យរបស់កុមារី ធ្វើឲ្យពួកគេងាយរងគ្រោះលើអំពើហិង្សាផ្លូវភេទ ការយាយី ការបង្ខិតបង្ខំ និងការរំលោភបំពាន។ អំពើហិង្សាយេនឌ័រនៅក្នុងសាលា គឺជាឧបសគ្គយ៉ាងសំខាន់លើការអប់រំរបស់ក្មេងស្រី។ កុមារជាច្រើនត្រូវទទួលរងការយាយី និងរំលោភបំពាននៅក្នុងសាលារៀនៈ កុមារី និងកុមារាប្រមាណជា ២៤៦លាននាក់ត្រូវបានយាយី និងរំលោភបំពាននៅក្នុងនិងជុំវិញសាលារៀនជារៀងរាល់ឆ្នាំ [xxxvii] ។ ក្នុងពីរភាគបីនៃបណ្តាប្រទេសដែលមានគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំកម្រិតមធ្យមសិក្សាគឺសំដៅទៅលើក្មេងស្រី [xxxviii] ។ អវត្តមាននៃបង្គន់ដាច់ដោយឡែក ការខ្វះខាតសំឡីអនាម័យ និងភាពខ្មាស់អៀនទាក់ទងនឹងការចាប់ផ្តើមមានអនាម័យក្នុងពេលដែលក្មេងស្រីមានរដូវ អាចប៉ះពាល់ដល់ការសិក្សារបស់ពួកគេបង្កើនអត្រាអវត្តមាន និងកាត់បន្ថយការចូលរួមក្នុងការសិក្សារបស់ពួកគេ។ ដូចគ្នានេះដែរ ការខ្វះការយកចិត្តទុកដាក់ទៅលើសិទ្ធិ និងសេចក្តីត្រូវការរបស់កុមារ យុវជន និងមនុស្សពេញវ័យ ដែលមានភាពពិការយ៉ាងធ្ងន់ធ្ងរ បានដាក់កម្រិតមួយយ៉ាងធំដល់ការចូលរួមរបស់ពួកគេក្នុងការសិក្សាអប់រំ។

15 វាជាការសំខាន់ក្នុងការសំគាល់ថា គំនិតនៃបរិស្ថានរៀនសូត្រមានសុវត្ថិភាព និងបរិយាប័ន្ន ត្រូវបានបង្កើតឡើង តាមរយៈ បទដ្ឋានអប្បបរមា INEE និងបញ្ជីផ្ទៀងផ្ទាត់នៃសាលាកុមារមេត្រីរបស់អង្គការយូនីសេហ្វ ។

## ៦៦. យុទ្ធសាស្ត្រដែលចង្អុលបង្ហាញ៖

- គ្រប់គ្រងគោលនយោបាយទូលំទូលាយ ចម្រុះ និងជាប់លាប់ដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ ពិការភាព និង លើកកម្ពស់បទដ្ឋាននិងប្រព័ន្ធដែលធានាថា សាលារៀនមានសុវត្ថិភាព និងគ្មានអំពើហិង្សា។
- បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការការពារអ្នកសិក្សា គ្រូបង្រៀន និងបុគ្គលិកឲ្យរួចផុតពីការប្រើអំពើហិង្សាក្នុងក្របខ័ណ្ឌនៃសាលារៀនដោយគ្មានអំពើហិង្សា និងនៅក្នុងតំបន់ជម្លោះប្រដាប់អាវុធ ប្ដេជ្ញានិងគោរពតាមច្បាប់មនុស្សធម៌អន្តរជាតិដែលការពារសាលារៀនជាសម្ភារៈស៊ីវិល និងដាក់ការរំលោភបំពានឲ្យទទួលខុសត្រូវក្នុងការអនុវត្តវិស័យអប់រំឆ្នាំ ២០៣០។
- ធានាថាគ្រប់ស្ថាប័នមានសុវត្ថិភាព មានទឹក ភ្លើង បង្គន់ដាច់ដោយឡែកដែលមិនខូច និងប្រើប្រាស់បាន មានថ្នាក់រៀនមានសុវត្ថិភាព និងមានសម្ភារៈសិក្សាគ្រប់គ្រាន់ និងមានបច្ចេកវិទ្យាដែលសមស្រប។
- ធានាថាសាលារៀន និងមជ្ឈមណ្ឌលសិក្សាទាំងអស់មានធនធានស្មើគ្នាទាំងសាលារៀនមានសេដ្ឋកិច្ចសង្គមល្អ និងមិនល្អ។
- បង្កើតឱកាសរៀន និងបរិស្ថានរៀនសូត្រសម្រាប់ការអប់រំក្រៅប្រព័ន្ធ និងសម្រាប់មនុស្សពេញវ័យឲ្យបានទូលំទូលាយ រួមមានបណ្ដាញនៃមជ្ឈមណ្ឌលសិក្សាសហគមន៍ និងការផ្ដល់ឱកាសឲ្យទទួលបានធនធាន ICT ដែល ជាធាតុសំខាន់មួយនៃការសិក្សាពេញមួយជីវិត។

**ចំណុចដៅ ៤.ខ៖** ត្រឹមឆ្នាំ ២០២០ ពង្រីកឲ្យបានច្រើនជាសកល លើចំនួនអាហារូបករណ៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសបណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត កោះតូចៗនៃរដ្ឋកំពុងអភិវឌ្ឍន៍ និងប្រទេសនៅទ្វីបអាហ្វ្រិកសម្រាប់ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សារួមមានកម្មវិធីបណ្ដុះបណ្ដាល វិជ្ជាជីវៈ និងបច្ចេកវិទ្យាពត៌មាននិងសារគមនាគម៍ បច្ចេកទេស ជំនាញ វិស្វកម្ម និងវិទ្យាសាស្ត្រ នៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត។

៦៧. កម្មវិធីអាហារូបករណ៍អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ឱកាសសម្រាប់យុវជន និងមនុស្សពេញវ័យដែលមិនអាចមានលទ្ធភាពក្នុងការបន្តការសិក្សារបស់ពួកគេបាន។ វាបានផ្ដល់នូវសារៈសំខាន់នៃការចូលរួមចំណែកក្នុងអន្តរជាតូបនិយកម្មលើប្រព័ន្ធអប់រំ និងការស្រាវជ្រាវកម្រិតឧត្តមសិក្សា ជាពិសេសនៅក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត។ ពួកគេអាចជួយបង្កើនលទ្ធភាពទទួលបានចំណេះដឹងជាសាកល និងកសាងសមត្ថភាពក្នុងការផ្ទេរចំណេះដឹង ការសម្របខ្លួនទៅនឹងលក្ខខណ្ឌ និងបច្ចេកវិទ្យាក្នុងតំបន់។ ក្នុងឆ្នាំ ២០១០ – ២០១១ ថវិកាជំនួយជាមធ្យមមានចំនួន ៣,២ ពាន់លានដុល្លាសហរដ្ឋអាមេរិច ត្រូវបានបម្រុងទុកជារៀងរាល់ឆ្នាំ ដើម្បីផ្ដល់អាហារូបករណ៍ និងការចំណាយរបស់និស្សិត ស្មើនឹងមួយភាគបួននៃការផ្ដល់ជំនួយសរុបដល់វិស័យអប់រំ [xxxix]។ ការចំណាយនេះ មិនត្រឹមតែសំខាន់ក្នុងការពង្រឹងនូវជំនាញនៃកម្លាំងពលកម្មនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបប៉ុណ្ណោះទេ ថែមទាំងវាផ្ដល់ផលប្រយោជន៍ដល់ប្រទេសដែលមានចំណូលពាក់កណ្ដាលមធ្យមផងដែរ។ ឧទាហរណ៍ ចំនួនថវិកាសរុបក្នុងទម្រង់ជាអាហារូបករណ៍ និងការចំណាយរបស់និស្សិតទទួលបានជារៀងរាល់ឆ្នាំ ដោយគ្រាន់តែប្រាំប្រទេសដែលមានប្រាក់ចំណូលមធ្យម ស្មើនឹងចំនួនសរុបនៃការផ្ដល់ជំនួយដោយផ្ទាល់ទៅនឹងការអប់រំជាមូលដ្ឋានសម្រាប់៣៦ប្រទេស ដែលមានប្រាក់ចំណូលទាបក្នុងឆ្នាំ

២០១០-២០១១។ នៅពេលដែលប្រទេសអភិវឌ្ឍន៍ បានផ្តល់នូវអាហារូបករណ៍ដល់និស្សិតមកពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ គួរតែត្រូវបានរៀបចំឡើងដើម្បីកសាងសមត្ថភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ខណៈពេលដែលសារៈសំខាន់នៃអាហារូបករណ៍ត្រូវបានទទួលស្គាល់ ប្រទេសផ្តល់ជំនួយក៏ត្រូវបានលើកទឹកចិត្តក្នុងការបង្កើនទម្រង់ផ្សេងទៀតនៃការគាំទ្រដល់ការអប់រំ។

៦៨. ស្របជាមួយនឹងការផ្តោតលើវិស័យអប់រំឆ្នាំ ២០៣០ លើសមភាព បរិយាប័ន្ន និងគុណភាព អាហារូបករណ៍គួរតែត្រូវបានកំណត់គោលដៅប្រកបដោយតម្លាភាពចំពោះយុវជនដែលមានសាវតាលំបាក។ ជាញឹកញាប់អាហារូបករណ៍ ត្រូវបានដាក់គោលដៅនៅមុខវិជ្ជាដូចជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ICT កម្មវិធីអប់រំគ្រូបង្រៀន និងវិជ្ជាជីវៈ។ ការយកចិត្តទុកដាក់ជាពិសេសអាហារូបករណ៍គួរតែត្រូវបានផ្តល់ទៅដល់កុមារី និងស្ត្រីសម្រាប់សិក្សានៅក្នុងមុខវិជ្ជា STEM។

៦៩. **យុទ្ធសាស្ត្រចង្អុលបង្ហាញ៖**

- ធានាថាយន្តការ កម្មវិធី និងគោលនយោបាយនានា សម្រាប់កម្មវិធីអាហារូបករណ៍អន្តរជាតិ គឺបានឆ្លុះបញ្ចាំងពីបរិបទនៃការអភិវឌ្ឍ អាទិភាព និងផែនការជាតិនានាដោយផ្តោតលើការពង្រឹងធនធានមនុស្សនៅក្នុងតំបន់ដែលជាកន្លែងដែលពួកគេកំពុងត្រូវការបំផុត។
- កំណត់គោលដៅនូវរាល់ឱកាសអាហារូបករណ៍ប្រកបដោយតម្លាភាពដល់ស្ត្រីវ័យក្មេង និងបុរសដែលមានសាវតាលំបាក។ ធានាថា ឱកាសអាហារូបករណ៍សម្រាប់យុវជនដែលជួបការលំបាកត្រូវបានលើកកម្ពស់យ៉ាងមាន តម្លាភាព ដូច្នេះអាចអនុញ្ញាតឱ្យយុវជនវ័យក្មេងធ្វើការសម្រេចចិត្តដោយល្អិតល្អន់ និងរៀបចំដើម្បីការពារស្ថានភាពផ្លូវ ច្បាប់ និងសិទ្ធិរបស់ពួកគេ។
- អភិវឌ្ឍន៍កម្មវិធីរួមរវាងសាកលវិទ្យាល័យក្នុងប្រទេស និងប្រទេសដែលត្រូវទៅសិក្សាដើម្បីលើកទឹកចិត្តសិស្សឲ្យត្រឡប់មកប្រទេសកំណើតវិញ ព្រមទាំងយន្តការផ្សេងទៀតដើម្បីការពារមិនឲ្យបាត់បង់អ្នកចេះដឹងដោយ សារពួកគេសម្រេចចិត្តរស់នៅក្រៅប្រទេសរបស់ខ្លួន និងលើកកម្ពស់ការវិលត្រលប់មប្រទេសកំណើតវិញ។
- អភិវឌ្ឍន៍អាហារូបករណ៍នៅក្នុងប្រទេស ដើម្បីបង្កើនចំនួន និងប្រភេទនៃអ្នកទទួលផលនៅក្នុងប្រទេសដែលត្រូវបញ្ជូនទៅ ក៏ដូចជាបង្កើនទីផ្សារការងារក្នុងស្រុកផងដែរ។

**ចំណុចដៅ ៤.គ៖** ត្រឹមឆ្នាំ ២០៣០ បង្កើនយ៉ាងខ្លាំងការផ្គត់ផ្គង់គ្រូដែលមានសមត្ថភាពប្រកបដោយចីរភាព តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសចំពោះប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត និងរដ្ឋកំពុងអភិវឌ្ឍន៍ដែលជាកោះតូចៗនានា។

៧០. គ្រូបង្រៀន គឺជាគន្លឹះដើម្បីសម្រេចបានរបៀបវារៈវិស័យអប់រំឆ្នាំ ២០៣០ ដូច្នេះក្រុមគោលដៅនេះ គឺមានសារៈសំខាន់បំផុត។ វាតម្រូវឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ជាមួយកាលបរិច្ឆេទកំណត់ជាបន្ទាន់ព្រោះ គម្លាត

សមភាពក្នុងការអប់រំមានលក្ខណៈធ្ងន់ធ្ងរដោយសារតែការខ្វះខាត និងការបែងចែកគ្រូដែលបានបណ្តុះបណ្តាលមិនស្មើគ្នា ពិសេសនៅក្នុងតំបន់ជួបការលំបាក។ ដោយសារគ្រូបង្រៀន គឺជាលក្ខខណ្ឌមូលដ្ឋានសម្រាប់ការធានាគុណភាពអប់រំ គ្រូបង្រៀន និងអ្នកអប់រំគួរតែត្រូវបានផ្តល់សិទ្ធិអំណាច ជ្រើសរើស និងឲ្យប្រាក់ឈ្នួលគ្រប់គ្រាន់ ការលើកទឹកចិត្តមានលក្ខណៈសម្បត្តិវិជ្ជាជីវៈ និងគាំទ្រដោយប្រពន្ធ័គ្រប់គ្រងមានប្រសិទ្ធិភាព និងមានរចនាសម្ព័នល្អប្រសើរ។

៧១. ត្រឹមឆ្នាំ២០៣០ ត្រូវការគ្រូបង្រៀនជាង ៣,២លាននាក់បន្ថែមទៀត ដើម្បីសម្រេចបាននូវការអប់រំបឋមសិក្សាជាសាកល [xl] និង៥,១លាននាក់បន្ថែមទៀតនឹងត្រូវការដើម្បីសម្រេចបាននូវការអប់រំមធ្យមសិក្សាបឋមភូមិជាសកល [xli]។ លើសពីនេះទៅទៀត គ្រូដែលត្រូវចាកចេញពីវិជ្ជាជីវៈចន្លោះឆ្នាំ ២០១៥ និងឆ្នាំ ២០៣០នឹងត្រូវមានគ្រូសម្រាប់ជំនួស។ ជាមួយគ្នានេះដែរ នៅក្នុងមួយភាគបីនៃប្រទេសដែលមានទិន្នន័យតិចជាង ៧៥%នៃគ្រូបឋមសិក្សា ត្រូវបានទទួលការបណ្តុះបណ្តាលតាមស្តង់ដារជាតិ [xlii]។ ការសម្រេចចិត្តកាលពីមុនលើស្តង់ដារទាបនៅពេលជួបភាពខ្វះខាតបានចូលរួមចំណែកលើនិន្នាការកើនឡើងនៃថ្នាក់រៀន ដែលត្រូវបានជួយដោយបុគ្គលិកមិនទាន់មានជំនាញពិតប្រាកដ។ វិជ្ជាជីវៈបង្រៀនជាកត្តារួមចំណែកសំខាន់ក្នុងការបង្រៀនទៅលើគុណភាពទាបនៃលទ្ធផលសិក្សាដោយសារអវត្តមាន ខ្វះខាតនៃការអភិវឌ្ឍជំនាញបន្ត ខ្វះការគាំទ្រសម្រាប់គ្រូបង្រៀន និងស្តង់ដារជាតិ។ ប្រព័ន្ធអប់រំដែលទទួលបានជោគជ័យក្នុងការធានាបាននូវគុណភាព និងសមភាព បានផ្តោតលើការបន្តការអភិវឌ្ឍជំនាញវិជ្ជាជីវៈដែលគាំទ្រការរៀនសូត្របន្តរបស់គ្រូបង្រៀន និងការកែលម្អក្នុងអាជីពរបស់ខ្លួន។

៧២. គ្រូបង្រៀនក៏មានសិទ្ធិសេដ្ឋកិច្ច សង្គម និងនយោបាយរួមមានសិទ្ធិក្នុងការស្វែងរកលក្ខខណ្ឌការងារសមរម្យ និងប្រាក់បំណាច់គ្រប់គ្រាន់។ រដ្ឋាភិបាលគួរតែធ្វើឲ្យការបង្រៀនការងារមានភាពទាក់ទាញ និងជាជម្រើសទីមួយលើវិជ្ជាជីវៈជាមួយនឹងការបន្តបណ្តុះបណ្តាល និងការអភិវឌ្ឍ ដោយការកែលម្អស្ថានភាពដែលមានជំនាញវិជ្ជាជីវៈរបស់គ្រូបង្រៀនការគាំទ្រនូវលក្ខខ័ណ្ឌការងារផ្សេងៗ និងគួរពង្រឹងយន្តការកិច្ចសន្ទនាពីគោលនយោបាយជាមួយស្ថាប័នគ្រូបង្រៀន។

៧៣. ចុងបញ្ចប់ គ្រូបង្រៀនរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការរៀនសូត្ររបស់សិស្សដោយមានការគាំទ្រពីថ្នាក់ដឹកនាំសាលា អាជ្ញាធរ រដ្ឋាភិបាល និងសហាគមន៍។ នេះជាភស្តុតាងយ៉ាងរឹងមាំមួយដែលថាគ្រូបង្រៀនមានការបើកចំហដើម្បីផ្លាស់ប្តូរ ចង់រៀន និងអភិវឌ្ឍន៍នៅក្នុងអាជីពរបស់ពួកគេ។ នៅពេលជាមួយគ្នានេះដែរ ពួកគេត្រូវការពេលវេលា ដើម្បីផ្តួចផ្តើមគំនិតបន្ថែមទៀតក្នុងការធ្វើការជាមួយមិត្តរួមការងារ និងថ្នាក់ដឹកនាំសាលា និងទាញយកប្រយោជន៍នៃឱកាសសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។

**៧៤. យុទ្ធសាស្រ្តចង្អុលបង្ហាញ៖**

- រៀបចំយុទ្ធសាស្ត្រទាក់ទងនឹងយេនឌ័រ ដើម្បីទាក់ទាញបេក្ខជនដែលល្អបំផុត និងមានការលើទឹកចិត្តបំផុតលើការបង្រៀន និងធានាថាពួកគេត្រូវបានដាក់ពង្រាយនៅកន្លែងដែលត្រូវការពួកគេបំផុត។ នេះរួមមានគោលនយោបាយ និងវិធានការផ្លូវច្បាប់ដើម្បីធ្វើឲ្យមានការទាក់ទាញវិជ្ជាជីវៈបង្រៀនដល់បុគ្គលិកបច្ចុប្បន្នដែលមានសក្តានុពល ដោយការកែលម្អលក្ខខ័ណ្ឌការងារ ការធានាផលប្រយោជន៍ សន្តិសុខសង្គម និងការធានាថាប្រាក់ខែរបស់គ្រូបង្រៀន និងបុគ្គលិកអប់រំផ្សេងទៀតនោះ គឺយ៉ាងហោចណាស់ស្មើគ្នាប្រៀបធៀប

ទៅនឹងអ្នកដែលចាប់យកអាជីពដទៃទៀត ដែលមានតម្រូវការស្រដៀងគ្នា ឬលក្ខណៈសម្បត្តិដែលមានតម្លៃស្មើ។

- ពិនិត្យឡើងវិញ វិភាគ និងកែលម្អគុណភាពនៃការបណ្តុះបណ្តាលគ្រូ (មុនសេវាកម្ម និងនៅក្នុងសេវាកម្ម) និងផ្តល់ឲ្យគ្រូទាំងអស់ ប្រកបដោយគុណភាពនៅមុនសេវាកម្ម និងការអភិវឌ្ឍវិជ្ជាជីវៈជាបន្តបន្ទាប់ និងការគាំទ្រ។
- រៀបចំក្របខ័ណ្ឌគុណវុឌ្ឍិសម្រាប់គ្រូ គ្រូឧទ្ទេស អ្នកគ្រប់គ្រងគ្រូ និងអ្នកអធិការកិច្ច។
- រៀបចំ និងអនុវត្តគោលនយោបាយគ្រប់គ្រងគ្រូបង្រៀនប្រកបដោយសមភាពបរិយាប័ន្ន និងយេនឌ័រដែលគ្របដណ្តប់លើការជ្រើសរើស ការបណ្តុះបណ្តាល ការដាក់ពង្រាយ ប្រាក់ខែ អភិវឌ្ឍន៍អាជីព លក្ខខ័ណ្ឌការងារ និងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃគ្រូបង្រៀន អ្នកអប់រំ និងគុណភាពនៃការបង្រៀន។
- ផ្តល់ដល់គ្រូបង្រៀនជាមួយនឹងជំនាញបច្ចេកវិទ្យាគ្រប់គ្រាន់ ដើម្បីការគ្រប់គ្រងបណ្តាញសង្គម និងវិស័យ ICT ក៏ដូចជាជំនាញវាយតម្លៃប្រភព អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងផ្តល់នូវការបណ្តុះបណ្តាលស្តីពីរបៀបដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សិស្សដែលមានតម្រូវការអប់រំពិសេស។
- រៀបចំ និងអនុវត្តប្រព័ន្ធទទួលមតិត្រឡប់ប្រកបដោយប្រសិទ្ធិភាព ដើម្បីគាំទ្រដល់ការបង្រៀនបានល្អ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀនដែលធានាថាការបណ្តុះបណ្តាលមានផលប៉ះពាល់ជាវិជ្ជមានលើការងាររបស់គ្រូបង្រៀន។
- ពង្រឹងភាពជាអ្នកដឹកនាំតាមសាលារៀន ដើម្បីធ្វើឲ្យការបង្រៀន និងការរៀនមានភាពប្រសើរឡើង។
- បង្កើត ឬ ពង្រឹងយន្តការសម្រាប់បង្កើតកិច្ចពិភាក្សាសង្គមតាមស្ថាប័ន ជាមួយនឹងគ្រូបង្រៀន និងអ្នកតំណាងស្ថាប័នរបស់ពួកគេ ដើម្បីធានាថាមានការចូលរួមយ៉ាងពេញលេញនៅក្នុងការអភិវឌ្ឍ ការពិនិត្យ និងការវាយតម្លៃលើគោលនយោបាយអប់រំ។

## សូចនាករ

៧៥. សូចនាករចំនួនបួនកម្រិតត្រូវបានស្នើឡើង៖

- **ថ្នាក់សកល:** ការបង្កើតសូចនាករមួយផ្នែកតូចដើម្បីប្រៀបធៀបជាសកលសម្រាប់គោលដៅអភិវឌ្ឍដោយចីរភាពរួមទាំងគោលដៅអភិវឌ្ឍដោយចីរភាពទី៤ ស្តីពីការអប់រំដែលត្រូវបានរៀបចំឡើងតាមរយៈដំណើរការពិគ្រោះ យោបល់ដែលដឹកនាំដោយគណៈកម្មាធិការស្ថិតិរបស់អង្គការសហប្រជាជាតិដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅរកចំណុចដៅដែលទាក់ទង។
- **តាមប្រធានបទ:** ការបង្កើតសូចនាករមួយទូលំទូលាយជាងមុនដើម្បីប្រៀបធៀបជាសកល ដែលស្នើដោយសហគមន៍វិស័យអប់រំ ដើម្បីតាមដានចំណុចដៅអប់រំឲ្យបានទូលំទូលាយថែមទៀតតាមបណ្តាប្រទេសនានា និងរួមបញ្ចូលទាំងសូចនាករថ្នាក់សកលផងដែរ។
- **ថ្នាក់តំបន់:** សូចនាករបន្ថែមទៀតដែលអាចត្រូវបានបង្កើតឡើងដោយយកចិត្តទុកដាក់លើបរិបទថ្នាក់តំបន់ជាក់លាក់ និងអាទិភាពនៃគោលនយោបាយដែលពាក់ព័ន្ធ សម្រាប់ផ្នត់គំនិតដែលមានការកែ

សម្រួលតិចតួចទៅនឹងការប្រៀបធៀបជាសកល។

- **ថ្នាក់ជាតិ៖** សូចនាករដែលបានជ្រើសរើស ឬបង្កើតឡើងដោយប្រទេសទាំងឡាយ ដែលមានយកចិត្តទុកដាក់លើបរិបទថ្នាក់ជាតិ និងឆ្លើយតបទៅនឹងរបៀបវារៈប្រព័ន្ធអប់រំផែនការ និងគោលនយោបាយរបស់ពួកគេ។

៧៦. សូចនាករតាមប្រធានបទមួយចំនួន ត្រូវរៀបចំដោយក្រុមប្រឹក្សាយោបល់ផ្នែកបច្ចេកទេស ស្របតាមការពិគ្រោះយោបល់ជាសាធារណៈយ៉ាងទូលំទូលាយ ដែលមាននៅក្នុងឧបសម្ព័ន្ធ២។ វាផ្អែកលើលក្ខណៈវិនិច្ឆ័យចំនួនប្រាំគឺៈ ភាពពាក់ព័ន្ធ ការសម្របតាមគោលគំនិតនៅក្នុងគោលដៅ លទ្ធភាពសម្រាប់ការប្រមូលទិន្នន័យអាចធ្វើបានដោយទៀងទាត់តាមប្រទេស (ប៉ុន្តែមិនចាំបាច់ប្រមូលប្រចាំឆ្នាំទេ) ភាពងាយស្រួលក្នុងការទំនាក់ទំនងទៅអ្នកចូលរួមជាសកល និងលទ្ធភាពដែលអាចឲ្យយកទៅបកប្រែបាន។ សម្រាប់ចំណុចដៅមួយចំនួន សូចនាករដែលរឹងមាំគឺអាចរកបានរួចជាស្រេចសម្រាប់បណ្តាប្រទេសមួយចំនួនធំ។ សម្រាប់ប្រទេសមួយចំនួនទៀតទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងសម្រាប់អភិវឌ្ឍន៍វិធីសាស្ត្ររបស់សូចនាករ និង/ឬ ត្រូវអភិវឌ្ឍន៍សមត្ថភាពប្រទេសទាំងឡាយដើម្បីប្រមូល និងប្រើប្រាស់ទិន្នន័យ។ ជាពិសេស កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់សកលដើម្បីបំពេញតម្រូវការចាំបាច់សម្រាប់វាស់វែងសមធម៌ និងការអប់រំបរិយាប័ន្ន ក៏ដូចជាលទ្ធផលសិក្សា និងគុណភាពដែរ (សម្រាប់បំណែងចែកទិន្នន័យតាមក្រុមប្រជាជនដែលជាជនងាយរងគ្រោះគឺសំខាន់ណាស់) សូចនាករទាំងនេះនឹងត្រូវបានតាមដាន យោងតាមភាពពាក់ព័ន្ធរបស់ពួកគេដោយផ្អែកលើបរិបទប្រទេស សមត្ថភាព និងលទ្ធភាពទិន្នន័យដែលអាចមាន។

# III. បែបបទនៃការអនុវត្ត

៧៧. ការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ នឹងតម្រូវឲ្យមានយន្តការថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលសម្រាប់អភិបាលកិច្ច គណនេយ្យភាព ការសម្របសម្រួល ការពិនិត្យ ការតាមដាននិងការពិនិត្យឡើងវិញ ការរាយការណ៍ និងការវាយតម្លៃ។ ក៏តម្រូវផងដែរឲ្យមានយុទ្ធសាស្ត្រ រួមទាំងភាពជាដៃគូ និងការផ្តល់ហិរញ្ញប្បទានផងដែរ។ **គោលបំណងសំខាន់នៃយន្តការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ គឺគាំទ្រដល់សកម្មភាពថ្នាក់ជាតិ។** ដើម្បីធ្វើឲ្យមានប្រសិទ្ធិភាពបំផុត យន្តការទាំងនេះនឹងត្រូវដាក់បញ្ចូលឲ្យមានការចូលរួម និងប្រកបដោយតម្លាភាព។ គេនឹងបន្តកសាងយន្តការដែលមានស្រាប់ចំពោះវិសាលភាពដែលអាចធ្វើទៅបាន។

## អភិបាលកិច្ច គណនេយ្យភាព និងភាពជាដៃគូ

៧៨. ចំណុចសំខាន់នៃវិស័យអប់រំឆ្នាំ២០៣០ ស្ថិតនៅថ្នាក់ជាតិ។ **រដ្ឋាភិបាល**ទាំងឡាយមានការទទួលខុសត្រូវជាចម្បងដើម្បីផ្តល់ជូនសិទ្ធិទទួលបានការអប់រំ និងតួនាទីសំខាន់ជាការរក្សាប្រសិទ្ធិភាព ការគ្រប់គ្រង និងការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំសាធារណៈដោយសមភាព និងប្រកបដោយប្រសិទ្ធិភាព។ គេគប្បីរក្សានិរន្តរភាពដល់ការដឹកនាំនយោបាយលើវិស័យអប់រំ និងត្រួសត្រាយដំណើរការនៃបរិបទ និងការអនុវត្តគោលដៅវិស័យអប់រំឆ្នាំ២០៣០ និងចំណុចដៅដ៏ទៃទៀត ផ្អែកលើបទពិសោធន៍ និងអាទិភាពថ្នាក់ជាតិ ស្របពេលជាមួយនឹងការធានាឲ្យបាននូវដំណើរការប្រកបដោយតម្លាភាព និងឲ្យមានការដាក់បញ្ចូលជាមួយដៃគូសំខាន់ដ៏ទៃទៀត។ តួនាទីរបស់រដ្ឋគឺមានសារៈសំខាន់ណាស់ក្នុងការកំណត់បទដ្ឋាន កែលម្អគុណភាព និងកាត់បន្ថយវិសមភាពរវាងថ្នាក់តំបន់ សហគមន៍ និងសាលារៀន។ រដ្ឋាភិបាលគួរតែដាក់បញ្ចូលផែនការអប់រំទៅក្នុងការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍដោយចីរភាព និងការឆ្លើយតបផ្នែកមនុស្សធម៌ដែលធានាថាគោលនយោបាយគឺត្រូវស្របគ្នាជាមួយនឹងកាតព្វកិច្ចស្របច្បាប់របស់រដ្ឋាភិបាល ដើម្បីគោរពការពារ និងបំពេញសិទ្ធិទទួលបានការអប់រំ។

៧៩. រយៈពេលជាង១៥ឆ្នាំទៀតនឹងដល់ឆ្នាំ២០៣០ ដំណើរការធ្វើសេចក្តីសម្រេចចិត្តនៃប្រជាធិបតេយ្យភាវូបនីយកម្មត្រូវបានរំពឹងថា មានការកើនឡើងដោយបានឆ្លុះបញ្ចាំងសម្លេង និងអាទិភាពរបស់ពលរដ្ឋទៅក្នុងការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយអប់រំគ្រប់កម្រិត។ ការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ អាចទទួលបានផលប្រយោជន៍ពីការគាំទ្រនៃភាពជាដៃគូយ៉ាងរឹងមាំដែលនាំមកនូវការបំពេញការងារទាំងអស់រួមគ្នា ដែលជាការចូលរួមចំណែក និងធ្វើសកម្មភាពដ៏មានសក្តានុពលដែលបានបញ្ជាក់ដូចខាងក្រោម។ ភាពជាដៃគូគ្រប់កម្រិតទាំងអស់ត្រូវបានណែនាំដោយគោលនយោបាយនៃការបើកចំហរកិច្ចពិភាក្សាស្តីពីគោលនយោបាយបែបបទបរិយាប័ន្ន និងការចូលរួម ព្រមទាំងការទទួលខុសត្រូវ តម្លាភាព និងកិច្ចសហការទៅវិញទៅមក។ ការចូលរួមត្រូវចាប់ផ្តើមដោយមានការរួមចំណែកពីក្រុមគ្រួសារ និងសហគមន៍ទាំងឡាយដើម្បីជម្រុញឲ្យមានតម្លាភាព និងដើម្បីធានាឲ្យបាននូវអភិបាលកិច្ចល្អនៅក្នុងរដ្ឋបាលអប់រំ។ ការទទួលខុសត្រូវដែលកើនឡើងនៅសាលារៀនអាចពង្រឹងប្រសិទ្ធិភាពក្នុងការផ្តល់សេវាកម្ម។

៨០. **អង្គការសង្គមស៊ីវិល**(CSOs) រួមទាំងអ្នកតំណាង សម្ព័ន្ធ និងបណ្តាញការងារធំៗ បានដើរតួនាទីយ៉ាងសំខាន់។ ពួកគេត្រូវមានតួនាទីចូលរួមក្នុងគ្រប់ដំណាក់កាលគិតចាប់ពីការរៀបចំផែនការរហូតដល់ការត្រួតពិនិត្យ និងការវាយតម្លៃ ដោយមានការរួមចំណែកជាលក្ខណៈស្ថាប័ន និងធានាឲ្យបាន។ អង្គការសង្គមស៊ីវិល អាចៈ

- ជម្រុញឲ្យមានការប្រមូលផ្តុំក្នុងសង្គម និងបង្កើនការយល់ដឹងជាសាធារណៈ ធ្វើឱ្យមានសម្លេងរបស់ប្រជាពលរដ្ឋ (ជាពិសេសអ្នកដែលប្រឈមមុខនឹងការរើសអើង) ចូលទៅក្នុងការអភិវឌ្ឍគោលនយោបាយ។
- បង្កើតឲ្យមានការច្នៃប្រឌិតថ្មី និងវិធីសាស្ត្របំពេញបន្ថែមដែលជួយជម្រុញសិទ្ធិទទួលបានការអប់រំ ជាពិសេសសម្រាប់ក្រុមដែលគេផាត់ចេញ ។
- ចងក្រងឯកសារ និងចែករំលែកភស្តុតាងពីការអនុវត្ត ផ្អែកលើការវាយតម្លៃរបស់ពលរដ្ឋ និងពីការស្រាវជ្រាវដើម្បីប្រាប់ដល់កិច្ចពិភាក្សាលើគោលនយោបាយ ក៏ដូចជាធ្វើឲ្យរដ្ឋាភិបាលមានការទទួលខុសត្រូវ តាមដាន

វឌ្ឍនភាព ការតស៊ូមតិផ្អែកលើភស្តុតាង ពិនិត្យការចំណាយ និងធានាឲ្យបាននូវតម្លាភាពក្នុងអភិបាលកិច្ចវិស័យអប់រំ និងការផ្តល់ថវិកា។

៨១. **គ្រូបង្រៀន អ្នកអប់រំ** និងស្ថាប័នរបស់ពួកគេ គឺជាដៃគូសំខាន់ណាស់ក្នុងសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគេ ហើយគួរត្រូវបានចូលរួមគ្រប់ដំណាក់កាលទាំងអស់ ក្នុងការធ្វើគោលនយោបាយ ការរៀបចំផែនការ ការអនុវត្ត និងការ ពិនិត្យតាមដាន។ គ្រូបង្រៀន និងបុគ្គលិកគាំទ្រវិស័យអប់រំអាចៈ

- ប្រើប្រាស់ជំនាញវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តរបស់ខ្លួនដើម្បីធានាថាសិស្សទទួលបានការអប់រំ
- នាំមកនូវតថភាពជាក់ស្តែងរបស់ថ្នាក់រៀន ដើម្បីកិច្ចពិភាក្សាគោលនយោបាយឈានមុខ ការបង្កើតគោលនយោបាយ និងរៀបចំផែនការ ហើយផ្តល់ជូនជាស្ពានចម្លងរវាងគោលនយោបាយ និងការអនុវត្ត ការចូលរួមរំលែកបទពិសោធន៍របស់ពួកគេដែលជាអ្នកអនុវត្ត និងយល់ដឹងយ៉ាងទូលំទូលាយ និងជំនាញរបស់ពួកគេចំពោះគោលនយោបាយ និងយុទ្ធសាស្ត្រទាំងមូល។
- ជម្រុញឲ្យមានការអប់រំបរិយាប័ន្ន គុណភាព និងសមភាព ហើយកែលម្អកម្មវិធីសិក្សានិងគរុកោសល្យ។

៨២. **វិស័យឯកជន និងស្ថាប័នផ្តល់មូលនិធិ** អាចដើរតួនាទីយ៉ាងសំខាន់ដោយប្រើប្រាស់បទពិសោធន៍ វិធីសាស្ត្របង្កើតថ្មី ជំនាញអាជីវកម្ម និងធនធានហិរញ្ញវត្ថុរបស់ពួកគេ ដើម្បីពង្រឹងវិស័យអប់រំសាធារណៈ។ ពួកគេអាចចូលរួមចែករំលែកក្នុងការអប់រំ និងការអភិវឌ្ឍតាមរយៈភាពជាដៃគូ ឬពហុភាគី ការវិនិយោគទុន និងការចូលរួមចំណែកដែលមានតម្លាភាពស្របតាមអាទិភាពថ្នាក់តំបន់ និងថ្នាក់ជាតិដោយគោរពការអប់រំដូចជាសិទ្ធិមនុស្សដែរ ហើយមិនបង្កើនវិសមភាព។ លើសពីនេះទៅទៀតពួកគេអាចៈ

- ប្រមូលផ្តុំធនធានបន្ថែមទៀតសម្រាប់វិស័យអប់រំសាធារណៈ រួមបញ្ចូលទាំងការបង់ពន្ធដ៏ត្រឹមត្រូវ និងប្រើប្រាស់ធនធានទាំងនោះលើផ្នែកដែលជាអាទិភាព។
- ជួយដល់អ្នករៀបចំផែនការវិស័យអប់រំ និងបណ្តុះបណ្តាលជំនាញឲ្យយល់ដឹងពីនិន្នាការទីផ្សារការងារ និងតម្រូវការជំនាញដោយជួយសម្រួលប្រតិបត្តិការសាលារៀនដើម្បីធ្វើការងារ និងចូលរួមចំណែកដល់វិធីសាស្ត្រដែលមានការច្នៃប្រឌិតថ្មីដើម្បីដោះស្រាយបញ្ហាប្រឈមរបស់វិស័យអប់រំ។
- បង្កើនឱកាសអប់រំបន្ថែមទៀត ដោយផ្តល់ជូនសេវាកម្ម និងសកម្មភាពបន្ថែមដើម្បីឈានដល់ឱកាសច្រើនបំផុតនៅក្នុងក្របខ័ណ្ឌនៃស្តង់ដារ និងបទដ្ឋានដែលបានធ្វើនិយ័តកម្មដោយប្រទេស។

៨៣. **សហគមន៍ស្រាវជ្រាវ** មានការចូលរួមចំណែកយ៉ាងសំខាន់ ដើម្បីធ្វើការអភិវឌ្ឍវិស័យអប់រំជាទូទៅ និងកិច្ចពិភាក្សាគោលនយោបាយ។ សហគមន៍ស្រាវជ្រាវអាចៈ

- បង្កើតការស្រាវជ្រាវដែលពាក់ព័ន្ធនឹងគោលនយោបាយ រួមទាំងការស្រាវជ្រាវដែលផ្សារភ្ជាប់នឹងការអនុវត្តដើម្បីជួយសម្រួលដល់ការសម្រេចបាននូវគោលដៅ និងធ្វើឲ្យមានការយល់ដឹងលើវិស័យអប់រំមានស្រាប់នៅក្នុងទម្រង់ដែលអាចប្រើបានសម្រាប់អ្នកបង្កើតគោលនយោបាយ។
- អភិវឌ្ឍន៍សមត្ថភាពថ្នាក់តំបន់ និងថ្នាក់ជាតិប្រកបដោយនិរន្តរភាព សម្រាប់ការស្រាវជ្រាវទាំងគុណភាព និងបរិមាណ។
- ជួយឲ្យមានការរីកចម្រើន ស្នើសុំជម្រើសឬដំណោះស្រាយ និងកំណត់ឲ្យមានការអនុវត្តល្អបំផុតប្រកបដោយការច្នៃប្រឌិតថ្មី អាចពង្រីកបាន និងអាចផ្ទេរបាន។

៨៤. **យុវជន** សិស្ស និងស្ថាប័នរបស់ពួកគេ គឺជាដៃគូយ៉ាងសំខាន់ជាមួយនឹងជំនាញជាក់លាក់មួយដែលជាក្រុមគោលដៅដ៏សំខាន់នៃវិស័យអប់រំឆ្នាំ២០៣០។ ដូច្នេះពួកគេអាចត្រូវបានដាក់ឲ្យកំណត់នូវតម្រូវការរបស់ខ្លួនដើម្បីធ្វើឲ្យប្រសើរឡើងនៃការសិក្សាដែលជាអ្នករៀនយ៉ាងសកម្ម និងមានការទទួលខុសត្រូវ។ កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីធានាពីភាពជាតំណាង និងការចូលរួមយ៉ាងសកម្មរបស់ពួកគេ។ ពួកគេអាចៈ

- ជម្រុញរដ្ឋាភិបាល និងដៃគូដ៏ទៃទៀតឲ្យមានការអភិវឌ្ឍកម្មវិធីអប់រំសម្រាប់មនុស្សវ័យជំទង់ដោយប្រឹក្សាយោបល់ជាមួយពួកគេ ពិសេសជាមួយយុវជនដែលងាយរងគ្រោះ និងបាត់បង់ឱកាសដើម្បីឆ្លើយតបឲ្យបានប្រសើរដល់តម្រូវការ និងសេចក្តីប្រាថ្នារបស់ពួកគេ។
- ជួយកំណត់គោលនយោបាយដែលជម្រុញឲ្យមានប្រព័ន្ធអប់រំបែបពាក់ព័ន្ធនិងឆ្លើយតប ហើយជម្រុញឲ្យមានកិច្ចប្រតិបត្តិការយ៉ាងរលូនពីវិស័យអប់រំ និងការបណ្តុះបណ្តាល ដើម្បីការងារសមរម្យ និងជីវិតមនុស្សពេញវ័យ។
- ចូលរួមកិច្ចពិភាក្សាជាមួយមនុស្សជំនាន់ខុសៗគ្នា ធ្វើឲ្យករណីនេះមានការទទួលស្គាល់កុមារ មនុស្សជំទង់ និងយុវជន និងជាពិសេសកុមារី និងស្ត្រីវ័យក្មេង ជាសិទ្ធិសាមីខ្លួន និងជាគូសន្ទនាស្របច្បាប់ក្នុងគោលនយោបាយ និងការអនុវត្តវិស័យអប់រំគ្រប់កម្រិត។

៨៥. ភាពជោគជ័យនៃវិស័យអប់រំឆ្នាំ២០៣០ នឹងផ្អែកលើកិច្ចប្រឹងប្រែងរួមគ្នា។ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយដែលជម្រុញឲ្យមានគណនេយ្យភាព និងតម្លាភាព ក៏ដូចជាអភិបាលកិច្ចដែលមានការចូលរួមសម្របសម្រួលភាពជាដៃគូគ្រប់កម្រិត និងគ្រប់វិស័យ ការលើកកម្ពស់សិទ្ធិក្នុងការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ នឹងត្រូវបានបង្កើតឡើង ឬអភិវឌ្ឍន៍បន្ថែម។ មានការចាំបាច់សម្រាប់ដៃគូទាំងអស់ ដើម្បីប្រកាន់យកទស្សនៈវិស័យអប់រំឆ្នាំ ២០៣០ ដែលបានគូសបញ្ជាក់នៅក្នុងក្របខ័ណ្ឌសម្រាប់ធ្វើសកម្មភាពនេះ និងដើម្បីទទួលខុសត្រូវៈ ស្ថាប័នពហុភាគីគួរមានការទទួលខុសត្រូវចំពោះរដ្ឋជាសមាជិករបស់ពួកគេ ក្រសួងអប់រំ និងក្រសួងពាក់ព័ន្ធដ៏ទៃទៀតចំពោះមុខពលរដ្ឋ ម្ចាស់ជំនួយ រដ្ឋាភិបាលជាតិ ពលរដ្ឋ សាលារៀន គ្រូបង្រៀន សហគមន៍អប់រំ និងទទួលខុសត្រូវកាន់តែទូលំទូលាយបន្ថែមទៀតចំពោះប្រជាពលរដ្ឋ។

## ការសម្របសម្រួលមានប្រសិទ្ធិភាព

៨៦. ខណៈពេលមានការដឹកនាំពីក្រសួងអប់រំទាំងឡាយ ការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពវិស័យអប់រំ និងចំណុចដៅទាក់ទងនឹងវិស័យអប់រំនៅក្នុង SDGs ដ៏ទៃទៀតនៅថ្នាក់ប្រទេស តម្រូវឲ្យ"រដ្ឋាភិបាលទាំងមូល" មានវិធីសាស្ត្រចំពោះវិស័យអប់រំ។ វិស័យអប់រំដើរតួនាទីក្នុងការបណ្តុះឲ្យមានចំណេះដឹងដោយផ្អែកលើសង្គម និងបញ្ឈប់ការកើនឡើងនៃវិសមភាព ក៏ដូចជាការផ្តោតសំខាន់សាជាថ្មីលើការរៀនសូត្រពេញមួយជីវិតនៅក្នុងរបៀបវារៈវិស័យអប់រំថ្មីត្រូវមានតម្រូវការសម្រាប់ភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការរួបរួមគ្នាដ៏រឹងមាំជាមួយរដ្ឋាភិបាលដែលផ្តោតលើការអភិវឌ្ឍវិស័យអប់រំ និងការធ្វើសមាហរណកម្មរបស់ខ្លួនទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ប្រទេសដែលដឹកនាំសកម្មភាពនឹងជម្រុញឲ្យមានការផ្លាស់ប្តូរ ទោះជាគោលដៅអប់រំប្រកបដោយមហិច្ឆតា មិនអាចសម្រេចបានដោយរដ្ឋាភិបាលតែម្នាក់ឯងបានឡើយ។ គេនឹងត្រូវការការគាំទ្ររបស់ភាគីដែលពាក់ព័ន្ធ រួមទាំងស្ថាប័នដែលមិនមែនជារបស់រដ្ឋ។ រដ្ឋាភិបាលគួរបង្កើតយន្តការសមស្រប

និងពង្រឹងយន្តការដែលមានស្រាប់ ឲ្យក្លាយជាប្រភពចម្បងនៃព័ត៌មានសម្រាប់ដំណើរការត្រួតពិនិត្យក្នុងតំបន់ និងជាសកល ដោយមានការគាំទ្រពីអង្គការសហប្រជាជាតិ។ គេក៏ត្រូវបង្កើតនីតិវិធីដើម្បីដឹកនាំសម្របសម្រួល និងជម្រុញឲ្យមានអន្តរាគមន៍សម្រាប់ការអភិវឌ្ឍវិស័យអប់រំគ្រប់កម្រិត និងគ្រប់ផ្នែក ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំផែនការ ការអនុវត្ត ការពិនិត្យគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំ។ លើសពីនេះទៅទៀត ដើម្បីជានាភាពជាម្ចាស់ប្រទេស ប្រទេសទាំងឡាយនឹងធ្វើការសម្របសម្រួលឲ្យមានជំនួយពីខាងក្រៅដែលផ្តល់ជូនដោយទីភ្នាក់ងារចាត់ចែងកិច្ចប្រជុំ និងទីភ្នាក់ងារពហុភាគី និងទ្វេភាគីដទៃទៀត។

៨៧. ក្នុងពេលជាមួយគ្នានេះដែរ កិច្ចប្រឹងប្រែងរួមគ្នានៅថ្នាក់តំបន់ និងថ្នាក់អនុតំបន់មានសារៈសំខាន់ណាស់ ដើម្បីសម្រេចបានជោគជ័យ និងការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ នៅថ្នាក់ជាតិ និងថ្នាក់តំបន់។ កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងថ្នាក់អនុតំបន់នឹងប្រព្រឹត្តទៅក្នុងដំណើរការថ្នាក់តំបន់ និងយន្តការសម្រាប់ការសម្របសម្រួលយ៉ាងទូលំទូលាយនិងការពិនិត្យរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព។ ទាំងនេះគួរបង្កើតឡើងលើភាពជាដៃគូក្នុងក្របខ័ណ្ឌនានា និងយន្តការប្រកបដោយប្រសិទ្ធិភាពដែលមានស្រាប់ ក៏ដូចជាការបង្កើតថ្មីមួយ ដើម្បីធានាឲ្យមានកិច្ចសហការ ប្រតិបត្តិការ ការសម្របសម្រួល និងការពិនិត្យនៃការអនុវត្តរបៀបវារៈវិស័យអប់រំក្នុងតំបន់ឲ្យបានរឹងមាំ។ ដំណើរការនេះអាចរួមបញ្ចូលទាំងការបង្កើតគោលនយោបាយនានាក្នុងតំបន់ ដែលមានការពាក់ព័ន្ធ និងមានភាពសមស្រប។ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌថ្នាក់តំបន់ដែលបានបង្កើតឡើងនាពេលបច្ចុប្បន្ន រួមទាំងរបៀបវារៈរបស់សហភាពអាហ្វ្រិក ២០៦៣ រួមមាន៖ យុទ្ធសាស្ត្រអាហ្វ្រិកដែលយើងចង់បាន និងវិស័យអប់រំប្រចាំទ្វីបសម្រាប់ឆ្នាំ២០១៦-២០២៥ យុទ្ធសាស្ត្រអប់រំរបស់អង្គការអប់រំ វប្បធម៌ វិទ្យាសាស្ត្រសម្ព័ន្ធអារ៉ាប់ យុទ្ធសាស្ត្រអឺរ៉ុបឆ្នាំ២០២០របស់សហភាពអឺរ៉ុប ក្របខ័ណ្ឌរបស់ក្រុមប្រឹក្សាអឺរ៉ុបស្តីពីសមត្ថភាពសម្រាប់កិច្ចពិភាក្សាទាក់ទងនឹងវប្បធម៌ ប្រជាធិបតេយ្យ និងអន្តរវប្បធម៌ គម្រោងអប់រំថ្នាក់តំបន់សម្រាប់វិស័យអប់រំនៅអាមេរិកឡាទីន និងតំបន់ការ៉ាប៊ីន និងសមាគមនៃទស្សនៈសហគមន៍ជាតិអាស៊ីអាគ្នេយ៍ ឆ្នាំ២០២៥។ តួនាទី និងសកម្មភាពជាក់លាក់នៃយន្តការថ្នាក់តំបន់ គួរដាក់ចេញក្នុងឆ្នាំ២០១៦ ដោយផ្តោតទៅលើលទ្ធផលនៃសន្និសីទរដ្ឋមន្ត្រីថ្នាក់តំបន់ស្តីពីការអប់រំក្រោយឆ្នាំ២០១៥។

៨៨. កិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារចាត់ចែងវេទិកាអប់រំពិភពលោកឆ្នាំ ២០១៥ (WEF ២០១៥) (**UNESCO, UNDP, UNFPA, UNHCR, UNICEF, UN Women និងធនាគារពិភពលោក**) ស្ថាប័នថ្នាក់តំបន់ និងស្ថាប័នអន្តររដ្ឋាភិបាលក៏ដូចជាសហគមន៍ថ្នាក់តំបន់ និងថ្នាក់អនុតំបន់នឹងជួយក្នុងការដោះស្រាយបញ្ហាប្រឈមរួមស្របពេលគ្នា។ អង្គការយូណេស្កូ តាមរយៈការិយាល័យប្រចាំតំបន់របស់ខ្លួន នឹងរួមគ្នាជាមួយនឹងអ្នកចាត់ចែងវេទិកាអប់រំពិភពលោកឆ្នាំ២០១៥ នឹងលើកកម្ពស់ការចែករំលែកចំណេះដឹងក៏ដូចជាការអនុវត្តន៍គោលនយោបាយដែលមានប្រសិទ្ធិភាពនៅទូទាំងតំបន់ទាំងឡាយ។ វេទិកាឆ្លងតំបន់សម្រាប់ការអប់រំសិទ្ធិមនុស្ស និងវគ្គបណ្តុះបណ្តាល និងរួមចំណែកក្នុងការខិតខំប្រឹងប្រែងនេះ។

៨៩. ការសម្របសម្រួលក្នុងតំបន់ដែលមានភាពរួមបញ្ចូលគ្នា និងប្រកបដោយប្រសិទ្ធិភាព នឹងផ្តោតទៅលើទិដ្ឋភាពមួយចំនួនដូចជាការប្រមូលទិន្នន័យ និងការពិនិត្យរួមទាំងការពិនិត្យពីបណ្តាប្រទេសជាមិត្តការសិក្សា និងការផ្លាស់ប្តូរការអនុវត្តល្អរួមគ្នាការបង្កើតគោលនយោបាយ កិច្ចពិភាក្សា និងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ កិច្ចប្រជុំផ្លូវការ និងព្រឹត្តិការណ៍កម្រិតខ្ពស់យុទ្ធសាស្ត្រទំនាក់ទំនងថ្នាក់តំបន់ការប្រមូលផ្តុំធនធានការតស៊ូមតិ និងការកសាង សមត្ថភាព និងការអនុវត្តគម្រោងរួមគ្នា។

៩០. ខណៈដែលរដ្ឋាភិបាលមានការទទួលខុសត្រូវជាចម្បងសម្រាប់ការអនុវត្ត ការតាមដានត្រួតពិនិត្យដោយជោគជ័យលើរបៀបវារៈ SDG **អង្គការសហប្រជាជាតិ**ដ៏មានការទទួលខុសត្រូវ ជាពិសេសក្នុងការសម្របសម្រួលរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាពនៅកម្រិតសកលលោកស្ថិតក្រោមការត្រួតពិនិត្យ និងការណែនាំយ៉ាងជិតដល់ពីរដ្ឋជាសមាជិករបស់ខ្លួន។ អង្គការសហប្រជាជាតិដែលមានបំណងស្រដៀងក្នុងការផ្តល់ជូននូវរបៀបវារៈ នៃការអភិវឌ្ឍថ្មី នឹងត្រូវជម្រុញឲ្យមានកិច្ចប្រតិបត្តិការ និងកិច្ចសហការក្នុងចំណោមទីភ្នាក់ងាររបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងការភ្ជាប់ទំនាក់ទំនងគ្នាតាមធម្មតា ការកំណត់ស្តង់ដារ និងទំហំប្រតិបត្តិការនៃការងាររបស់ខ្លួន។

៩១. ស្ថាប័នចាត់ចែងវេទិកាអប់រំពិភពលោក ២០១៥ ជាពិសេសអង្គការយូណេស្កូ ក៏ដូចជាដៃគូដ៏ទៃទៀត រួមទាំងដៃគូជាសកលសម្រាប់ការអប់រំ (GPE) ជាវេទិកាផ្តល់ហិរញ្ញប្បទានរបស់សហភាគីពាក់ព័ន្ធ នឹងគាំទ្រដល់ប្រទេសទាំងឡាយដោយឡែក និងជារួម ក្នុងការអនុវត្តវិស័យអប់រំឆ្នាំ២០៣០ ដោយផ្តល់ជូនការណែនាំផ្នែកបច្ចេកទេស ការអភិវឌ្ឍសមត្ថភាពថ្នាក់ជាតិ ថ្នាក់តំបន់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុក៏ដូចជាការគាំទ្រសម្រាប់ការពិនិត្យដោយផ្អែកលើអាណត្តិរៀងៗខ្លួន និងផលប្រយោជន៍ដែលមានការប្រៀបធៀបក្នុងវិធីបំពេញបន្ថែមរបស់ពួកគេ។

**៩២.** **អង្គការយូណេស្កូ** ជាទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិដែលមានឯកទេសជំនាញវិស័យអប់រំនឹងបន្តតួនាទីនៅក្នុងអាណត្តិរបស់ខ្លួនដើម្បីដឹកនាំ និងសម្របសម្រួលរបៀបវារៈវិស័យអប់រំឆ្នាំ២០៣០ ជាពិសេសដោយៈ

- ធ្វើការតស៊ូមតិដើម្បីរក្សាការប្តេជ្ញាចិត្តខាងនយោបាយ
- ធ្វើការអភិវឌ្ឍសមត្ថភាព
- សម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយការចែករំលែកចំណេះដឹង ការកំណត់ស្តង់ដារ និងការផ្តល់ជូនការណែនាំពីគោលនយោបាយ
- លើកកម្ពស់កិច្ចប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នាដែលត្រូវបានទទួលការគាំទ្រពីប្រទេសអភិវឌ្ឍហើយ (South-South និង triangular cooperation)
- ពិនិត្យវឌ្ឍនភាពឆ្ពោះទៅកាន់ចំណុចដៅអប់រំជាពិសេសតាមរយៈការងាររបស់ UIS និងការពិនិត្យរបាយការណ៍អប់រំជាសកល(GEM)
- កោះប្រជុំភាគីពាក់ព័ន្ធជាសកល តំបន់ និងជាតិ ដើម្បីណែនាំពីការអនុវត្តរបៀបវារៈវិស័យអប់រំឆ្នាំ២០៣០។
- មានមុខងារជាផ្នែកមួយសម្រាប់ការអប់រំនៅក្នុងរបៀបវារៈឆ្នាំ២០៣០ ទាំងមូលសម្រាប់រចនាសម្ព័ន្ធសម្របសម្រួលការអភិវឌ្ឍដោយចីរភាព។

  គ្រប់ស្ថាប័នរបស់យូណេស្កូទាំងអស់ រួមទាំងការិយាល័យតាមបណ្តាប្រទេស វិទ្យាស្ថាន ប្រព័ន្ធបណ្តាញការងារ និងវេទិកាពាក់ព័ន្ធ នឹងធ្វើការងារឆ្ពោះទៅរកការអនុវត្តវិស័យអប់រំឆ្នាំ២០៣០។

៩៣. យន្តការសម្របសម្រួលថ្នាក់សកលនៃវិស័យអប់រំឆ្នាំ២០៣០ ធ្វើការអនុវត្តន៍ឲ្យបានទូលំទូលាយជាងរបៀបវារៈឆ្នាំ២០៣០ សម្រាប់ចូលរួមចំណែកការអភិវឌ្ឍដោយចីរភាព គឺជាភាពទូទៅនៃរចនាសម្ព័ន្ធ និងដំណើរការទាក់ទង រួមទាំងគណៈកម្មការដឹកនាំវិស័យអប់រំឆ្នាំ២០៣០ កិច្ចប្រជុំស្តីពីវិស័យអប់រំជាសកល(GEMs) កិច្ចប្រជុំថ្នាក់តំបន់ និងការពិគ្រោះយោបល់រួមគ្នារបស់អង្គការក្រៅរដ្ឋាភិបាល ស្តីពីវិស័យអប់រំសម្រាប់ទាំងអស់

គ្នា(CCNGO)។ យន្តការសម្របសម្រួលនឹងត្រូវបានត្រួតពិនិត្យឡើងវិញតាមរយៈ GEMs និងប្រែប្រួលទៅតាមការចាំបាច់។

៩៤. ដើម្បីធានាឲ្យមានការសម្របសម្រួលជាសកលបានរឹងមាំ យូណេស្កូនឹងកោះប្រជុំពហុភាគីពាក់ព័ន្ធ **គណៈកម្មាធិការដឹកនាំវិស័យអប់រំឆ្នាំ២០៣០ (Education 2030 SC)** ធ្វើការអនុវត្តន៍ឲ្យបានទូលំទូលាយជាងរបៀបវារៈឆ្នាំ២០៣០ សម្រាប់ចូលរួមចំណែកការអភិវឌ្ឍដោយចីរភាព។ គណៈកម្មាធិការដឹកនាំវិស័យអប់រំឆ្នាំ២០៣០ (Education 2030 SC) នឹងគាំទ្រដល់រដ្ឋជាសមាជិក និងដៃគូក្នុងការសម្រេចបាននូវវិស័យអប់រំឆ្នាំ២០៣០។ ចុងបញ្ចប់ក្នុងសកម្មភាពផ្សេងៗទៀត វានឹងផ្តល់ជូនការណែនាំជាយុទ្ធសាស្ត្រ ពិនិត្យការរីកចម្រើនទៅលើ GEMR និងធ្វើការផ្តល់អនុសាសន៍ដល់សហគមន៍អប់រំស្តីពីអាទិភាពជាសំខាន់ និងសកម្មភាពដែលពាក់ព័ន្ធដើម្បីសម្រេចបានរបៀបវារៈថ្មីដូចជា៖ ត្រួតពិនិត្យនិងធ្វើការតស៊ូមតិសម្រាប់ការផ្តល់ហិរញ្ញវត្ថុគ្រប់គ្រាន់ លើកកម្ពស់សុខុដុមរូបនីយកម្មនិងការសម្របសម្រួលនៃសកម្មភាពរបស់ដៃគូ។ សមាសភាពរបស់ គណកម្មការដឹកនាំវិស័យអប់រំឆ្នាំ២០៣០ នឹងបង្កើតឡើងដោយរួមមាន៖

- រដ្ឋជាសមាជិក ដែលនឹងជាសម្លេងភាគច្រើន រួមមានតំណាងរដ្ឋជាសមាជិកចំនួនបី សម្រាប់ក្រុមក្នុងតំបន់ចំនួនប្រាំមួយ និងអ្នកតំណាងមួយរូបរបស់ប្រទេស E-៩ លើមូលដ្ឋានវង្វិលជុំ។
- យូណេស្កូ យូនីសេហ្វ និងធនាគារពិភពលោក មានអសនៈអចិន្ត្រៃយ៍ និងអ្នកតំណាងមួយរូបនៃទីភ្នាក់ងារចាត់ចែងកិច្ចប្រជុំ (UNDP, UNHCR, UNFPA, UN Women) លើមូលដ្ឋានវង្វិលជុំ។
- អ្នកតំណាងមួយរូបរបស់ភាពជាដៃគូសកលសម្រាប់ការអប់រំ ។
- អ្នកតំណាងពីររូបរបស់អង្គការក្រៅរដ្ឋាភិបាលនៅលើមូលដ្ឋានវង្វិលជុំ។
- អ្នកតំណាងមួយរូបរបស់ស្ថាប័នគ្រូបង្រៀន
- អ្នកតំណាងមួយរូបរបស់ OECD ដោយសារស្ថានភាពរបស់ខ្លួនជាអង្គការប្រតិបត្តិការអន្តរជាតិ ហើយតួនាទីរបស់ខ្លួននៅក្នុងស្ថាបត្យកម្មជំនួយសកលលោកទាក់ទងនឹងជំនួយអភិវឌ្ឍន៍ជាផ្លូវការ(ODA)
- អ្នកតំណាងមួយរូបពីស្ថាប័នថ្នាក់តំបន់សម្រាប់មួយតំបន់នៃតំបន់ទាំងប្រាំមួយ ដែលត្រូវធ្វើការសម្រេចចិត្តដោយថ្នាក់តំបន់ដែលមានគោលគំនិតដើម្បីវង្វិលភាពជាអ្នកតំណាង។ សម្រាប់អាមេរិកឡាទីន និងការីបីនអ្នកតំណាងនឹងត្រូវមកពីស្ថាប័នរបស់ Ibero-American States សម្រាប់វិស័យអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌។

សមាជិកទាំងអស់នឹងត្រូវបានចាត់តាំងដោយស្ថាប័នរៀងៗខ្លួន នឹងជាតំណាងឲ្យពួកគេ ហើយនឹងទទួលខុសត្រូវទៅលើពួកគេ។ ការវង្វិលជុំនឹងប្រព្រឹត្តទៅរៀងរាល់ពីរឆ្នាំម្តង។ លើសពីនេះទៅទៀត ក្រុមវង្វិលជុំនៃសម្ព័ន្ធសមាជិក នឹងត្រូវបានបង្កើតឡើងដើម្បីធានានូវតុល្យភាពតំបន់ ដោយក្រុមការងារដឹកនាំការអប់រំឆ្នាំ២០៣០ ។ ចេះនឹងបញ្ចូលអ្នកតំណាងរបស់វិស័យឯកជន ស្ថាប័នផ្តល់មូលនិធិ ស្ថាប័នយុវជន និងនិស្សិត។ សម្ព័ន្ធសមាជិក នឹងចូលរួមក្នុងកិច្ចប្រជុំក្នុងនាមជាអ្នកអង្កេតការណ៍ តាមការអញ្ជើញដោយក្រុមការងារដឹកនាំការអប់រំឆ្នាំ២០៣០។ ក្រុមការងារដឹកនាំការអប់រំឆ្នាំ ២០៣០ ក៏អាចបង្កើតក្រុមជំនាញតាមប្រធានបទដោយយោងលើតម្រូវការជាក់ស្តែងដែលមានពេលវេលាកំណត់ក្រុមការងារចំពោះកិច្ចផ្សេងៗដែលមានជំនាញតាមប្រធានបទត្រូវផ្តល់ជាតុចូលជាលក្ខណៈបច្ចេកទេសទៅនឹងការងាររបស់ខ្លួន និង/ ឬក៏ទាញយកការងារណាមួយដែលមានស្រាប់។ យូណេស្កូនឹងផ្តល់ជូនលេខាធិការដ្ឋានសម្រាប់ក្រុមការងារដឹកនាំការអប់រំឆ្នាំ២០៣០ ។

៩៥. កាលកំណត់កិច្ចប្រជុំស្តីពីវិស័យអប់រំជាសកល ស្របទៅតាមការកំណត់សម័យប្រជុំរបស់វេទិកានយោបាយកម្រិតខ្ពស់ស្តីពីការអភិវឌ្ឍដោយចីរភាព នឹងត្រូវបានរៀបចំដោយយូណេស្កូ ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារដឹកនាំវិស័យអប់រំឆ្នាំ២០៣០ ដើម្បីពិនិត្យវាងរបៀបវារៈវិស័យអប់រំឆ្នាំ២០៣០ នឹងវឌ្ឍភាពដែលបានធ្វើឡើង និងចែករំលែកលទ្ធផល ដោយមានការតាមដានជាសកលយ៉ាងសមស្រប និងពិនិត្យយន្តការសម្រាប់គោលដៅអភិវឌ្ឍដោយចីរភាព ។ រដ្ឋជាសមាជិកទាំងអស់ និងភាគីពាក់ព័ន្ធដ៏ទៃទៀត ដែលជាផ្នែកនៃយន្តការសម្របសម្រួលនឹងចូលរួមនៅក្នុង GEMs។ លើសពីនេះទៅទៀត កិច្ចប្រជុំជាន់ខ្ពស់នឹងត្រូវរៀបចំឡើងរួមជាមួយមហាសន្និសីទរបស់យូណេស្កូ ។ ទាំងនេះនឹងត្រូវបានបំពេញបន្ថែមដោយកិច្ចប្រជុំថ្នាក់តំបន់ ទៅតាមពេលវេលាដែលត្រូវកំណត់នៅថ្នាក់តំបន់ដោយរដ្ឋជាសមាជិក និងភាគីពាក់ព័ន្ធដ៏ទៃទៀត។

៩៦. អង្គការយូណេស្កូ នឹងបន្តសម្របសម្រួលកិច្ចពិភាក្សា ការឆ្លុះបញ្ចាំង និងភាពជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលឯកទេសរួមទាំង CCNGO ដែលជាផ្នែកសំខាន់នៃយន្តការសម្របសម្រួលជាសកល ការបង្កើតលើបទពិសោធន៍ដែលមានស្រាប់ ដោយពិចារណាលើមហិច្ឆតាធំជាងមុននៃរបៀបវារៈថ្មី។

## ការត្រួតពិនិត្យ ការតាមដាន និងការពិនិត្យឡើងវិញសម្រាប់គោលនយោបាយផ្អែកលើភស្តុតាង

៩៧. ការតាមដាន និងការពិនិត្យឡើងវិញផ្អែកលើការពិនិត្យយ៉ាងដិតដល់លើគោលនយោបាយនៃការរាយការណ៍ការវាយតម្លៃប្រព័ន្ធ និងឧបករណ៍ទាំងឡាយណាដែលមានសារៈសំខាន់សម្រាប់ការសម្រេចសមិទ្ធិផលនៃវិស័យអប់រំឆ្នាំ២០៣០។ ការត្រួតពិនិត្យគុណភាពក្នុងវិស័យអប់រំ តម្រូវឲ្យមានយុទ្ធសាស្ត្រលក្ខណៈចម្រុះគ្របដណ្តប់ការរៀបចំប្រព័ន្ធជាតុចូល ខ្លឹមសារ ដំណើរការ និងលទ្ធផល។ ខណៈដែលការទទួលខុសត្រូវជាបឋមសម្រាប់ការពិនិត្យ ស្ថិតនៅកម្រិតប្រទេសជាតិ បណ្តាប្រទេសទាំងឡាយគួរបង្កើតឲ្យមានយន្តការត្រួតពិនិត្យ និងការទទួលខុសត្រូវប្រកបដោយប្រសិទ្ធិភាព សម្របទៅនឹងអាទិភាពថ្នាក់ជាតិ ក្នុងការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល។ ពួកគេក៏គួរធ្វើការដើម្បីបង្កើតភាពស្របគ្នាឲ្យបានច្រើនជាងមុននៅកម្រិតសកលលោក ដូចទៅនឹងអ្វីដែលជាស្តង់ដារគុណភាពជាក់លាក់ និងលទ្ធផលសិក្សា គួរតែបានសម្រេចដោយឆ្លងកាត់ដំណើរជីវិតពីការអភិវឌ្ឍកុមារភាពរហូតដល់ទទួលបាន ជំនាញជាមនុស្សពេញវ័យ និងរបៀបដែលពួកគេគួរត្រូវបានវាស់វែង។ បន្ថែមពីនេះទៀត បណ្តាប្រទេសទាំងឡាយគួរស្វែងរកការកែលម្អគុណភាព និងពេលវេលានៃការធ្វើរបាយការណ៍។ ព័ត៌មាន និងទិន្នន័យត្រូវទទួលបានទាំងអស់គ្នាដោយសេរី។ ទិន្នន័យ ពត៌មាន និងលទ្ធផលថ្នាក់ជាតិ ផ្អែកលើយន្តការនៃការធ្វើរបាយការណ៍ដែលមានស្រាប់ រួមជាមួយនឹងប្រភពទិន្នន័យថ្មីជាការចាំបាច់នឹងជាទុនចំពោះការពិនិត្យឡើងវិញនៅថ្នាក់តំបន់ និងថ្នាក់សកល។

៩៨. ដើម្បីវាស់វែង និងត្រួតពិនិត្យឲ្យបានប្រសើរជាងមុនលើគុណភាព សមភាព និងការអប់រំបែបបរិយាប័ន្នកិច្ចប្រឹងប្រែងគួរត្រូវបានធ្វើឡើងដើម្បីបង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបញ្ចូលទិន្នន័យសមស្រប ហើយប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពសម្រាប់ការរៀបចំផែនការ និងការបង្កើតគោលនយោបាយ។ ដៃគូទាំងឡាយក្នុងកិច្ចប្រតិបត្តិការជិតស្និទ្ធជាមួយ UIS និងសេចក្តីណែនាំផ្សេងៗ នឹងផ្តល់ជូនការគាំទ្រដោយផ្ទាល់ និងចំគោលដៅដល់រដ្ឋជាសមាជិក ដើម្បីពង្រឹងវិធានការពាក់ព័ន្ធ សមត្ថភាពត្រួតពិនិត្យ និងការវាស់វែង។ UIS នឹងសម្របសម្រួលការចែករំលែកមេរៀននៃការអនុវត្តល្អ ដោយមានទស្សនៈក្នុងការរឹតបណ្តឹងប្រព័ន្ធទិន្នន័យរបស់ប្រទេសជាតិ ជាពិសេសសម្រាប់បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក ប្រទេសមានការអភិវឌ្ឍតិចបំផុត បណ្តាប្រទេសកំពុង

អភិវឌ្ឍន៍នៅជាប់ដីគោក បណ្តារដ្ឋកំពុងអភិវឌ្ឍន៍លើកោះតូចៗ និងបណ្តាប្រទេសដែលមានចំណូលមធ្យម។ កិច្ចប្រឹងប្រែងគួរត្រូវបានធ្វើឡើងដើម្បីបញ្ចូលក្របខ័ណ្ឌគុណភាពក្នុងផែនការអប់រំថ្នាក់ជាតិ និងដើម្បីបង្កើតសមត្ថភាពនៃប្រទេសទាំងឡាយដើម្បីពិនិត្យសមភាពការអប់រំបែបបរិយាប័ន្ន និងលទ្ធផលសិក្សា។

៩៩. ការត្រួតពិនិត្យតាមដានជាសកលមានសារៈសំខាន់ចំពោះកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិ និងតំបន់ដើម្បីពង្រឹងការវិភាគ និងការគ្រប់គ្រងចំណេះដឹង។ ស្របជាមួយអនុសាសន៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតនឹងត្រូវបានធ្វើឡើងដើម្បីធ្វើសុខដុមនីយកម្មរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍដោយចីរភាពមួយនឹងរបាយការណ៍របស់អង្គសន្ធិសញ្ញាសិទ្ធិមនុស្សនានាទាក់ទងនឹងវិស័យអប់រំ។ របាយការណ៍ជាតិផ្លូវការទាំងនេះ ឆ្លុះបញ្ចាំងពីការចូលរួមចំណែករបស់សង្គមស៊ីវិលផ្តល់ជូននូវការយល់ដឹងដែលមានសារៈសំខាន់ទៅក្នុងស្ថានភាពនៃសិទ្ធិទទួលបានការអប់រំ។

១០០. ក្នុងការទទួលស្គាល់ពីសារៈសំខាន់នៃសុខដុមនីយកម្មនៃការពិនិត្យ និងការធ្វើរបាយការណ៍ UIS នឹងនៅតែជាប្រភពជាផ្លូវការនៃទិន្នន័យប្រៀបធៀបទូទាំងប្រទេសលើវិស័យអប់រំ។ នេះនឹងបន្តបង្កើតសូចនាករពិនិត្យជាអន្តរជាតិលើការស្ទាបស្ទង់មតិវិស័យអប់រំប្រចាំឆ្នាំរបស់ខ្លួន និងលើប្រភពទិន្នន័យដ៏ទៃទៀតដែលធានាឲ្យមានការប្រៀបធៀបជាអន្តរជាតិសម្រាប់បណ្តាប្រទេស និងដែនដីជាង២០០។ បន្ថែមពីនេះទៀត ចំពោះការប្រមូលទិន្នន័យ UIS នឹងធ្វើការជាមួយដៃគូដើម្បីអភិវឌ្ឍន៍សូចនាករថ្មី យុទ្ធសាស្ត្រស្ថិតិ និងឧបករណ៍ពិនិត្យ ដើម្បីវាយតម្លៃវឌ្ឍនភាពល្អប្រសើរជាងមុនតាមរយៈចំណុចដៅទាក់ទងនឹងអាណត្តិរបស់យូណេស្កូធ្វើការសម្របសម្រួលជាមួយក្រុមការងារដឹកនាំការអប់រំឆ្នាំ២០៣០ ។

១០១. របាយការណ៍ត្រួតពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នានឹងត្រូវបានបន្តក្នុងរូបភាពជារបាយការណ៍អប់រំជាសកល(GEM)។ នេះនឹងត្រូវបានរៀបចំដោយក្រុមឯករាជ្យមួយ ហើយនិងត្រូវបានបោះពុម្ពផ្សព្វផ្សាយដោយយូណេស្កូ។ នាយករបស់ក្រុមនេះនឹងត្រូវបានតែងតាំងដោយអគ្គនាយករបស់អង្គការយូណេស្កូ។ ការយកចិត្តទុកដាក់នឹងត្រូវបានផ្តល់បន្ថែមទៀតទៅលើតុល្យភាពភូមិសាស្ត្រនៃក្រុមប្រឹក្សាផ្តល់យោបល់របស់ខ្លួន។ របាយការណ៍ GEM នឹងក្លាយជាយន្តការសម្រាប់ការត្រួតពិនិត្យ និងការធ្វើរបាយការណ៍ស្តីពីគោលដៅអភិវឌ្ឍដោយចីរភាពលើវិស័យអប់រំ និងស្តីពីវិស័យអប់រំនៅក្នុងគោលដៅអភិវឌ្ឍដោយចីរភាពដ៏ទៃទៀត ដោយផ្អែកលើយន្តការជាសកលដែលត្រូវបង្កើតឡើងដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការអនុវត្តរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព។ វាក៏ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តយុទ្ធសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីជួយឲ្យដៃគូពាក់ព័ន្ធមានការទទួលខុសត្រូវចំពោះការប្តេជ្ញាចិត្តរបស់ពួកគេដែលជាផ្នែកមួយនៃការតាមដាន និងការពិនិត្យរបស់ SDG ទាំងមូល។

១០២. ការប្រមូលការវិភាគ និងការប្រើប្រាស់ទិន្នន័យនឹងត្រូវបានពង្រឹងបន្ថែមទៀត ដោយជម្រុញឲ្យមាន"បដិវត្តទិន្នន័យ" លើអនុសាសន៍នៃក្រុមប្រឹក្សាជំនាញឯករាជ្យរបស់អគ្គលេខាអង្គការសហប្រជាជាតិ ស្តីពីបដិវត្តទិន្នន័យសម្រាប់ការអភិវឌ្ឍដោយចីរភាព[16]។ ដើម្បីដោះស្រាយភាពខ្វះខាតទិន្នន័យបច្ចុប្បន្ន ទីភ្នាក់ងារទាំងឡាយត្រូវកែលម្អការសម្របសម្រួលរួមទាំងការពង្រឹងក្រុមអន្តរភ្នាក់ងារដែលមានស្រាប់ និងបង្កើតក្រុមថ្មីៗ

16 អនុសាសន៍សំខាន់ៗរបស់ក្រុមប្រឹក្សាជំនាញឯករាជ្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិរួមមាន៖ (១) ការអភិវឌ្ឍឱ្យមានការមូលមតិគ្នាជាសកលលើគោលការណ៍និងស្តង់ដារ, (២) ចែករំលែកបច្ចេកវិទ្យា និងការបង្កើតថ្មីសម្រាប់ផលប្រយោជន៍រួម, (៣) ធនធានថ្មីសម្រាប់ការអភិវឌ្ឍសមត្ថភាព, (៤) ភាពជាអ្នកដឹកនាំសម្រាប់ការសម្របសម្រួល និងការកៀរគរ និង, (៥) ការសម្រេចបឋមមួយចំនួនទៀតនៅលើទិន្នន័យ SDG។

ដើម្បីអភិវឌ្ឍវិធីសាស្ត្រសុខដុមនីយកម្មសម្រាប់ទទួលបានការប៉ាន់ស្មានរួមផ្អែកលើទិន្នន័យដែលអាចទទួលបាន ខណៈដែលការអភិវឌ្ឍប្រភពទិន្នន័យប្រៀបធៀបថ្មីតាមតម្រូវការជាចាំបាច់។ បណ្ដាប្រទេស និងទីភ្នាក់ងារទាំងឡាយគួរពង្រឹង និងកំណត់ស្ដង់ដារទិន្នន័យលើការប្រមូលផ្ដុំប្រភពក្នុងស្រុក និងបណ្ដាញហិរញ្ញវត្ថុសម្រាប់វិស័យអប់រំរួមទាំងការចូលរួមតាមគ្រួសារផងដែរ។ បណ្ដាប្រទេស និងទីភ្នាក់ងារទាំងឡាយក៏នឹងទទួលបានផលប្រយោជន៍ពីការចូលរួមក្នុងយន្តការដែលបានស្នើឡើង ដើម្បីអភិវឌ្ឍន៍ស្ដង់ដារបង្កើនសមត្ថភាពប្រមូលព័ត៌មានចាំបាច់ និងចែករំលែកទិន្នន័យបន្ថែមទៀត ។

១០៣. លើសពីនេះទៅទៀតវប្បធម៌ស្រាវជ្រាវ និងការវាយតម្លៃគឺមានការចាំបាច់នៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីរៀនមេរៀនពីការអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយ ហើយបង្រៀនពួកគេឲ្យចេះធ្វើសកម្មភាព។ សម្រាប់ថ្នាក់ជាតិបណ្ដាប្រទេសទាំងឡាយ គួរវាយតម្លៃផលប៉ះពាល់គោលនយោបាយអប់រំរបស់ខ្លួនស្ដីពីការសម្រេចបានគោលដៅអប់រំឆ្នាំ២០៣០។ ពួកគេត្រូវពឹងផ្អែកលើលទ្ធផលត្រួតពិនិត្យ និងការស្រាវជ្រាវដើម្បីជានាំឲ្យបាននូវការសម្រេចផ្អែកលើភស្ដុតាងប្រកបដោយប្រសិទ្ធិភាព និងកម្មវិធីតម្រង់ទិសយោងលើលទ្ធផល។ ដំណើរការវាយតម្លៃគួរសម្លឹងមើលទៅសមាសភាគទាំងអស់នៃប្រព័ន្ធអប់រំ ក្នុងគោលបំណងចែករំលែកមេរៀនបើកការជជែកពិភាក្សាគ្នាពីអ្វីដែលអាចប្រើការបាន និងផ្ដល់ជូនមតិស្ថាបនា។ គោលការណ៍សំខាន់សម្រាប់វិធីសាស្ត្រវាយតម្លៃរួមមានមជ្ឈការនៃគុណភាពបង្រៀននិងរៀន៖ សារៈសំខាន់នៃការដឹកនាំកម្រិតសាលារៀន សមភាព និងការអប់រំបែបបរិយាប័ន្នជាគន្លឹះ៖ តម្លាភាព និងការចូលរួមរបស់ដៃគូនៅគ្រប់កម្រិត។ សរុបមក សកម្មភាពវាយតម្លៃគួរតែរួមចំណែកក្នុងការសម្រេចបានគោលដៅទាំងពីរ គឺការទទួលខុសត្រូវ និងការអភិវឌ្ឍ។ លើសពីនេះទៅទៀត នៅកម្រិតសកល ទីភ្នាក់ងារចាត់ចែងកិច្ចប្រជុំប្ដេជ្ញាអនុវត្តន៍ការវាយតម្លៃពីប្រសិទ្ធិភាពនៃយន្តការសម្របសម្រួលរបស់ពួកគេ និងវិសាលភាពកម្មវិធីគាំទ្រប្រទេសដែលបានចូលរួមអនុវត្តវិស័យអប់រំឆ្នាំ ២០៣០។

## ការផ្ដល់ហិរញ្ញប្បទាន

១០៤. កិច្ចប្រជុំកំពូលស្ដីពីវិស័យអប់រំទីក្រុងអូស្លូ (ខែកក្កដា ឆ្នាំ២០១៥)[xliii] និងសន្និសីទអន្តរជាតិលើកទីបីស្ដីពីការផ្ដល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ (Addis Ababa ខែកក្កដា ឆ្នាំ២០១៥) បានអះអាងថា ការផ្ដល់ហិរញ្ញវត្ថុត្រូវតែមានការកើនឡើងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដោយចីរភាពវិស័យអប់រំ (SDG4) ។ ការសម្រេចបានយ៉ាងពេញលេញនៃរបៀបវារៈវិស័យអប់រំឆ្នាំ២០៣០ តម្រូវឲ្យមានការផ្ដល់ហិរញ្ញប្បទានដែលមាននិរន្តរភាពការច្នៃប្រឌិតថ្មី និងការកំណត់គោលដៅបានយ៉ាងល្អ និងការរៀបចំអនុវត្តយ៉ាងមានប្រសិទ្ធិភាពជាពិសេសក្នុងបណ្ដាប្រទេសដែលនៅឆ្ងាយពីការសម្រេចបាននូវការអប់រំ ប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នាគ្រប់កម្រិត និងនៅក្នុងស្ថានភាពអាសន្ន។ ដោយមានការទទួលស្គាល់បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងធនធាន កិច្ចប្រជុំកំពូលទីក្រុងអូស្លូបានបង្កើតឡើងនូវគណៈកម្មាការកម្រិតខ្ពស់លើការផ្ដល់ហិរញ្ញប្បទាននៃឱកាសអប់រំជាសកលជាជំហានដំបូង ដែលមានកាសម្រេចចិត្តដើម្បីពង្រឹងករណីវិនិយោគក្នុងការអប់រំ និងដើម្បីផ្លាស់ប្ដូរការវិនិយោគមិនគ្រប់គ្រាន់នាពេលបច្ចុប្បន្ន។ កិច្ចខិតខំប្រឹងប្រែងដើម្បីបំពេញគម្លាតមូលនិធិនេះ ត្រូវចាប់ផ្ដើមដោយការផ្ដល់មូលនិធិក្នុងស្រុក។ ពេលដំណាលគ្នានេះដែរ ហិរញ្ញវត្ថុសាធារណៈអន្តរជាតិដើរតួនាទី

យ៉ាងសំខាន់ក្នុងការបំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងរបស់បណ្ដាប្រទេស ដើម្បីប្រមូលធនធានសាធារណៈក្នុងស្រុក ជាពិសេសនៅក្នុងបណ្ដាប្រទេសក្រីក្រ និងងាយរងគ្រោះបំផុតដោយសារធនធានក្នុងស្រុកមានកំណត់។ វិធីសាស្ត្រផ្ដល់មូលនិធិក្នុងជម្រើសផ្សេងៗ និងមានភាពច្នៃប្រឌិតថ្មីៗ ក៏ត្រូវការចាំបាច់ផងដែរ។

១០៥. របៀបវារៈសកម្មភាព Addis Ababa[xliv] ជម្រុញឲ្យបណ្ដាប្រទេសទាំងឡាយកំណត់គោលដៅចំណាយសមស្របនៅថ្នាក់ជាតិសម្រាប់វិស័យអប់រំ។ បរិបទថ្នាក់ជាតិគឺមានភាពចម្រុះគ្នា ប៉ុន្តែចំណុចគោលនានាជាអន្តរជាតិ និងថ្នាក់តំបន់ដូចខាងក្រោមនេះ គឺជាចំណុចដែលមានសារៈសំខាន់៖

- បែងចែកយ៉ាងហោចណាស់ ៤%ទៅ៦%នៃផលិតផលក្នុងស្រុកសរុប (GDP) ដើម្បីវិស័យអប់រំ និង/ឬ
- បែងចែកយ៉ាងហោចណាស់១៥%ទៅ២០%នៃការចំណាយជាសាធារណៈដើម្បីវិស័យអប់រំ។ សេចក្ដីថ្លែងការណ៍ទីក្រុងអ៊ីនឈុនជម្រុញឱ្យមានការប្រកាន់ខ្ជាប់ចំពោះចំណុចគោលទាំងនេះ និងការប្ដេជ្ញាចិត្តដើម្បីបង្កើនការចំណាយសាធារណៈទៅលើវិស័យអប់រំ ស្របតាមបរិបទរបស់ប្រទេស។ ជាមធ្យម[xlv] នៅក្នុងឆ្នាំ២០១២ បណ្ដាប្រទេសទាំងឡាយបានបែងចែកជាមធ្យម ៥.0% នៃ GDP និង ១៣.៧%នៃខ្ទង់ចំណាយសាធារណៈមកលើវិស័យអប់រំ។ ប្រទេសអភិវឌ្ឍន៍តិចបំផុតត្រូវតែឈានដល់ ឬលើសពីចំនួនខាងលើនៃលក្ខខណ្ឌ សន្ទស្សន៍ទាំងនេះ ប្រសិនបើពួកគេចង់សម្រេចបាននូវគោលដៅដែលបានដាក់ចេញនៅក្នុងក្របខ័ណ្ឌនេះ។ នេះក៏ត្រូវបញ្ជាក់ដោយការវិភាគលើការចំណាយនៃការសម្រេចបានជាសកលនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សានៅក្នុងបណ្ដាប្រទេសដែលមានចំណូលទាប និងមធ្យមនៅឆ្នាំ ២០៣០ ដែលព្យាករណ៍ថាមានការកើនឡើងពី ១៤៩ពាន់លានដុល្លារអាមេរិកក្នុងឆ្នាំ២០១២ ទៅ ៣៤០ ពាន់លានដុល្លារអាមេរិកជាមធ្យម ចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០៣០[xlvi]។ ការកើនឡើងជាចាំបាច់ក្នុងការចំណាយអាចត្រូវសម្រេចបានតាមរយៈ៖

១០៦. **ការបង្កើន និងការកែលម្អនៃការផ្ដល់ហិរញ្ញប្បទានក្នុងស្រុកសម្រាប់វិស័យអប់រំ៖** ប្រភពធនធានក្នុងស្រុកនឹងនៅជាប្រភពដែលសំខាន់បំផុតសម្រាប់ការផ្ដល់មូលនិធិដល់វិស័យអប់រំ ដូចនេះត្រូវមានការប្ដេជ្ញាចិត្តច្បាស់លាស់ពីរដ្ឋាភិបាលដើម្បីផ្ដល់ហិរញ្ញវត្ថុដែលមានសមភាព និងមានភាពសមស្របជាមួយអាទិភាពអប់រំថ្នាក់ជាតិ តម្រូវការ និងសមត្ថភាព ដើម្បីជម្រុញឲ្យមានការសម្រេចបានសិទ្ធិក្នុងការទទួលបានការអប់រំ។ បណ្ដាប្រទេសទាំងឡាយនឹងត្រូវការ៖

- **បង្កើនមូលនិធិសាធារណៈសម្រាប់វិស័យអប់រំ៖** នេះតម្រូវឱ្យពង្រីកមូលដ្ឋានពន្ធ (ជាពិសេសការបញ្ចប់ពន្ធដែលបង្កភាពអន្តរាយ) ការទប់ស្កាត់ការគេចពន្ធ និងការបង្កើនបដិភាគថវិការបស់ជាតិដែលបានទុកបម្រុងដើម្បីវិស័យអប់រំ។
- **ផ្ដល់អាទិភាពដល់អ្នកដែលត្រូវការបំផុត៖** កុមារជួបការលំបាក យុវជន និងមនុស្សពេញវ័យ ក៏ដូចជាស្ត្រី កុមារី និងមនុស្សនៅក្នុងតំបន់ដែលទទួលរងគ្រោះដោយសារជម្លោះដែលជាធម្មតាមានតម្រូវការអប់រំធំជាងគេ ដូចនេះការផ្ដល់បិរញ្ញប្បទានគួរត្រូវបានកំណត់គោលដៅចំពោះពួកគេ។
- **បង្កើនប្រសិទ្ធិភាព និងគណនេយ្យភាព៖** កែលម្អអភិបាលកិច្ច និងគណនេយ្យភាពអាចបង្កើនសមត្ថភាព និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនៃប្រភពធនធានដែលមានស្រាប់ និងធានាថា ការផ្ដល់ហិរញ្ញប្បទានបានទៅដល់ថ្នាក់រៀន។

១០៧. **បង្កើន និងកែលម្អហិរញ្ញវត្ថុខាងក្រៅ៖** ក្នុងឆ្នាំ២០០០ សហគមន៍ពិភពលោកបានអះអាងថា "ពុំមានប្រទេសណាដែលបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លាចំពោះការអប់រំសម្រាប់ទាំងអស់គ្នា នឹងត្រូវបានរាំងស្ទះក្នុងសមិទ្ធិផលរបស់ខ្លួននៃគោលដៅនេះ ដោយកង្វះធនធានឡើយ" [xlviip.9]។ ការខ្វះខាតមូលនិធិមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ឱកាសអប់រំរបស់អ្នក សិក្សារាប់ពាន់លាននាក់ដែលត្រូវទទួលបានសិទ្ធិអប់រំប្រកបដោយគុណភាពនោះទេ។ ការប្តេជ្ញាចិត្តនេះ គឺកាន់តែមានសារៈសំខាន់ថែមទៀត ជាមួយនឹងរបៀបវារៈគោលដៅអភិវឌ្ឍដោយចីរភាពដ៏មានមហិច្ឆតា។ គម្លាតនៃការផ្តល់ហិរញ្ញប្បទានសរុបប្រចាំឆ្នាំរវាងប្រភពធនធានក្នុងស្រុកដែលអាចរកបាន និងចំនួនចាំបាច់ដើម្បីឈានដល់គោលដៅអប់រំថ្មីដែលត្រូវ ព្យាករណ៍ជាមធ្យម៣៩ពាន់លានដុល្លារអាមេរិកចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០៣០ នៅក្នុងបណ្តាប្រទេសដែលមានចំណូលទាប និងមធ្យម។ ជាពិសេសគម្លាតនេះ គឺមានកម្រិតធំធេងនៅក្នុងបណ្តាប្រទេសមានប្រាក់ចំណូលទាប ដែលវាបង្កើតការចំណាយចំនួន៤២% នៃតម្លៃសរុបប្រចាំឆ្នាំ។ ការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈអន្តរជាតិរួមទាំងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) គឺជារឿងសំខាន់ណាស់សម្រាប់ទាក់ទាញការកៀរគរធនធានបន្ថែមពីប្រភពសាធារណៈជន និងឯកជនផ្សេងទៀត។ ដូច្នេះជំនួយនៅតែជាប្រភពសំខាន់នៃការផ្តល់ហិរញ្ញវត្ថុដល់វិស័យអប់រំរយៈពេល១៥ឆ្នាំទៅមុខទៀត ប្រសិនបើចំណុចដៅនេះត្រូវធ្វើឲ្យបានសម្រេច ហើយនឹងត្រូវបានបំពេញបន្ថែមដោយការកើនឡើងនៃការរួមចំណែកពីបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម[xlviii]។ ហេតុនេះហើយបានជាដៃគូអប់រំត្រូវតែ៖

- **ធ្វើឲ្យជំនួយទៅលើវិស័យអប់រំមានការប្រសើរឡើងវិញ៖ការធ្លាក់ចុះ** នូវជំនួយទៅលើវិស័យអប់រំក្នុងប៉ុន្មានឆ្នាំថ្មីៗនេះត្រូវធ្វើឲ្យមានការប្រសើរឡើងវិញ។ ការបំពេញនូវការប្តេជ្ញាចិត្តទាំងអស់ដែលទាក់ទងទៅនឹងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) គឺមានសារៈសំខាន់ណាស់ ក្នុងនោះមានទាំងការប្តេជ្ញាចិត្តដោយបណ្តាប្រទេសអភិវឌ្ឍន៍ក្នុងកាសម្រេចបាននូវគោលដៅ០,៧% នៃប្រាក់ចំណូលជាតិសរុប ( GNI) សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និង ០,១៥% ទៅ ០,២% នៃ(GNI)ទៅកាន់ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត។ យោងតាមការ ប្តេជ្ញាចិត្តរបស់ពួកគេបណ្តាប្រទេសអភិវឌ្ឍន៍ដែលពុំទាន់បានធ្វើនៅឡើយ ត្រូវបានស្នើបង្កើនកិច្ចខិតខំប្រឹង ប្រែងបន្ថែមទៀតឆ្ពោះទៅរកគោលដៅពី ០,៧% នៃ GNI សម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការចំពោះប្រទេសកំពុងអភិវឌ្ឍ។ លើសពីនេះទៅទៀត ការគាំទ្រសម្រាប់ការអប់រំដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច ត្រូវមានការកើនឡើង។ កាន់តែលម្អិតជាងនេះ គឺគួរតែមានចលនាឆ្ពោះទៅការបង្កើនការផ្តល់ជំនួយលើការអប់រំ តាមសេចក្តីត្រូវការនិងអាទិភាពរបស់ប្រទេស ។ ជំនួយដល់វិស័យអប់រំត្រូវតែអាចព្យាករណ៍បាន។
- **កែលម្អប្រសិទ្ធភាពជំនួយតាមរយៈសុខដុមនីយកម្ម និងការសម្របសម្រួលកាន់តែប្រសើរ៖** ម្ចាស់ជំនួយបណ្តាប្រទេសដែលមានប្រាក់ចំណូលមធ្យម និងដៃគូដ៏ទៃទៀត គួរគាំទ្រផ្នែកហិរញ្ញវត្ថុចំពោះគោលដៅទាំងអស់នៃវិស័យអប់រំឆ្នាំ២០៣០ ស្របតាមតម្រូវការ និងអាទិភាពរបស់ប្រទេសនិមួយៗ ស្វែងរកការពង្រីកផ្នែកហិរញ្ញវត្ថុក្នុង និងក្រៅស្រុកក្នុងការគាំទ្រដល់របៀបវារៈរួមនេះ។ ម្ចាស់ជំនួយគួរបន្តនាំមកនូវកិច្ចប្រតិបត្តិការក្នុងការអភិវឌ្ឍស្របជាមួយនឹងការណែនាំនៃប្រសិទ្ធភាពជំនួយ ធានាថាវាត្រូវបានសម្របសម្រួលយ៉ាងល្អ និងពង្រឹងសភាវៈនៃភាពជាម្ចាស់ និងគណនេយ្យភាពរបស់ប្រទេសនីមួយៗចំពោះពលរដ្ឋរបស់ខ្លួន។
- **កែលម្អសមភាពនៃការផ្តល់ហិរញ្ញប្បទានពីខាងក្រៅ៖** ការផ្តល់ហិរញ្ញប្បទានពីខាងក្រៅគួរត្រូវបានកំណត់គោលដៅឲ្យបានប្រសើរនូវការគាំទ្រអនុវិស័យដែលមិនសូវបានទទួលការយកចិត្តទុកដាក់ និងបណ្តា

ប្រទេសដែលមានប្រាក់ចំណូលទាប ក្រុមជួបការលំបាក និងងាយរងគ្រោះនៅក្នុងបណ្តាប្រទេសមានប្រាក់ចំណូលមធ្យម។ ជាមួយគ្នានេះដែរ និន្នាការនៃការធ្លាក់ចុះលំហូរនៃជំនួយអភិវឌ្ឍន៍ផ្លូវការចំពោះបណ្តាប្រទេសដែល មានប្រាក់ចំណូលមធ្យមត្រូវធ្វើការសម្រួលឲ្យបានប្រសើរឡើង។ ការបែងចែកនៃលំហូរជំនួយផ្លូវការមិនគួរត្រូវ បានចែកតាមប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗនោះទេ។ ក្នុងន័យនេះ ត្រូវមានការយកចិត្តទុកដាក់ជាពិសេសចំពោះបណ្តាប្រទេសដែលងាយរងគ្រោះ ដូចជារដ្ឋកំពុងអភិវឌ្ឍដែលជាកោះតូចៗជាដើម។ ម្ចាស់ជំនួយពហុភាគី និងទ្វេភាគីសម្រាប់វិស័យអប់រំគួរអភិវឌ្ឍយុទ្ធសាស្ត្រ ដោយសហប្រតិបត្តិការជាមួយបណ្តាប្រទេសទទួលជំនួយ ថាតើប្រភេទនៃការគាំទ្របែបណាដែលគួរតែត្រូវបានផ្តល់ជូនតាមរយៈបណ្តាញណាមួយ និងបែបបទនៃការផ្តល់ជូនដូចម្តេច។

- **ជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍដូចគ្នាដែលត្រូវបានទទួលការគាំទ្រដោយប្រទេសអភិវឌ្ឍ (South-South និងtriangular cooperation)៖** កិច្ចសហប្រតិបត្តិការ South- South គឺជាធាតុសំខាន់មួយទៀតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការអភិវឌ្ឍគឺជាការបំពេញបន្ថែម តែមិនមែនជាការជំនួសចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសអភិវឌ្ឍនិងប្រទេសកំពុងអភិវឌ្ឍនោះទេ (North-South cooperation)។ យោងលើសារៈសំខាន់របស់ខ្លួនដែលមានការកើនឡើងជាប្រវត្តិសាស្ត្រ និងចំណុចផ្សេងៗគ្នានៃកិច្ចប្រតិបត្តិការ South-South គួរត្រូវបានគេមើលឃើញថាជាការបង្ហាញពីសាមគ្គីភាពក្នុងចំណោមប្រជាជន និងបណ្តាប្រទេសទាំងឡាយនៅតាមបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍គឺត្រូវផ្អែកលើបទពិសោធន៍ និងវត្ថុបំណងរួមរបស់ពួកគេ។ កិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ដែលត្រូវបានទទួលការគាំទ្រដោយប្រទេសអភិវឌ្ឍ (triangular cooperation) គួរត្រូវបានពង្រឹងជាមធ្យោបាយនៃការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ និងនាំមកនូវបទពិសោធន៍ និងជំនាញពាក់ព័ន្ធដើម្បីទទួលយកកិច្ចសហប្រតិបត្តិការនៃការអភិវឌ្ឍ។ លើសពីនេះទៅទៀតការបង្កើតធនាគារអភិវឌ្ឍ BRICS ដោយប្រទេសប្រេស៊ីល ប្រទេសចិន ប្រទេសឥណ្ឌា សហព័ន្ធរុស្ស៊ី និងអាហ្វ្រិកខាងត្បូង អាចជាការផ្តល់ជូនប្រភពថ្មីនៃមូលនិធិសម្រាប់វិស័យអប់រំ និងជួយធ្វើឲ្យជំនួយមានការកើនឡើងវិញ។
- **បង្កើនបរិមាណជំនួយដល់វិស័យអប់រំក្នុងស្ថានភាពដែលមានវិវាទ និងវិបត្តិ៖** វានឹងមិនអាចធ្វើទៅបានដោយជោគជ័យក្នុងការផ្តល់ការអប់រំសម្រាប់ទាំងអស់គ្នាដោយមិនបានទៅដល់កុមារ យុវជន និងមនុស្សពេញវ័យនៅក្នុងបណ្តារដ្ឋដែលមានភាពផុយស្រួយ និងប្រទេសដែលរងផលប៉ះពាល់ដោយវិវាទ និងគ្រោះធម្មជាតិនោះទេ។ វិស័យអប់រំទទួលបានតែ ២% នៃការអំពាវនាវរកជំនួយមនុស្សធម៌[xlix]។ កិច្ចខិតខំប្រឹងប្រែងជាបន្ទាន់គួរត្រូវបានធ្វើឡើងដើម្បីបង្កើនការគាំទ្រសម្រាប់វិស័យអប់រំក្នុងការឆ្លើយតបចំពោះមនុស្សធម៌ និងវិបត្តិអូសបន្លាយដែលអាស្រ័យលើតម្រូវការនិងដើម្បីធានាឱ្យបានការឆ្លើយតបបន្ទាន់ទៅនឹងស្ថានភាពជម្លោះ និងវិបត្តិ។ ការបង្កើត ចំណុចរួមរវាងមនុស្សធម៌ និងការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុព្រមទាំងគំរូរបស់ពួកគេអាចបង្កើនប្រសិទ្ធភាពនៃការវិនិយោគគ្រប់ប្រាក់ដុល្លារនៅក្នុងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញ និងដោះស្រាយតម្រូវការរយៈពេលខ្លី មធ្យម និងវែងដែលទាក់ទងគ្នាក្នុងគោលបំណងដើម្បីគាំទ្រដល់ប្រទេសដែលផុយស្រួយ និងប្រទេសដែលរងផលប៉ះពាល់ដោយជម្លោះក្នុងការស្វែងរកដំណោះស្រាយចំពោះវិបត្តិរយៈពេលវែង និងប្រកបដោយចីរភាព។

- **ពង្រីក និងពង្រឹងភាពជាដៃគូពហុភាគីពាក់ព័ន្ធដែលមានស្រាប់៖** វាជាការចាំបាច់ដែលការអនុវត្តរបៀបវារៈ វិស័យអប់រំឆ្នាំ២០៣០ទាំងមូលត្រូវទទួលបានការគាំទ្រ។ ការវិនិយោគទុន និងកិច្ចសហប្រតិបត្តិការអន្តរជាតិនឹងត្រូវបានពង្រីកដើម្បីឲ្យកុមារទាំងអស់ទទួលបានការអប់រំកុមារតូច បឋម និងមធ្យមដោយឥតគិតថ្លៃ សមភាព បរិយាប័ន្ន មានគុណភាព រួមទាំងការពង្រីក និងពង្រឹងគំនិតផ្តួចផ្តើមរបស់ពហុភាគីពាក់ព័ន្ធដូចជា ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE)។ លើសពីនេះទៅទៀត ទីកន្លែងអប់រំនឹងត្រូវបានកែលម្អ ហើយការវិនិយោគក្នុងការអប់រំ STEM ត្រូវបានកើនឡើង ការបណ្តុះបណ្តាលបច្ចេកទេស ជំនាញវិជ្ជាជីវៈ និងឧត្តមសិក្សា ព្រមទាំងការបណ្តុះបណ្តាលនឹងត្រូវបានពង្រឹង ធានានូវការទទួលបានស្មើគ្នាសម្រាប់ស្ត្រី និងកុមារី និងលើកទឹកចិត្តឲ្យមានការចូលរួមរបស់ពួកគេ ហើយចំនួនអាហារូបករណ៍ត្រូវបានផ្តល់ជូននិស្សិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីមានការកើនឡើងនូវការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា។ គឺជាការចាំបាច់ និងបន្ទាន់ដូចគ្នា ដើម្បីបង្កើនហិរញ្ញប្បទានសម្រាប់កម្មវិធីអក្ខរកម្មយុវជន និងមនុស្សពេញវ័យក៏ដូចជាឱកាសសិក្សា អប់រំ និងបណ្តុះបណ្តាលរបស់មនុស្សពេញវ័យនៅក្នុងទស្សនៈនៃការរៀនសូត្រពេញមួយជីវិត។ ជម្រើសផ្សេងទៀតសម្រាប់ការសម្របសម្រួលផ្តល់ហិរញ្ញប្បទាន លើវិស័យអប់រំគួរត្រូវបានពិចារណា នៅពេលដែលតម្រូវការត្រូវបានកំណត់ចំគោលដៅទាំងអស់។

១០៨. **ការច្នៃប្រឌិត ដោយផ្តោតលើភាពជាដៃគូ តម្លាភាព សមភាព និងប្រសិទ្ធភាព៖** ការសម្រេចបាននូវរបៀបវារៈអប់រំប្រកបដោយមហិច្ឆតានេះ នឹងតម្រូវឲ្យមានការបើកចំហនូវប្រភពធនធានដែលមានសក្តានុពលទាំងអស់ ដើម្បីគាំទ្រសិទ្ធិទទួលបានការអប់រំបន្ថែមលើ "ពីអ្វីដែលធ្លាប់ធ្វើកន្លងមក" ហើយជួនកាលធ្វើច្រើនទទួលបានតិច។ ដំណើរការនៃការបន្តកែលម្អគឺមានភាពចាំបាច់ ដែលរួមមានការច្នៃប្រឌិត ការតាមដាន ការវាយតម្លៃលទ្ធផលនៃការច្នៃប្រឌិត និងការប្រើប្រាស់ភស្តុតាងថ្មីដើម្បីទទួលបានជោគជ័យ និងដើម្បីផ្លាស់ប្តូរដំណើរការកន្លែងដែលចាំបាច់។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវបានដឹកនាំការបង្កើនឥទ្ធិពលនៃការចំណាយបច្ចុប្បន្នដើម្បីសម្រេចបាននូវលទ្ធផលប្រសើរជាងមុន។ នេះគឺជាមូលហេតុដែលអភិបាលកិច្ច និងភាពជាដៃគូដែលមានការកែលម្អគឺមានសារៈសំខាន់ ប៉ុន្តែការច្នៃប្រឌិតថ្មីដ៏ទៃទៀតក៏មានភាពចាំបាច់ផងដែរ៖

- **ផ្តោតការវិនិយោគលើការអប់រំបរិយាប័ន្ន សមភាព និងគុណភាព៖** ការធ្វើឲ្យប្រាកដអំពីសមភាពបរិយាប័ន្ន និងគុណភាព គឺជាការច្នៃប្រឌិតថ្មីក្នុងប្រព័ន្ធជាច្រើន។ ការវិនិយោគទុនទាំងអស់ ទាំងបច្ចុប្បន្ន និងថ្មីគួរតែត្រូវបានធ្វើឡើងឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យសំខាន់ដូចជា៖ តើនេះជួយធានាថាមនុស្សទាំងអស់រួមទាំងអ្នកជួបការលំបាក និងងាយរងគ្រោះបំផុតទទួលបានចំណេះដឹង ឥរិយាបទ និងជំនាញដែលពួកគេត្រូវការសម្រាប់ជីវិត និងជីវភាពរស់នៅរបស់ពួកគេ និងសម្រាប់ការសម្រេចបានយ៉ាងពេញលេញនៃសិទ្ធិទទួលបានការអប់រំឬទេ?
- **តម្រង់ទិសប្រភពធនធានហិរញ្ញវត្ថុឯកជន៖** លើសពីតួនាទីចាំបាច់របស់ខ្លួនក្នុងការបង់ពន្ធ វិស័យឯកជនបានក្លាយជាកត្តារួមចំណែកមួយជាមួយសក្តានុពលដែលគួរឲ្យកត់សម្គាល់ចំពោះធនធានបន្ថែមទៀតសម្រាប់វិស័អប់រំ និងបង្កើនការរួមបញ្ចូលគ្នា។ វាមានសារៈសំខាន់ណាស់ក្នុងការធានាថា ការចំណាយទៅលើវិស័យអប់រំពីវិស័យឯកជនត្រូវបានតម្រង់ទិសឆ្ពោះទៅរកបណ្តាប្រទេស ប្រជាជនដែលត្រូវការបំផុត ដើម្បីពង្រឹងវិស័យអប់រំជាសាធារណៈ ភាពជាដៃគូប្រកបដោយជោគជ័យជាមួយវិស័យឯកជននឹងតម្រូវឲ្យមានការសម្របសម្រួល និងយន្តការនិយ័តកម្មដើម្បីធានាឲ្យបាននូវតម្លាភាព និងគណនេយ្យភាព។

- **បញ្ហាប្រឈម និងបង្ការពីការប្រើប្រាស់មិនត្រឹមត្រូវនៃធនធាន៖** មូលនិធិដែលមានសារៈសំខាន់សម្រាប់វិស័យអប់រំត្រូវបានបាត់បង់តាមរយៈអំពើពុករលួយ និងអប្រសិទ្ធិភាព។ ការពិនិត្យ និងការតាមដានការចំណាយដោយឯករាជ្យអាចធ្វើឲ្យមូលនិធិកើនឡើងគួរឲ្យកត់សម្គាល់ដែលសាលាពិតជាទទួលបាន។
- **បង្កើតការពិនិត្យ និងការធ្វើរបាយការណ៍ប្រកបដោយតម្លាភាព៖** ការប្តេជ្ញាចិត្តដោយផ្ទាល់ចំពោះវិធីសាស្ត្រសម្របសម្រួល និងប្រព័ន្ធគណនេយ្យភាពទៅវិញទៅមករួមទាំងការពិនិត្យ និងការធ្វើរបាយការណ៍ប្រកបដោយតម្លាភាពទៅលើការផ្តល់ហិរញ្ញប្បទានវិស័យអប់រំឆ្នាំ២០៣០ គឺតម្រូវឲ្យមាន។ នេះគួររួមបញ្ចូលទាំងការយកចិត្តទុកដាក់ពិសេសចំពោះធនធានហិរញ្ញវត្ថុកំពុងទៅដល់ប្រជាជនដែលងាយរងគ្រោះ និងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។ ការប្តេជ្ញានេះ តម្រូវឲ្យមានសមត្ថភាពអភិវឌ្ឍន៍ និងកំណត់ដោយឡែកនូវធនធានគ្រប់គ្រាន់សម្រាប់ការប្រមូលទិន្នន័យធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

# សេចក្តីសន្និដ្ឋាន

១០៩. យើងគឺជាសហគមន៍អប់រំអន្តរជាតិ ឈរយ៉ាងរឹងមាំក្នុងការរួបរួមលើវិធីសាស្ត្ររួមបញ្ចូលគ្នាថ្មីៗទាំងអស់ ដើម្បីធានាឲ្យបាននូវវិស័យអប់រំប្រកបដោយគុណភាព និងសមភាពសម្រាប់កុមារ យុវជន និងមនុស្សពេញវ័យ ខណៈការដែលការលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ យើងនឹងធ្វើការរួមគ្នាដើម្បីសម្រេចបានចំណុចដៅ អប់រំទាំងអស់ ហើយវានឹងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិទូទាំងពិភពលោកនៃវិស័យអប់រំ។ យើងឯកភាពថាតម្រូវការហិរញ្ញប្បទានបន្ថែមទៀត គឺមានភាពចាំបាច់ ដើម្បីសម្រេចបានគោលដៅថ្មី ហើយធនធាននោះគួរត្រូវបានប្រើ ប្រាស់នៅក្នុងលក្ខណៈប្រកបដោយប្រសិទ្ធិភាពបំផុតក្នុងគោលបំណងឆ្ពោះទៅរកវឌ្ឍនភាពចំពោះវិស័យអប់រំឆ្នាំ ២០៣០។ យើងក៏សង្កត់ធ្ងន់ផងដែរ នូវតម្រូវការសម្រាប់អភិបាលកិច្ចល្អ និងគណនេយ្យភាពចំពោះពលរដ្ឋក្នុងវិស័យអប់រំ។ យើងជឿជាក់ថា វិស័យអប់រំឆ្នាំ២០៣០ នឹងធ្វើឲ្យមានការរីកចម្រើនជាប្រវត្តិសាស្ត្រក្នុងការអប់រំ យើងប្តេជ្ញាក្នុងការច្នៃប្រឌិតថ្មី និងសកម្មភាពប្រកបដោយនិរន្តរភាព ដើម្បីធានាថាវិស័យអប់រំពិតជាបានផ្លាស់ប្តូរជីវិតរស់នៅក្នុងពិភពលោក។ ការសម្រេចបានវិស័យអប់រំឆ្នាំ២០៣០ មានន័យថា ភាពជោគជ័យអាចត្រូវបានប្រកាស លុះត្រាតែមនុស្សគ្រប់រូបគឺទទួលបានជោគជ័យទាំងអស់។

# ឧបសម្ព័ន្ធ ១ សូចនាករថ្នាក់សកល

ផ្នែកនេះនឹងត្រូវដាក់បញ្ចូលក្រោយការបញ្ចប់ខ្លឹមសារតាមរយៈដំណើរការរបស់អង្គការសហប្រជាជាតិ

# ឧបសម្ព័ន្ធ ២ ក្របខ័ណ្ឌសូចនាករដែលបានស្នើឡើង (សេចក្តីព្រាង)

ឧបសម្ព័ន្ធនេះត្រូវបានដាក់ស្នើនូវបញ្ជីសូចនាករតាមប្រធានបទដែលបានអភិវឌ្ឍន៍ដោយក្រុមប្រឹក្សាបច្ចេកទេស (TAG) លើសូចនាករអប់រំ។ ក្រុមប្រឹក្សាបច្ចេកទេសរួមមាន អ្នកតំណាងចូលរួមមកពីរដ្ឋជាសមាជិក តំណាងដោយគ្រប់តំបន់ទាំងអស់ក៏ដូចជាសង្គមស៊ីវិល និងដៃគូអន្តរជាតិ (UNESCO, EFA Global Monitoring Report/GEMR, OECD, UNICEF និង World Bank)។ នេះគឺជាសេចក្តីព្រាងដែលបានដាក់ជូនសម្រាប់ពិភាក្សានៅក្នុងក្រុមរៀបចំសេចក្តីព្រាងវិស័យអប់រំ ២០៣០។ ទោះជាយ៉ាងណាក៏ដោយ គ្មានការសម្រេចចិត្តណាមួយលើសូចនាករទាំងនេះឡើយ លុះត្រាតែបានធ្វើបច្ចុប្បន្នភាពដោយផ្អែកលើការសម្រេចចុងក្រោយដោយសូចនាករជាសកលតាមរយៈដំណើរការ IAEG និងយល់ព្រមដោយក្រុមការងារដឹកនាំវិស័យអប់រំឆ្នាំ ២០៣០ ។

### តារាងទី១ ក្របខ័ណ្ឌសូចនាករតាមប្រធានបទ

### គោលបំណងរួមៈ ធានាការអប់រំដែលមានគុណភាព បែបបរិយាប័ន្ន សមភាព និងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៨ | ១០ | ១១ |
|---|---|---|---|---|---|---|---|---|---|---|
| ទស្សនៈ | លរ. | សូចនាករ | សមធម៌ | ភេទ | ទីកន្លែង | ទ្រព្យធន | ដែលអាចប្រើបាន | គ្របដណ្តប់ | សូចនាករសកល ដែលបានស្នើឡើង | យោបល់ |
| | | **ចំណុចដៅ ៤.១ - ៤.៧** | | | | | | | | |
| **៤.១**: ត្រឹមឆ្នាំ ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់បញ្ចប់ការសិក្សាដោយឥតគិតថ្លៃ ទទួលបានសមភាព និងគុណភាព សម្រាប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាដែលនាំមកនូវលទ្ធផលនៃការសិក្សាដែលពាក់ព័ន្ធ និងមានប្រសិទ្ធិភាព | | | | | | | | | | |
| ការរៀនសូត្រ | ១. | ភាគរយនៃកុមារ/មនុស្សវ័យក្មេង(i) នៅពេលបញ្ចប់បឋមសិក្សា និង (ii) បញ្ចប់មធ្យមសិក្សាបឋមភូមិ យ៉ាងហោចណាស់ទទួលបាននូវជំនាញកម្រិតអប្បរមាលើ(ក)ការអាន និង (ខ)គណិតវិទ្យា | មាន | x | x | x | ១-៣ ឆ្នាំ | | មាន | កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតវិធានការជាសកលនេះនឹងផ្តោតលើគោលគំនិតទូទៅនៃភាពស្ទាត់ជំនាញអប្បរមាដោយទាញយកទំនាក់ទំនងរវាងការសិក្សាវាយតម្លៃលើសិស្សថ្នាក់ជាតិតំបន់ និងអន្តរជាតិ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ២. | ការវាយតម្លៃការសិក្សាផ្នែករដ្ឋបាលតំណាងថ្នាក់ជាតិ (i) នៅបឋមសិក្សា (ii) នៅចុងបញ្ចប់បឋមសិក្សា និង (iii) នៅចុងបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ | ទេ | | | | ១-៣ ឆ្នាំ | | | ត្រូវរៀបចំស្តង់ដារសម្រាប់គ្រប់ការវាយតម្លៃ ថ្នាក់ជាតិ តំបន់ និងអន្តរជាតិទាំងអស់ ដើម្បីធ្វើឲ្យប្រសើរឡើងនូវគុណភាពរបស់ពួកគេ។ អ្នកអង្កេតការណ៍ពីលទ្ធផលនៃការសិក្សា UIS នឹងតាមដានការវាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ |
| ការបញ្ចប់ការសិក្សា | ៣. | ផលធៀបចំនួនសិស្សចូលសិក្សាលើថ្នាក់ចុងក្រោយ(បឋមសិក្សា មធ្យមសិក្សាបឋមភូមិ) | មាន | x | | មាន | | C១៥០ | | |
| | ៤. | អត្រាបញ្ចប់ការសិក្សា (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ) | មាន | X | X | X | មាន | C១០០ | | សូចនាករនេះអាចទទួលយកបាននាពេលបច្ចុប្បន្ននេះ ក៏ប៉ុន្តែតម្រូវអោយបញ្ចប់នូវវិធីសាស្ត្រមួយ និងបង្កើនចំនួនការស្ទាបស្ទង់មតិដែលអាចធ្វើបានដើម្បីគណនាវា។ អត្រានេះត្រូវបានគណនាសម្រាប់កុមារអាយុ៣-៥ឆ្នាំលើសអាយុផ្លូវការដែលបានកំណត់សម្រាប់កម្រិតអប់រំជាក់ស្តែង។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ការចូលរួម | ៥. | អត្រាសិស្សក្រៅសាលា (បឋមសិក្សា, មធ្យមសិក្សាបឋមភូមិ, មធ្យមសិក្សាទុតិយភូមិ) | មាន | X | X | X | មាន | C១៦០ | | សូចនាករនេះនឹងត្រូវបានប្រើប្រាស់ដើម្បីពិនិត្យតាមដានកុមារ និងមនុស្សវ័យជំទង់ដែលជាជនភៀសខ្លួន និងជនផ្លាស់ទីលំនៅស្របជាមួយនឹងការខិតខំប្រឹងប្រែងធ្វើអោយប្រសើរឡើងនូវតំបន់ដែលគ្របដណ្ដប់។ |
| | ៦. | ភាគរយនៃកុមារលើសអាយុសម្រាប់កម្រិត (បឋមសិក្សា មធ្យមសិក្សាបឋមភូមិ) | មាន | X | X | X | មាន | C១០០ | | សូចនាករនេះអាចទទួលយកបាននាពេលបច្ចុប្បន្ននេះ ក៏ប៉ុន្តែការងារខ្លះតម្រូវអោយយល់ព្រមជាមួយនឹងវិធីសាស្ត្ររួមសម្រាប់ការកែប្រែអាយុ។ |
| បទបញ្ញត្តិ | ៧. | ចំនួនឆ្នាំនៃ (i) ការសិក្សាឥតគិតថ្លៃ និង (ii) កាតព្វកិច្ចនៃការចូលរៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ត្រូវបានធានាដោយក្របខ័ណ្ឌផ្លូវច្បាប់ | ទេ | | | | មាន | ទាំងអស់គ្នា | | |

**៤.២៖** ត្រឹមឆ្នាំ ២០៣០ ធានាថាកុមារី និងកុមារាទាំងអស់ ទទួលបានរក្សាការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាពការអប់រំកម្រិតមត្តេយ្យ និងការថែ ដូច្នេះពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ការអប់រំកម្រិតបឋមសិក្សា

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ការត្រៀមខ្លួន | ៨. | ភាគរយនៃកុមារដល់អាយុចូលសាលាដែលកំពុងលូតលាស់ត្រូវតាមសុខភាព ការសិក្សា និងសុខមាលភាពចិត្តសាស្ត្រសង្គម | មាន | X | X | X | ៣-៥ ឆ្នាំ | | មាន | សូចនាករនេះកំពុងត្រូវបានតាមដានតាមរយៈសន្ទស្សន៍ការអភិវឌ្ឍកុមារតូច ដែលមានមកពីការស្ទាបស្ទង់កម្រងពហុសូចនាករ Multiple Indicator Cluster Surveys (MISC) សម្រាប់កុមារដែលមានអាយុត្រូវចូលសាលាប៉ុន្តែការងារតម្រូវឲ្យពិនិត្យមើលជម្រើស ឈានដល់ការមូលមតិគ្នា និងអភិវឌ្ឍន៍កម្រងសំណួរសម្រាប់ប្រើប្រាស់ក្នុងការស្ទាបស្ទង់មតិ។ |
| | ៩. | ភាគរយនៃកុមារអាយុក្រោម ៥ ឆ្នាំ ដែលទទួលបានបរិយាកាសរៀននៅផ្ទះប្រកប ដោយអំណោយផល | មាន | x | x | x | មាន | C៣០ | | សូចនាករនេះអាចទទួលយកបាននាពេលបច្ចុប្បន្ននេះ តាមរយៈ MICS ក៏ប៉ុន្តែកិច្ចការតម្រូវអោយពិនិត្យជម្រើសផ្សេង, ឈានដល់ការមូលមតិគ្នា និងអភិវឌ្ឍន៍កម្រងសំណួរសម្រាប់ប្រើប្រាស់ក្នុងការស្ទាបស្ទង់មតិ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ការចូលរួម | ១០. | អត្រាការចូលរួមក្នុងការថែទាំ និងការអប់រំកុមារតូច ក្នុងពេលវេលាដែលបានផ្តល់ជូនដើម្បីចូលកម្រិតបឋមសិក្សា | មាន | X | X | X | ៣-៥ ឆ្នាំ | | | វាជាការចាំបាច់ណាស់ដើម្បីអោយមានភាពសុខដុមនូវសូចនាករនេះតាមរយៈការធ្វើការស្ទាបស្ទង់មតិចំនួនពីរផ្នែក (i) ក្រុមអាយុដែលមានយោងឧទាហរណ៍)MICS សួរសំណួរទៅកាន់ក្មេងអាយុ ៣ ទៅ ៤ ឆ្នាំ) និង(ii) ប្រភេទនៃកម្មវិធីដែលបានគ្របដណ្តប់។ |
| | ១១. | ផលធៀបសិស្សដែលបានចុះឈ្មោះសរុបថ្នាក់មុនបឋមសិក្សា | មាន | x | | | មាន | C ១៦៥ | | |
| បទបញ្ញត្តិ | ១២. | ចំនួនឆ្នាំនៃ (i) ការសិក្សាឥតបង់ប្រាក់ និង (ii) កាតព្វកិច្ចនៃការចូលថ្នាក់មុនបឋមសិក្សា ត្រូវបានធានាដោយក្របខ័ណ្ឌផ្លូវច្បាប់ | ទេ | | | | មាន | ទាំងអស់គ្នា | | |
| **៤.៣**: ត្រឹមឆ្នាំ ២០៣០ ធានានូវការទទួលបានស្មើគ្នាសម្រាប់បុរស និងស្ត្រីទាំងអស់ ដើម្បីអប់រំបច្ចេកទេស វិជ្ជាជីវៈ ឧត្តមសិក្សាប្រកបដោយគុណភាព រួមទាំងសាកលវិទ្យាល័យផងដែរ | | | | | | | | | | |
| ការចូលរួម | ១៣. | ផលធៀបចំនួនសិស្សសរុបដែលចុះឈ្មោះចូលរៀនឧត្តមសិក្សា | មាន | x | | | មាន | C ១៤៥ | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ១៤. | អត្រាការចូលរួមកម្មវិធីអប់រំបច្ចេកទេសវិជ្ជាជីវៈ (១៥ ទៅ ២៤ឆ្នាំ) | មាន | x | | | ៣-៥ ឆ្នាំ | | | ទិន្នន័យ គឺអាចរកបាននៅលើការចុះឈ្មោះរៀនបច្ចេកទេស វិជ្ជាជីវៈនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ ថ្នាក់ក្រោយមធ្យមសិក្សា តែមិនមែនជាឧត្តមសិក្សា និងការអប់រំថ្នាក់ឧត្តមសិក្សាដែលមានវគ្គខ្លីៗនោះទេ។ មានការលំបាក ក្នុងការប្រមូលទិន្នន័យ TVET តាមអាយុ នៅតាមបរិបទសាលារៀនផ្លូវការ/សាកលវិទ្យាល័យ ។ |
| | ១៥. | ភាគរយនៃយុវជន / មនុស្សពេញវ័យចូលរួមនៅក្នុងការអប់រំ និងការបណ្តុះបណ្តាលនៅ១២ ខែចុងក្រោយតាមប្រភេទនៃកម្មវិធី (ក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) និងតាមក្រុមអាយុ | មាន | x | x | x | មាន | C៣០ | មាន | បច្ចុប្បន្ននេះ ទិន្នន័យមានតែនៅលើការអប់រំមនុស្សចាស់ នៅបណ្តាប្រទេសសហភាពអឺរ៉ុប។ ការងារមួយចំនួនធំ តម្រូវអោយរៀបចំសំណុំសំណួរដើម្បីប្រើប្រាស់ក្នុងការស្ទាបស្ទង់មតិកម្លាំងពលកម្ម ឬការស្ទាបស្ទង់មតិជាសកលដ៏ទៃទៀត។<br><br>សូចនាករនឹងត្រូវបានគណនាសម្រាប់ជួរនៃក្រុមអាយុ និងសម្រាប់ប្រភេទខុសគ្នានៃកម្មវិធីផ្លូវការ និងក្រៅប្រព័ន្ធគិតទាំងការសិក្សារបស់មនុស្សចាស់។ |

**៤.៤៖** ត្រឹមឆ្នាំ ២០៣០ បង្កើនឲ្យបានច្រើននូវចំនួនយុវជន និងមនុស្សពេញវ័យដែលមានជំនាញពាក់ព័ន្ធរួមមាន ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ឱកាសទទួលបានការងារធ្វើ ការងារសមរម្យ និងសហគ្រិនភាព

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ជំនាញ | ១៦. | ១. ភាគរយនៃយុវជន/មនុស្សពេញវ័យដែលទទួលបានយ៉ាងហោចណាស់កម្រិតអប្បរមាជំនាញនៅក្នុងជំនាញអក្ខរកម្មឌីជីថល | មាន | x | x | x | ១-៣ ឆ្នាំ | … | | ការស្ទាបស្ទង់មតិមួយចំនួនឧទាហរណ៍ ICILS ព្យាយាមវាស់វែងជំនាញទាំងនោះ។ តម្រូវឲ្យមានការខិតខំប្រឹងប្រែងយ៉ាងសំខាន់ដើម្បីរៀបចំការប្រមូលទិន្នន័យសកល។ |
| | | ២ ភាគរយនៃបុគ្គលដែលមានជំនាញ ICT តាមប្រភេទនៃជំនាញ | មាន | x | x | x | ១-៣ ឆ្នាំ | … | មាន | សូចនាករសកលដែលត្រូវបានស្នើឡើងនឹងត្រូវបានទាញយកពីការស្ទាបស្ទង់មតិរបស់ ITU និងអាចពី OECD ផងដែរ។ |
| | ១៧. | អត្រាទទួលបានការអប់រំយុវជន/មនុស្សពេញវ័យ តាមក្រុមអាយុ ស្ថានភាពសកម្មភាពសេដ្ឋកិច្ចកម្រិតនៃការអប់រំ និងកម្មវិធីតម្រង់ទិស | មាន | x | x | ? | មាន | C ១២ 0 | | |

**៤.៥៖** ត្រឹមឆ្នាំ ២០៣០ លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាឱ្យបាននូវភាពស្មើគ្នាក្នុងការចូលរៀនគ្រប់កម្រិតទាំងអស់នៃការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនងាយរងគ្រោះ រួមទាំងជនពិការ ជនជាតិដើមភាគតិច និងកុមារ នៅក្នុងស្ថានភាពងាយរងគ្រោះ

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សមធម៌ឆ្លងគោលដៅ | ... | សន្ទស្សន៍សមភាព (ភេទស្រី / ប្រុស ជនបទ / ទីប្រជុំជន អ្នកមានទ្រព្យច្រើន/ អ្នកមានទ្រព្យតិច និង អ្នកដ៏ទៃទៀត ដូចជាជនពិការ និង អ្នករងផលប៉ះពាល់ពីជម្លោះដែលយោងលើទិន្នន័យដែលអាចរកបាន ) សម្រាប់សូចនាករទាំងអស់នៅលើបញ្ជីនេះដែលអាចត្រូវបូកសរុប ( កំណត់អត្តសញ្ញាណ ក្នុង Columns ៤-៧ )<br><br>តាមដែលអាចធ្វើទៅបានសូចនាករផ្សេងៗ គួរតែបង្ហាញទំនាក់ទំនងនឹងបែងចែក គ្រប់ប្រជាពលរដ្ឋ | | | | | | | មាន | សូចនាករជំនួសរួមមាន: (i) ផលធៀបសេស(ii)សន្ទស្សន៍ នៃការផ្តោត(iii) ក្រុមដែលទទួលបានផលប្រយោជន៍តិចតួចដូចជាកុមារីក្រីក្រតាមជនបទ ដែលទាក់ទងនឹងមធ្យោបាយ។ |
| គោលនយោបាយ | ១៨. | ភាគរយនៃសិស្សក្នុងការសិក្សាថ្នាក់បឋមដែលភាសាទីមួយ ឬភាសាប្រើប្រាស់នៅផ្ទះ គឺជាភាសាដែលយកមកបង្រៀន | មាន | x | x | x | ៣-៥ ឆ្នាំ | | | ការវាស់វែងភាសាប្រើប្រាស់តាមផ្ទះ និង ភាសាដែលយកមកសិក្សាដែលនឹងត្រូវបានតម្រូវអោយអភិវឌ្ឍន៍ឧបករណ៍សម្រាប់វាស់វែងជាសកល។ |
| | ១៩. | វិសាលភាពដែលមានរូបមន្តផ្អែកលើគោលនយោបាយច្បាស់លាស់ ត្រៀមបម្រុងទុកឡើងវិញនូវធនធានអប់រំសម្រាប់ប្រជាជនដែលជួបប្រទះការលំបាក | ទេ | | | | ៣-៥ ឆ្នាំ | | | តម្រូវឲ្យមានក្របខ័ណ្ឌសម្រាប់ប្រទេសក្នុងការបកស្រាយ និងវាយតម្លៃគោលនយោបាយ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ២០. | ការចំណាយលើវិស័យអប់រំចំពោះសិស្សម្នាក់តាមរយៈកម្រិតនៃការសិក្សា និងប្រភពនៃមូលនិធិ | ទេ | | | | ១-៣ ឆ្នាំ | | | វិសាលភាពរបស់សូចនាករនេះជាពិសេសសម្រាប់ការចំណាយលើវិស័យអប់រំឯកជនត្រូវការពង្រីកគួរឲ្យកត់សម្គាល់។ |
| | ២១. | ភាគរយនៃជំនួយសម្រាប់វិស័យអប់រំគ្រៀមទុកសម្រាប់ប្រទេសដែលមានចំណូលទាប | ទេ | | | | មាន | C៦០ | | |
| **៤.៦៖** ត្រឹមឆ្នាំ ២០៣០ ធានាថាយុវជន និងមនុស្សពេញវ័យភាគច្រើន ទាំងបុរស និងស្ត្រីសម្រេចបាននូវអក្ខរភាព និងចេះគិតលេខ | | | | | | | | | | |
| ជំនាញ | ២២. | ភាគរយនៃប្រជាជនតាមក្រុមអាយុដែលទទួលបានយ៉ាងហោចណាស់កម្រិតថេរនៃជំនាញ (ក) អក្ខរកម្ម វិជ្ជាជីវៈ និង (ខ)ជំនាញគិតលេខ | មាន | x | x | x | ៣-៥ ឆ្នាំ | | មាន | នៅពេលដែលប្រទេសដែលមានប្រាក់ចំណូលមធ្យម (STEP) និងប្រាក់ចំណូលខ្ពស់(PIAAC) ត្រូវបានវាយតម្លៃលើជំនាញអក្ខរកម្ម និងជំនាញគិតលេខរបស់មនុស្សពេញវ័យ ឧបករណ៍ ចំណាយមានប្រសិទ្ធិភាព សមនឹងតម្លៃមួយដែលត្រូវការ ដើម្បីឱ្យមានបញ្ចូលនៅក្នុងការស្ទាបស្ទង់មតិផ្សេងទៀតសម្រាប់ប្រើនៅទូទាំងប្រទេស។ |
| | ២៣. | អត្រាអក្ខរកម្មយុវជន/មនុស្សពេញវ័យ | មាន | x | x | | មាន | C ១៦០ | | អាយុផ្តោត គឺ១៥-២៤ ឆ្នាំ សម្រាប់យុវជន និង 15 ឆ្នាំឡើងសម្រាប់មនុស្សពេញវ័យ ប៉ុន្តែក្រុមអាយុផ្សេងទៀតក៏អាចបានដែរ។ |
| បទបញ្ញត្តិ | ២៤. | អត្រាចូលរួមរបស់យុវជន/ មនុស្សពេញវ័យក្នុងកម្មវិធីអក្ខរកម្ម | មាន | x | x | x | ៣-៥ ឆ្នាំ | | | ឧបករណ៍គួរតែត្រូវបានរៀបចំដោយភ្ជាប់ជាមួយសូចនាករទី ១៥។ |

**៤.៧៖** ត្រឹមឆ្នាំ ២០៣០ ធានាថាអ្នកសិក្សាទាំងអស់ទទួលបាននូវចំណេះដឹង និងជំនាញដែលត្រូវការដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព រួមបញ្ចូលទាំងចំណោមអ្នកដ៏ទៃទៀត តាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាព និងរបៀបរស់នៅដែលប្រកបដោយចីរភាព សិទ្ធិមនុស្ស សមភាពយេនឌ័រ លើកកម្ពស់វប្បធម៌ សន្តិភាពនិងអហឹង្សា ភាពជាពលរដ្ឋសកល និងការទទួលយកវប្បធម៌ចម្រុះ នៃការចូលរួមចំណែកដើម្បីការអភិវឌ្ឍដោយចីរភាព

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បទបញ្ញត្តិ | ២៥. | វិសាលភាពនៃ (i) ការអប់រំពលរដ្ឋសកល (ii) ការអប់រំសម្រាប់ការអភិវឌ្ឍដោយចីរភាពត្រូវបានបញ្ជ្រាបនៅក្នុង (ក)គោលនយោបាយអប់រំថ្នាក់ជាតិ (ខ)កម្មវិធីសិក្សា(គ) អប់រំគ្រូ និង(ឃ)វាយតម្លៃសិស្ស | ទេ | | | | ១-៣ ឆ្នាំ | | | កិច្ចការប្រកបដោយការចូលរួមតម្រូវឲ្យឈានទៅដល់ការមូលមតិគ្នាមួយស្តីថាតើគោលនយោបាយនៅកម្រិតថ្នាក់ជាតិដែលទាក់ទងនឹងគំនិតទាំងអស់នេះយ៉ាងដូចម្តេច។ ក្របខ័ណ្ឌនឹងតម្រូវអោយមានសម្រាប់គោលនយោបាយថ្នាក់ជាតិដើម្បីបកស្រាយ និង វាយតម្លៃ។ |
| ចំណេះដឹង | ២៦. | ភាគរយនៃសិស្សតាមក្រុមអាយុ (ឬ កម្រិតអប់រំ) បង្ហាញពីការយល់ដឹងពីបញ្ហាទាក់ទងទៅនឹងភាពជាពលរដ្ឋសកល និងចីរភាព | មាន | x | ? | ? | ៣-៥ ឆ្នាំ | | | បច្ចុប្បន្ននេះមិនមានការស្ទាបស្ទង់មតិណាមួយដែលប្រមូលទិន្នន័យចាំបាច់នោះទេ។ |
| | ២៧. | ភាគរយនៃសិស្សដែលមានអាយុ១៥ឆ្នាំបង្ហាញពីជំនាញនៅក្នុងចំណេះដឹងផ្នែកវិទ្យាសាស្ត្រ បរិស្ថាន និងផែនដីវិទ្យា | មាន | x | x | x | មាន | C៥៥ | មាន | ខណៈដែលទិន្នន័យកាន់តែច្រើន និងសូចនាករដែលពាក់ព័ន្ធជាច្រើនត្រូវបានបង្កើត សូចនាករនេះអាចត្រូវបានដាក់ជំនួស។ |
| បទបញ្ញត្តិ | ២៨ | ភាគរយនៃសាលារៀនដែលផ្តល់មូលដ្ឋានបំណិនជីវិត HIV និងការអប់រំបញ្ហាផ្លូវភេទ | ទេ | | | | ៣-៥ ឆ្នាំ | | | តម្រូវអោយមានការរៀបចំការងារដើម្បីឈានទៅដល់ការមូលមតិគ្នាមួយស្តីពីការកំណត់វិធីសាស្ត្រ បែបនេះ និងរៀបចំក្របខ័ណ្ឌសម្រាប់ប្រមូលទិន្នន័យ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ២៩. | វិសាលភាពនៃក្របខ័ណ្ឌចំពោះកម្មវិធីពិភពលោកស្តីពីការអប់រំសិទ្ធិមនុស្ស គឺត្រូវបានអនុវត្តន៍ទូទាំងប្រទេស(ដូចក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៩/១១៣) | ទេ | | | | ៣-៥ ឆ្នាំ | ទាំងអស់គ្នា | | តម្រូវអោយមានការរៀបចំការងារដើម្បីឈានទៅដល់ការមូលមតិគ្នាមួយ ថាតើក្របខ័ណ្ឌនេះអាចត្រូវបានពិនិត្យតាមដានយ៉ាងដូចម្តេច។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | **មធ្យោបាយនៃការអនុវត្ត ៤.ក-៤.ខ** | | | | | | | | |
| **៤.ក៖** ត្រឹមឆ្នាំ ២០៣០ កសាង និងធ្វើឱ្យប្រសើរឡើងនូវសម្ភារៈបរិក្ខារអប់រំ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ក៏ដូចជាពិការភាព យេនឌ័រ និងផ្តល់នូវបរិយាកាសសិក្សាដែលមានសុវត្ថិភាព អហឹង្សា បរិយាប័ន្ន និងមានប្រសិទ្ធិភាពសម្រាប់ទាំងអស់គ្នា | | | | | | | | | | |
| ធនធាន | ៣០. | ភាគរយនៃសាលារៀនដែលមាន (i) ទឹកពិសារ (ii) បង្គន់អនាម័យ(iii) សម្ភារៈលាងសម្អាតដៃ | មាន | | x | | ១-៣ ឆ្នាំ | | មាន | តម្រូវឲ្យមានការងារមួយចំនួនធំដើម្បីពង្រីកការគ្រប់ដណ្តប់កិច្ចខិតខំប្រឹងប្រែងប្រមូលទិន្នន័យបច្ចុប្បន្នក្នុងបណ្តាប្រទេសទាំងអស់ យោងលើនិយមន័យសូចនាករ WASH។ |
| | ៣១. | ភាគរយនៃសាលារៀនដែលមាន (i) អគ្គិសនី (ii) អ៊ីនធឺណិតសម្រាប់គោលបំណងគរុកោសល្យ និង (iii) កុំព្យូទ័រសម្រាប់គោលបំណងគរុកោសល្យ | មាន | | x | | មាន | C៧០ | មាន | |
| | ៣២. | ភាគរយនៃសាលារៀនដែលមានហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ទាំងឡាយសម្រាប់សិស្សមានពិការភាព | មាន | | x | | ៣-៥ ឆ្នាំ | | មាន | តម្រូវឲ្យមានត្រៀមការងារដើម្បីរៀបចំមធ្យោបាយស្តីពីលក្ខណៈវិនិច្ឆ័យវាយតម្លៃសម្រាប់លក្ខខ័ណ្ឌសាលាសម្រាប់ជនពិការទូទាំងប្រទេស។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បរិយាកាស | ៣៣. | ភាគរយនៃសិស្ស បានជួបប្រទះការ គំរាមកំហែង ការផ្តន្ទាទោស ការយាយី ហិង្សា ការរើសអើងផ្លូវភេទ និងការរំលោភបំពាន | មាន | x | x | x | មាន | ៨០ | | សូចនាករនេះអាចរក បានតាមរយៈការស្ទាប ស្ទង់មតិសុខភាព សិស្សតាមសាលាជា សកល។ |
| | ៣៤. | ចំនួននៃការវាយ ប្រហារទៅលើសិស្ស បុគ្គលិក និងស្ថាប័ន | ទេ | | | | ១-៣ ឆ្នាំ | | | តម្រូវឲ្យមានការងារ មួយចំនួនធំសម្រាប់ បង្កើតការប្រមូល ទិន្នន័យដើម្បីវាស់វែង នូវសូចនាករនេះ ដោយផ្អែកលើ ឧទាហរណ៍របាយ ការណ៍ស្ថាប័នអប់រំ ស្ថិតក្រោមការវាយ ប្រហារ។ |

**៤.ខ៖** ត្រឹមឆ្នាំ ២០២០ ពង្រីកឲ្យបានច្រើនជាសកល លើចំនួនអាហារូបករណ៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសបណ្តាប្រទេសដែលមាន ការអភិវឌ្ឍតិចតួចបំផុត កោះតូចៗនៃរដ្ឋកំពុងអភិវឌ្ឍន៍ និងប្រទេសនៅទ្វីបអាហ្វ្រិក សម្រាប់ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា រួមមានកម្មវិធី ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកវិទ្យាពត៌មាននិងសារគមនាគមន៍ បច្ចេកទេស ជំនាញ វិស្វកម្ម និងវិទ្យាសាស្ត្រ នៅក្នុងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួន | ៣៥. | ចំនួនអាហារូបករណ៍ថ្នាក់ឧត្តមសិក្សាដែលបានផ្តល់ឲ្យដោយប្រទេសដែលទទួលផល | ទេ | | | | ១-៣ ឆ្នាំ | | | តម្រូវឲ្យមានការងារត្រៀមរៀបចំមួយចំនួនសម្រាប់បង្កើតយន្តការប្រមូលទិន្នន័យ ដើម្បីវាស់វែងចំណុចដៅនេះ រួមបញ្ចូលទាំងការចែកចាយអាហារូបករណ៍ប្រកបដោយសមភាព។<br><br>រួមបញ្ចូលអាហារូបករណ៍ផ្តល់ដោយប្រទេសដែលបញ្ជូនសិស្សទៅបរទេស ក៏ដូចជាប្រទេសដើម ឬប្រទេសផ្តល់ជំនួយ និងអាហារូបករណ៍ពីមូលនិធិ និងស្ថាប័នឧត្តមសិក្សា ។ |
| | ៣៦. | ទំហំនៃជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) សម្រាប់អាហារូបករណ៍តាមវិស័យនិងប្រភេទនៃការសិក្សា | គ្មាន | | | | មាន | ទាំងអស់គ្នា | មាន | សូចនាករនេះគ្រាន់តែវាស់វែងប្រភពអាហារូបករណ៍មួយចំនួនប៉ុណ្ណោះ។ |

**៤.គ៖** ត្រឹមឆ្នាំ ២០៣០ បង្កើនយ៉ាងខ្លាំង ការផ្គត់ផ្គង់គ្រូដែលមានសមត្ថភាពដោយចីរភាព តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាពិសេសចំពោះប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុត និងកោះតូចៗដែលជារដ្ឋកំពុងអភិវឌ្ឍន៍។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| លក្ខណៈសម្បត្តិ | ៣៧. | ភាគរយនៃគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិស្របតាមស្តង់ដារជាតិ តាមកម្រិតអប់រំ និងប្រភេទនៃគ្រឹះស្ថានសិក្សា | មាន | x | x | | ១-៣ ឆ្នាំ | | | តម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងមួយចំនួនធំដើម្បីព្រមព្រៀងលើស្តង់ដាររួម និងធានានូវការគ្របដណ្តប់ដោយប្រភេទនៃគ្រឹះស្ថានសិក្សា។<br><br>គ្រូដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់យ៉ាងហោចណាស់មានលក្ខណៈសម្បត្តិឧត្តមសិក្សាអប្បបរមាតម្រូវដោយស្តង់ដារជាតិសម្រាប់ការបង្រៀនមុខវិជ្ជាជាក់លាក់។ |
| | ៣៨. | ផលធៀបសិស្ស និងគ្រូដែលមានលក្ខណៈសម្បត្តិតាមកម្រិតអប់រំ | គ្មាន | | | | មាន | | | |
| ដែលបានទទួលការបណ្តុះបណ្តាល | ៣៩. | ភាគរយនៃគ្រូបង្រៀននៅក្នុង<br>i- មត្តេយ្យសិក្សា<br>ii- បឋមសិក្សា<br>iii- មធ្យមសិក្សាបឋមភូមិនិង<br>iv- មធ្យមសិក្សាទុតិយភូមិជាគ្រូដែលបានទទួលយ៉ាងហោចណាស់ការបណ្តុះបណ្តាលដែលមានការទទួលស្គាល់អប្បបរមាទាំងមុនបង្រៀន និងក្នុងពេលបង្រៀន និងតម្រូវឲ្យមានគរុកោសល្យសម្រាប់បង្រៀនកម្រិតពាក់ព័ន្ធនៅក្នុងប្រទេស និងតាមប្រភេទគ្រឹះស្ថានសិក្សា | មាន | x | x | | មាន | | មាន | តម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីយល់ព្រមនឹងស្តង់ដាររួម និងធានានូវការគ្របដណ្តប់ដោយប្រភេទនៃគ្រឹះស្ថានសិក្សា។<br><br>គ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលយ៉ាងហោចណាស់ការបណ្តុះបណ្តាលគរុកោសល្យអប្បបរមាដែលតម្រូវដោយស្តង់ដារថ្នាក់ជាតិដើម្បីក្លាយជាគ្រូបង្រៀន។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ៤០. | ផលធៀបសិស្សគ្រូ ដែលទទួលការបណ្តុះបណ្តាលតាមកម្រិតនៃការអប់រំ | គ្មាន | | | | មាន | | | |
| ដែលមានការជំរុញលើកទឹកចិត្ត | ៤១. | ប្រាក់បៀវត្សគ្រូបង្រៀនជាមធ្យមទាក់ទងនឹងវិជ្ជាជីវៈដ៏ទៃទៀតតម្រូវឲ្យមានកម្រិតប្រៀបធៀបនៃគុណសម្បត្តិអប់រំ | គ្មាន | | | | ១-៣ ឆ្នាំ | | | តម្រូវឲ្យមានត្រៀមរៀបចំដើម្បីបង្កើតវិធីសាស្ត្រផ្អែកលើទិន្នន័យកម្លាំងពលកម្ម។ |
| | ៤២. | អត្រាបាត់បង់គ្រូបង្រៀនតាមកម្រិតអប់រំ | គ្មាន | x | | | ១-៣ ឆ្នាំ | | | តម្រូវឲ្យមានការងារមួយចំនួនធំដើម្បីពង្រីកការគ្របដណ្តប់នៃការប្រមូលទិន្នន័យបច្ចុប្បន្ន នៅគ្រប់ប្រទេសទាំងអស់។ |
| ដែលមានការគាំទ្រ | ៤៣. | ភាគរយនៃគ្រូបង្រៀនដែលទទួលបានសេវាបណ្តុះបណ្តាល ក្នុងរយៈពេល១២ខែចុងក្រោយតាមប្រភេទនៃការបណ្តុះបណ្តាល | គ្មាន | x | | | ៣-៥ ឆ្នាំ | | | តម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាដើម្បីបង្កើតឧបករណ៍វាយតម្លៃ ឧប្បត្តិហេតុ រយៈពេល និងខ្លឹមសារនៃការបណ្តុះបណ្តាល។ |

**សំគាល់៖** Column ១០ បង្ហាញពីសូចនាករដែលបានស្នើសុំឡើងដោយប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ដែលត្រូវដាក់បញ្ចូលក្នុងការកំណត់ជាសកលនៃសូចនាករសម្រាប់ពិនិត្យគោលដៅនៃរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍដោយចីរភាព ដែលកំពុងត្រូវបានអភិវឌ្ឍន៍ដោយអន្តរភ្នាក់ងារ និងក្រុមជំនាញការ ស្តីពីសូចនាករគោលដៅអភិវឌ្ឍន៍ដោយចីរភាព( IAEG-SDGs )

# ឯកសារយោង


i United Nations. 2015. Transforming our world: the 2030 Agenda for Sustainable Development. https://sustainabledevelopment.un.org/post2015/transformingourworld.

ii UNESCO. 2014. 2014 GEM Final Statement: The Muscat Agreement. http://unesdoc.unesco.org/images/0022/002281/228122E.pdf.

iii Adapted from: UNESCO. 2015. *Rethinking Education: Towards a global common good?* http://unesdoc.unesco.org/images/0023/002325/232555e.pdf.

iv UNICEF. 2015. *The Investment Case for Education and Equity.* www.unicef.org/publications/files/Investment_Case_for_Education_and_Equity_FINAL.pdf.

v UNESCO. 2015. *Rethinking Education,* op. cit., p.10.

vi UNESCO. 2014. *EFA Global Monitoring Report 2013/4 – Teaching and Learning: Achieving Quality for All.* http://unesdoc.unesco.org/images/0022/002256/225660e.pdf.

vii Banks, L.M. and Polack, S. *The Economic Costs of Exclusion and Gains of Inclusion of People with Disabilities: Evidence from Low and Middle Income Countries.* http://disabilitycentre.lshtm.ac.uk/files/2014/07/Costs-of-Exclusion-and-Gains-of-Inclusion-Report.pdf.

viii United Nations. 1948. Universal Declaration of Human Rights. www.un.org/en/documents/udhr.

ix UNESCO. 1960. Convention against Discrimination in Education. www.unesco.org/education/pdf/DISCRI_E.PDF.

x United Nations. 1989. Convention on the Rights of the Child. www.ohchr.org/en/professionalinterest/pages/crc.aspx.

xi United Nations. 1960. International Covenant on Economic, Social and Cultural Rights. www.ohchr.org/EN/ProfessionalInterest/Pages/CESCR.aspx. The covenant states (Art. 13.2) that '(a) Primaryeducation shall be compulsory and available free to all; (b) Secondary education in its different forms, including technical and vocational secondary education, shall be made generally available and accessible to all by every appropriate means, and in particular by the progressive introduction of free education; (c) Higher education shall be made equally accessible to all, on the basis of capacity, by every appropriate means, and in particular by the progressive introduction of free education'.

xii United Nations. 2006. Convention on the Rights of Persons with Disabilities. www.un.org/disabilities/convention/conventionfull.shtml.

xiii United Nations. 1979. Convention on the Elimination of All Forms of Discrimination against Women. www.un.org/womenwatch/daw/cedaw/text/econvention.htm.

xiv United Nations. 1951. Convention relating to the Status of Refugees. www.unhcr.org/3b66c2aa10.html.

xv United Nations. 2010. Resolution on the Right to Education in Emergency Situations. www.ineesite.org/uploads/files/resources/UN_Resolution_Education_in_Emergencies.pdf.

xvi Adapted from: UNESCO. 2015. Rethinking Education, op. cit.

xvii United Nations. n.d. Definition of key terms used in the UN Treaty Collection. http://treaties.un.org/Pages/Overview.aspx?path=overview/definition/page1_en.xml.

xviii UIS/EFA GMR. 2015. *A growing number of children and adolescents are out of school as aid fails to meet the mark.* Policy paper 22/Fact sheet 31. http://unesdoc.unesco.org/images/0023/002336/233610e.pdf.

xix UNESCO. 2012. *EFA Global Monitoring Report 2012 – Youth and Skills: Putting education to work.* http://unesdoc.unesco.org/images/0021/002180/218003e.pdf.

xx See for example:
European Union. 2007. *Key Competences for Lifelong Learning – European Reference Framework.* www.alfa-trall.eu/wp-content/uploads/2012/01/EU2007-keyCompetencesL3-brochure.pdf.
World Bank. 2011. *Learning for All: Investing in People's Knowledge and Skills to Promote Development.* http://siteresources.worldbank.org/EDUCATION/Resources/ESSU/Education_Strategy_4_12_2011.pdf.
UNESCO. 2012. *EFA Global Monitoring Report 2012,* op. cit.
UNESCO Bangkok. 2015. *Transversal Competencies in Education Policy and Practice (Phase I).* http://unesdoc.unesco.org/images/0023/002319/231907E.pdf.

xxi Consultative Group on Early Childhood Care and Development. n.d. *Early Childhood Development on the Post 2015 Development Agenda.* www.ecdgroup.com/pdfs/Response-to-HLP-Report-2013_final.pdf.

xxii UNESCO. 2015. *EFA Global Monitoring Report 2015,* op. cit.

xxiii UIS database for 2000 and 2013 data. http://data.uis.unesco.org.

xxiv UIS. 2012. International Standard Classification of Education: ISCED 2011. http://www.uis.unesco.org/Education/Documents/isced-2011-en.pdf.

xxv OECD. 2013. The skills needed for the 21st century. *OECD Skills Outlook 2013: First Results from the Survey of Adult Skills, Chapter 1.* http://skills.oecd.org/documents/SkillsOutlook_2013_Chapter1.pdf.

xxvi UNESCO. 2015. *EFA Global Monitoring Report 2015*, op. cit.

xxvii Ibid.

xxviii Ibid.
xxix Plan International. 2012. *The State of the World's Girls 2012: Learning for Life.* https://plan-international.org/state-worlds-girls-2012-learning-life.
xxx UNESCO Institute for Lifelong Learning. 2010. CONFINTEA VI Sixth International Conference on Adult Education: Final report. http://unesdoc.unesco.org/images/0018/001877/187790e.pdf.
xxxi UNESCO. 2008. *The Global Literacy Challenge: A profile of youth and adult literacy at the mid-point of the United Nations Literacy Decade 2003–2012.* http://unesdoc.unesco.org/images/0016/001631/163170e.pdf.
xxxii UIS. 2015. Adult and Youth Literacy: UIS Factsheet. www.uis.unesco.org/literacy/Documents/fs32-2015-literacy.pdf.
xxxiii OECD. 2010. PISA 2009 Results: *What Students Know and Can Do – Student Performance in Reading, Math and Science.* www.oecd.org/pisa/pisaproducts/48852548.pdf.
xxxiv UNESCO. 2014. *Shaping the Future We Want: UN Decade of Education for Sustainable Development (2005-2014) – Final Report.* http://unesdoc.unesco.org/images/0023/002303/230302e.pdf.
xxxv UNICEF. 2012. *Water, Sanitation and Hygiene: 2012 Annual Report.* www.unicef.org/wash/files/2012_WASH_Annual_Report_14August2013_eversion_(1).pdf.
xxxvi Plan International. 2012. *A Girl's Right to Learn Without Fear: Working to end gender-based violence at school.* https://plan-international.org/girls-right-learn-without-fear.
xxxvii United Nations Girls' Education Initiative. n.d. End School-Related Gender-Based Violence. Infographic. www.ungei.org/news/files/ENGLISH_SRGBV_INFOGRAPHIC_NOV2014_FINAL.pdf.
xxxviii UNESCO. 2014. *Education for All Global Monitoring Report 2013/14. Teaching and Learning: Achieving quality for all – Gender Summary*. http://unesdoc.unesco.org/images/0022/002266/226662E.pdf.
xxxix UNESCO. 2014. *EFA Global Monitoring Report 2013/4,* op. cit.
xl UIS/EFA GMR. 2014. Wanted: Trained teachers to ensure every child's right to primary education. Policy paper 15/Fact sheet 30. www.uis.unesco.org/Education/Documents/fs30-teachers-en.pdf.
xli UNESCO. 2014. *EFA Global Monitoring Report 2013/4,* op. cit.
xlii UIS/EFA GMR. 2014. Wanted: Trained teachers to ensure every child's right to primary education, op. cit., and UIS database for 2012 trained teacher numbers. http://data.uis.unesco.org.
xliii Norwegian Ministry of Foreign Affairs. 2015. Chair's Statement – The Oslo Declaration. www.osloeducationsummit.no/pop.cfm?FuseAction=Doc&pAction=View&pDocumentId=63448.
xliv United Nations. 2015. The Addis Ababa Action Agenda of the Third International Conference on Financing for Development. http://daccess-dds-ny.un.org/doc/UNDOC/GEN/N15/232/22/PDF/N1523222.pdf?OpenElement.
xlv UNESCO. 2015. *EFA Global Monitoring Report 2015,* op. cit.
xlvi UNESCO. 2015. Pricing the right to education: The cost of reaching new targets by 2030. EFA GMR Policy Paper 18. http://unesdoc.unesco.org/images/0023/002321/232197E.pdf.
xlvii UNESCO. 2000. Dakar Framework for Action, p. 9. http://unesdoc.unesco.org/images/0012/001211/121147e.pdf.
xlviii UNESCO. 2015. Pricing the right to education, op. cit.
xlix UNESCO. 2015. Humanitarian Aid for Education: Why it Matters and Why More is Needed. EFA GMR Policy Paper 21. http://unesdoc.unesco.org/images/0023/002335/233557E.pdf.
l See UNESCO and UNICEF. 2013. *Making Education a Priority in the Post-2015 Development Agenda: Report of the Global Thematic Consultation on Education in the Post-2015 Development Agenda.* www.unicef.org/education/files/Making_Education_a_Priority_in_the_Post-2015_Development_Agenda.pdf.

ផលិតដោយ :

ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល
NGO EDUCATION PARTNERSHIP

ឧបត្ថម្ភដោយ :

Asia South Pacific Association for Basic and Adult Education
Learning Beyond Boundaries